សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droitet des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ
# សណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


| តាក់តែងឡើងដោយ | | សាស្ត្រាចារ្យណែនាំ |
|---|---|---|
| និស្សិតឈ្មោះ៖ | លោក **សោភ័ណ ថារ៉ូ** | លោក **បណ្ឌិត អ៊ុន សកក្កដា** |
| | លោក **ហួរ ហុកសេង** | |

| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ | ឆ្នាំចូលរៀន | ២០១៣ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា | ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តជំនាន់ទី ១៧ ឆ្នាំទី ៤ នៃ សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចមានរាយនាមដូចខាងក្រោមៈ

១. លោក សោភ័ណ ថារ៉ូ

២.លោក ហួរ ហុកសេង

ជាបឋមខ្ញុំបាទសូមរំលឹកដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរគឺ លោក ឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើតដល់យើងខ្ញុំទាំងពីរនាក់ហើយបានខិតខំប្រឹងប្រែងចិញ្ចឹម បីបាច់ថែរក្សាផ្តល់ឱកាសឲ្យពួកយើងបានសិក្សារៀនសូត្ររហូតមកទល់ពេលបច្ចុប្បន្ន ហើយនឹង ឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅក្នុងឆ្នាំនេះ។

ខ្ញុំបាទសូមថ្លែងអំណរអគុណដល់ ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសកលវិទ្យាល័យភូមិន្ទ នីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានខិតខំចំណាយពេលវេលា និងកំលាំងកាយចិត្ត បង្រៀនខ្ញុំបាទតាំងពីឆ្នាំទីមួយរហូតមកទល់ពេលនេះ។ ប្រសិនបើគ្មានលោកទាំងអស់ទេក៏ពួកខ្ញុំ បាទគ្មានថ្ងៃនេះដែរ ពួកខ្ញុំសូមសន្យាថានឹងយកចំណេះដឹងទាំងអស់ទៅប្រើប្រាស់ជាប្រយោជន៍ ជួយដល់សង្គមជាតិទាំងមូល និងខិតខំជួយអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យកាន់តែរីកចំរើនទៅមុខជា លំដាប់។

សូមអគុណយ៉ាងជ្រាលជ្រៅដល់ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សតក្កដា** ជាសាស្ត្រាចារ្យណែនាំរបស់ខ្ញុំបាទ ដែលបានធ្វើការដឹកនាំ កែលំអរ និងផ្តល់យោបល់ល្អៗដល់ យើងខ្ញុំរហូតសម្រេចបានជោគជ័យក្នុងការតាក់តែងសារណានេះឡើង។

ជាចុងបញ្ចប់ខ្ញុំបាទទាំងពីរសូមអគុណដល់មន្ត្រីរាជការទាំងអស់ ដែលបានចំណាយពេល វេលាដ៏មានតំលៃក្នុងការតាក់តែងជាឯកសារ ដែលផ្តល់គំនិតល្អៗជាច្រើនដល់ការស្រាវជ្រាវ សារណានេះឡើង។ សូមអស់លោកទាំងអស់គ្នាជួបតែសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពុលៈ កុំបីឃ្លាឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីខ្ញុំបាទ បានសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេល៤ឆ្នាំ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រកន្លងមកនេះ ខ្ញុំបាទបានទទួលនូវចំនេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តី និងការអនុវត្តន៍នៅក្នុងផ្នែកនេះ។ យោងតាមចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយបាននាំឲ្យខ្ញុំបាទមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សាមួយ។ នេះជាឱកាសដ៏វិសេសវិសាលមួយដែលខ្ញុំបាទអាចវាស់ស្ទង់ចំនេះដឹងរបស់ខ្ញុំបាទផ្ទាល់ដែលខ្ញុំមានពីមុន និងការស្រាវជ្រាវបន្ថែម។ ហេតុនេះទើបខ្ញុំបានជ្រើសរើសយកប្រធានបទ "**ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យ**" មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវនៃការសរសេរសារណាបញ្ចប់ការសិក្សានេះ។

កម្មវត្ថុចំបងដែលខ្ញុំបាទសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវព្រោះប្រធានបទស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យ មានសារសំខាន់ណាស់ផ្នែកទ្រឹស្តីដល់ការអភិវឌ្ឍន៍ខណ្ឌឲ្យមានភាពល្អប្រសើរ។ ដោយសារតែការគ្រប់គ្រងបានល្អបានធ្វើឲ្យខណ្ឌមានការអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្មខ្លាំង ប៉ុន្តែបើប្រៀបនឹងខណ្ឌដទៃគឺនៅមានភាពអន់ថយនៅឡើយ។ ចំពោះផ្នែកគមនាគមន៍វិញក៏មានការរីកចំរើនខ្លាំងផងដែរ ដែលធ្វើឲ្យប្រជាជនរស់នៅក្នុងខណ្ឌមានភាពងាយស្រួលក្នុងការរស់នៅប្រចាំថ្ងៃ។ ដោយឡែកទោះជាមានការរីកចំរើនយ៉ាងណាបញ្ហាកកស្ទះនៅតែមាន។ មួយវិញទៀតបរិស្ថានក៏ជាបញ្ហាមួយដែរ ពោលគឺការបំពុលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ដោយឃើញពីបញ្ហាទាំងអស់នេះហើយទើបខ្ញុំបាទសម្រេចចិត្តស្រាវជ្រាវសរសេរសារណាស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យ នេះឡើងដើម្បីជួយផ្តល់ជាយោបល់មួយផ្នែកក្នុងការជួយដោះស្រាយបញ្ហាដែលខណ្ឌកំពុងតែជួបប្រទះ ដើម្បីការអភិវឌ្ឍន៍ខណ្ឌឲ្យកាន់តែប្រសើរជាងនេះទៀត។

ជាចុងក្រោយខ្ញុំបាទសូមអភ័យទោសចំពោះ កំហុសខុសឆ្គងដោយអចេតនាទាំងឡាយដែលកើតមានឡើងក្នុងការសរសេរសារណានេះទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ។ ខ្ញុំបាទសូមស្វាគមន៍ចំពោះការរិះគន់ទាំងឡាយណាដែលក្នុងន័យស្ថាបនា និងការផ្តល់ជាមតិយោបល់ផ្សេងៗក្នុងសារណាពីសំណាក់លោក លោកស្រី និងមិត្តអ្នកអានគ្រប់ពេលវេលា។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

## ជំពូកទី១ ៖ ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌមានជ័យ

**១.១. ទិដ្ឋភាពទូទៅ** ........ ៣

**១.១.១. មូលហេតុនាំឲ្យមានការរៀបចំ** ........ ៦

១.១.១.១. បញ្ហាកំណើនប្រជាជន ........ ៩

១.១.១.២. បញ្ហាចរាចរណ៍ ........ ១០

១.១.១.៣. បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់ ........ ១០

**១.១.២. រចនាសម្ព័ន្ធខណ្ឌមានជ័យ** ........ ១០

**១.២. បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌមានជ័យ** ........ ១២

**១.២.១. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខណ្ឌមានជ័យ** ........ ១៣

១.២.១.១. ប្រព័ន្ធគមនាគមន៍ ........ ១៣

១.២.១.២. ផ្លូវថ្នល់ ........ ១៣

១.២.១.៣. ស្ពានអាកាស ........ ១៥

**១.២.២. ការអភិវឌ្ឍន៍ផ្នែក សំណង់ លំនៅស្ថាន** ........ ១៧

១.២.២.១. រោងចក្រ ........ ១៧

១.២.២.២. លំនៅស្ថាន ........ ១៧

១.២.២.៣. បុរី និងសំណង់សហាកម្មសិទ្ធិ ........ ១៨

១.២.២.៤. សំណង់អាគារផ្សេងៗ ........ ១៨

## ជំពូកទី២ ៖ បរិស្ថានក្នុងខណ្ឌមានជ័យ

**២.១. ហេតុបង្ករនាំឲ្យមានការបំពុលបរិស្ថាន** ........ ២០

**២.១.១. ហេតុបង្ករនាំឲ្យមានការបំពុល ទឹក ដី និងខ្យល់** ........ ២០

២.១.១.១. ហេតុបង្ករឲ្យមានការបំពុល ទឹក ........ ២១

ក. ហេតុបង្ករ ........ ២១

ខ. ផលប៉ះពាល់ ........ ២២

២.១.១.២. ហេតុបង្ករឲ្យមានការបំពុល ដី ........ ២២

ក. ហេតុបង្ករ ........ ២២

ខ. ផលប៉ះពាល់ ........ ២៣

២.១.១.៣. ហេតុបង្ករឲ្យមានការបំពុល ខ្យល់ ....... ២៣
ក. ហេតុបង្ករ ....... ២៣
ខ. ផលប៉ះពាល់ ....... ២៥
**២.១.២. ហេតុបង្ករនាំឲ្យមានការបំពុលដោយ សំណល់រឹង រាវ និងសំលេង** ....... ២៦
២.១.២.១. ហេតុបង្ករឲ្យមានការបំពុលដោយ សំណល់រឹង ....... ២៦
ក. ហេតុបង្ករ ....... ២៦
ខ. ផលប៉ះពាល់ ....... ២៧
២.១.២.២. ហេតុបង្ករឲ្យមានការបំពុលដោយ សំណល់រាវ ....... ២៧
ក. ហេតុបង្ករ ....... ២៧
ខ. ផលប៉ះពាល់ ....... ២៨
២.១.២.៣. ហេតុបង្ករឲ្យមានការបំពុលដោយ សំលេង ....... ២៨
ក. ហេតុបង្ករ ....... ២៩
ខ. ផលប៉ះពាល់ ....... ២៩
**២.២. បញ្ហាបរិស្ថានក្នុងខណ្ឌមានជ័យ** ....... ៣០
**២.២.១. ការបំពុលដោយកាកសំណល់រឹង និងរាវ** ....... ៣០
**២.២.២. ការបំពុលខ្យល់** ....... ៣១
**២.២.៣. ការបំពុលទឹក** ....... ៣២
**២.៣. វិធានការដោះស្រាយទៅនឹងការបំពុលបរិស្ថាន** ....... ៣៣
**២.៣.១. វិធានការដោះស្រាយទៅនឹងការបំពុលទឹក ដី និងខ្យល់** ....... ៣៤
២.៣.១.១ វិធានការដោះស្រាយទៅនឹងការបំពុលទឹក ....... ៣៤
ក. វិធានការកាត់បន្ថយការបំពុលទឹក ....... ៣៥
ខ. វិធានការដោះស្រាយការបំពុលទឹក ....... ៣៥
២.៣.១.២.វិធានការដោះស្រាយទៅនឹងការបំពុលដី ....... ៣៧
២.៣.១.៣.វិធានការដោះស្រាយទៅនឹងការបំពុលខ្យល់ ....... ៣៧
**២.៣.២. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំណង់រឹង រាវ និងសំលេង** ....... ៣៩
២.៣.២.១. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំណល់រឹង ....... ៣៩
២.៣.២.២. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំណល់រាវ ....... ៤១
២.៣.២.៣. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំលេង ....... ៤២
**សេចក្តីសន្និដ្ឋាន** ....... ៤៣

**អនុសាសន៍** .......................................................................................................... ៩៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលទើបតែងើបផុតពីសង្គ្រាម នឹងទទួលបាននូវសុខសន្តិភាពបានប្រមាណជិត ៤០ ឆ្នាំ។ នៅក្នុងកម្លុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម ឬអាចហៅម្យ៉ាងទៀតថារបបប្រល័យពូជសាសន៍ គឺជាពេលដែលប្រទេសកម្ពុជាបានធ្លាក់ដល់ចំណុចសូន្យ។ នៅក្នុងសម័យនោះ ប្រជាជនត្រូវបានជំលៀសចេញពីផុតពីទីក្រុងដែលបានធ្វើឲ្យទីក្រុងភ្នំពេញក្លាយជាទីក្រុងខ្មោច។ មិនតែប៉ុណ្ណោះ ហេដ្ឋារចនាសម្ព័ន្ធ រួមមានដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ វត្តអារាមស្ពាន រោងចក្រ និងសំណង់អាគារផ្សេងៗទៀតត្រូវបាន វាយបំផ្លិចបំផ្លាញគ្មានសល់។

ប៉ុន្តែមិនយូរប៉ុន្មាន ប្រទេសកម្ពុជាក៏បានរំដោះផុតពីរបបដ៏សាហាវឃោរឃៅនេះ ហើយបានចាប់ផ្តើមកសាងប្រទេសសាជាថ្មីចាប់ពីចំណុចសូន្យ។ ដោយការខិតខំប្រឹងប្រែង និងបូករួមជាមួយការជួយជ្រោមជ្រែងពីសំណាក់ប្រទេសដទៃផងនោះ មកដល់ឥឡូវប្រទេសកម្ពុជាកបានចាប់ផ្តើមមានការអភិវឌ្ឍន៍យ៉ាងខ្លាំងគួរឲ្យកត់សំគាល់ ជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញតែម្តង។

មកដល់សព្វថ្ងៃនេះ យើងសង្កេតឃើញថានៅក្នុងរាជធានីភ្នំពេញមានការរីកចំរើនខ្លាំងបើប្រៀបធៀបទៅនឹងស្ថានភាពកាលពីមុន។ រាជធានីភ្នំពេញសព្វថ្ងៃគឺមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសគឺទៅលើវិស័យនគរូបនីយកម្មតែម្តង។ អាគារធំៗ ខ្ពស់ៗ ជាច្រើនបាន និងកំពុងលេចរូបរាងឡើងជាបន្តបន្ទាប់។ ក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន គឺល្អប្រសើរជាងមុនដោយមានការកសាងផ្លូវថ្នល់ និងស្ពានជាច្រើនខ្វាត់ខ្វែងដែលធ្វើឲ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការធ្វើដំណើរ។ លើសពីនេះទៅទៀត ស្ថានភាពផ្លូវគមនាគមន៍ក៏មានភាពល្អប្រសើរជាងមុន ផ្លូវដីត្រូវបានជំនួសដោយផ្លូវក្រាលកៅស៊ូ និងស៊ីម៉ង់ត៍ រីឯទំហំនៃផ្លូវថ្នល់ ក៏ត្រូវបានពង្រីកផងដែរ។

ដើម្បីធានាបាននូវសុវត្ថិភាពរបស់ប្រជាជនឲ្យចៀសរួចផុតពីគ្រោះថ្នាក់ សាលារាជធានីភ្នំពេញបានចេញវិធានការថ្មីៗជាច្រើន។ ស្ពានជាច្រើនបានសាងសង់ ដើម្បីភាពងាយស្រួលរបស់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ ដោយមិនចាំបាច់ប្រើប្រាស់សាឡាងក្នុងការឆ្លងទឹក ដែលមានភាពប្រថុយប្រថានទៀតនោះទេ។ ប្រព័ន្ធភ្លើងអគ្គិសនីត្រូវបានតឆ្វាត់ឆ្វែងក្នុងការផ្គត់ផ្គង់ទៅដល់ប្រជាពរដ្ឋគ្រប់កន្លែងនៅក្នុងរាជធានី ពុំមានការខ្វះខាតដូចកាលពីមុនទៀតនោះទេ។ ដូចគ្នានោះដែរប្រព័ន្ធទឹកស្អាតនៅក្នុងរាជធានីភ្នំពេញក៏បានតពាសពេញរាជធានីផ្គត់ផ្គង់ប្រជាពលរដ្ឋប្រើប្រាស់គ្រប់លំនៅស្ថាន។

បើប្រៀបធៀបទៅនឹងអតីតកាល ប្រទេសកម្ពុជាមានការរីកចំរើន និងអភិវឌ្ឍន៍ជាងមុនខ្លាំងណាស់។ ប៉ុន្តែបើប្រៀបធៀបទៅនឹងប្រទេសដទៃ ដូចជាប្រទេសថៃជាដើម ប្រទេសយើងនៅមានភាពខ្វះចន្លោះនៅឡើយដែលទាមទារឲ្យមានការអភិវឌ្ឍន៍បន្ថែមទៀត។ ទន្ទឹមនឹងការអភិវឌ្ឍន៍ បញ្ហាមួយ

ចំនួនក៏បានលេចឡើងជាមួយផងដែរ។ បញ្ហាដូចជា បញ្ហាចរាចរណ៍ ប្រព័ន្ធលូ ផ្លូវថ្នល់ សំណង់អាគារ ការបំពុល និងបញ្ហាជាច្រើនទៀតបានចោទឡើង។

ដោយមើលឃើញនូវបញ្ហាទាំងនេះ ក្រុមខ្ញុំបាទសំរេច សរសេរសារណាមួយក្រោមប្រធានបទថា "**ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យ**"។ មូលហេតុដែលយើងជ្រើសរើសនិយាយពីខណ្ឌមានជ័យពីព្រោះ ទីមួយគឺដោយសារតែតំបន់នេះគឺជាតំបន់មួយដែលសំបូរទៅដោយប្រភពបំពុល ទីពីរដោយសារតែខណ្ឌមានជ័យគឺមានការអភិវឌ្ឍន៍យឺតជាងខណ្ឌដទៃ និងចុងក្រោយគឺដោយសារតែយើងមិនអាចនិយាយពីរាជធានីភ្នំពេញទាំងមូលដូចនេះទើបយើងសំរេចយកនូវខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ មកនិយាយ។

នៅក្នុងប្រធានបទនេះដំបូងយើងបែងចែកជា២ជំពូកដូចតទៅៈ

- ជំពូកទី១ ៖ ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌមានជ័យ នឹងត្រូវលើកយកមកបកស្រាយ នៅក្នុងជំពូកនេះដែលជំពូកនេះមានពីរផ្នែកដោយផ្នែកទី ១ នឹងបកស្រាយទាក់ទងទៅនឹងទិដ្ឋភាពទូទៅនៃខណ្ឌមានជ័យ និង ផ្នែកទី ២ ដែលទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខណ្ឌមានជ័យ។
- ជំពូកទី២ ៖ បរិស្ថានក្នុងខណ្ឌមានជ័យ ត្រូវបានបកស្រាយក្នុងជំពូកនេះដោយជំពូកត្រូវបានបែងចែកជា បី ផ្នែក ដែលផ្នែកទី ១ នឹងផ្តោតទៅលើ កត្តាដែលបង្កអោយមានបញ្ហាបរិស្ថាន រីឯផ្នែកទី ២ នឹងលើកនូវបញ្ហាចំបងៗដែលកើតមានក្នុងខណ្ឌមានជ័យ និង ផ្នែកទី ៣ នឹងលើកឡើងនូវវិធានការដំណោះស្រាយទៅលើបញ្ហាទាំងនោះ។

# ជំពូកទី១

# ការរៀបចំសណ្ដាប់ធ្នាប់

# ខណ្ឌមានជ័យ

# ជំពូកទី១៖ ការរៀបចំសណ្តាប់ធ្នាប់ខណ្ឌមានជ័យ

មុននឹងចូលដល់ការនិយាយរៀបរាប់ពីការអភិវឌ្ឍន៍ និងការរៀបចំនៅខណ្ឌមានជ័យ យើងគួរតែស្វែងយល់ពីប្រវត្តិនៃការរៀបចំក្រុងដំបូងគេនៅលើសកលលោកជាមុនសិន។ ទីក្រុងដំបូងគេនៅលើសកលលោក គឺទីក្រុង Faiyum នៅប្រទេសអេហ្សីបដែលមានអាយុកាលប្រមាណ ៥០០០ឆ្នាំមុនគ្រិស្តសករាជ។ ទីក្រុងនេះមានទីតាំងនៅចំកណ្តាលប្រទេសអេហ្ស៊ីប មានចំងាយ១០០គីឡូម៉ែត្រពីទិសខាងត្បូងឆៀងខាងលិចនៃទីក្រុង Cario។

ចំពោះការរៀបចំក្រុងវិញ ទីក្រុងFaiyumគឺមានសមិទ្ធិផលមួយចំនួនគួរឲ្យកត់សម្គាល់។ នៅក្នុងការស្រាវជ្រាវរបស់ប្រវត្តិវិទូបានបង្ហាញឲ្យឃើញថា ទីក្រុងFaiyum មានការរៀបចំយ៉ាងល្អ។ តាមការស្រាវជ្រាវគេបានរកឃើញនូវវត្ថុតាងសេសសល់មួយចំនួនដែលអាចកំណត់បានថា នៅសម័យនោះគឺមានស្ថាបនា ផ្សារ វិហារសាសនា កន្លែងងូតទឹក ស្ពាន និងមាននូវប្រព័ន្ធធារាសាស្ត្រ ដើម្បីផ្គត់ផ្គង់តំរូវការរបស់ប្រជាពលរដ្ឋ។[1]

## ១.១. និដ្ឋភាពទូទៅ

ដើម្បីឲ្យមានភាពងាយស្រួលដល់ការបកស្រាយ និងដើម្បីឲ្យមានភាពងាយស្រួលក្នុងការយល់អត្ថន័យនៃប្រធានបទទាំងមូលយើងគួរគប្បីយល់នូវពាក្យគន្លឹះមួយចំនួនសិន។ ពាក្យគន្លឹះទាំងនោះរួមមាន៖ រាជធានី សណ្តាប់ធ្នាប់ និងបរិស្ថាន។

**រាជធានី** ៖ សំដៅទៅលើទីកន្លែងដែលមិនមានសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យផ្សេងទៀតអាចរួមបញ្ចូល៖ ចំនួនប្រជាជន ទីធ្លាទំនេរ ដង់ស៊ីតេប្រជាជន និងចរន្តសេដ្ឋកិច្ច។[2] រាជធានីក៏អាចមានន័យសំដៅទៅលើ នគរ ទីក្រុង បុរី។[3]

**សណ្តាប់ធ្នាប់** ៖ សំដៅទៅលើធាតុ៣ ៖ សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ។[4]

**បរិស្ថាន** ៖ នូវរាល់អ្វីៗដែលនៅជុំវិញខ្លួនយើង ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។

+ប្រវត្តិរាជធានីភ្នំពេញ

រាជធានីភ្នំពេញត្រូវបានរកឃើញ និងបង្កើតឡើងដោយលោកយាយពេញនៅក្នុងឆ្នាំ ១៣៧២ ហើយបានក្លាយជារាជធានីរបស់ប្រទេសកម្ពុជាតាំងពីឆ្នាំ ១៨៦៥ រហូតមកដល់សព្វថ្ងៃ។ រាជធានីភ្នំពេញមានការរីកចំរើនយ៉ាងខ្លាំងនៅមុនសម័យខ្មែរក្រហម។ ប៉ុន្តែគួរឲ្យស្តាយការរីកចំរើននេះមិនមាន

---

[1] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ទំព័រទី១ ដល់៥

[2] Long, 1998

[3] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជជួនណាត

[4] និតិរដ្ឋបាលទូទៅ ឯកឧត្តម បណ្ឌិត ចេង ច័ន្ទសង្វារ

ភាពស្ថិតស្ថេរយូរអង្វែងនោះទេ។ នៅក្នុងកម្លុងឆ្នាំ១៩៧៥ ប្រទេសកម្ពុជាត្រូវបានចាប់ផ្តើមមានសង្គ្រាមកើតឡើងជាបន្តបន្ទាប់។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបាន ធ្លាក់ចូលក្នុងរបបដ៏ខ្មៅងងឹត ពោលគឺរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ នាសម័យនោះ ទីក្រុងភ្នំពេញ ត្រូវបានប្រែប្រួលទាំងស្រុង។ ប្រជាជនដែលរស់នៅក្នុងទីក្រុងត្រូវបានទាហានខ្មែរក្រហមជំលៀសចេញទៅតាមបណ្តារខេត្តនានា ធ្វើឲ្យទីក្រុងដែលធ្លាប់តែសំបូរសប្បាយ អ៊ូអរ ក្លាយទៅជាទីក្រុងខ្មោចគ្មានមនុស្សរស់នៅ។ ឥវ៉ាន់នៅក្នុងផ្ទះត្រូវបានរើបោះទំលាក់ចេញមកខាងក្រៅ។ ទីក្រុងភ្នំពេញទាំងមូល ដែលធ្លាប់តែមានមនុស្សច្រើនកុះករ ត្រូវជំនួសដោយទាហាន និងកងទ័ពបំពាក់ដោយកាំភ្លើងគ្រប់ដៃ។ រីឯផ្ទះដែលធ្លាប់តែមានមនុស្សរស់នៅ ត្រូវបានចំហទ្វាចោល។ រថយន្ត ម៉ូតូ និងកង់ដែលធ្វើដំណើរនៅក្នុងទីក្រុង ត្រូវបានជំនួសដោយរថក្រោះទៅវិញ។[5] ទោះជាយ៉ាងណាក៏ដោយក៏របបនេះមិនបាននៅយូរអង្វែងដែរ ដោយរបបនេះបានដួលរលំទៅវិញនៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃដែលទីក្រុងភ្នំពេញ ត្រូវបានដណ្តើមបានទាំងស្រុងពីខ្មែរក្រហម និងជាថ្ងៃដែលទីក្រុងភ្នំពេញបានចាប់កំណើតសារជាថ្មី។

ក្រោយបានរំដោះពីរបបនេះ នៅថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ ប្រជាជនតិចតួចបំផុតបានចូលមករស់នៅតាមជាយក្រុង ដែលប្រជាជនទាំងនោះមកពីចំរុះខេត្ត ក្រុងនានា។ ដោយសារតែប្រទេសទើបតែរួចផុតពីសង្គ្រាមទីក្រុងភ្នំពេញទាំងមូលទទួលរងការបំផ្លាញខ្ទេចខ្ទីដែលធ្វើឲ្យ ប្រជាជនដែលទៅរស់នៅក្នុងទីក្រុងមានភាពលំបាកជាខ្លាំង។ ការរស់នៅក្នុងទីក្រុងនាសម័យនោះ ប្រជាជនត្រូវទ្រាំរស់នៅក្នុងស្ថានភាពលំបាកជាច្រើនដូចជា បញ្ហាទឹកស្អាត ភ្លើងអគ្គិសនី សន្តិសុខសណ្តាប់ធ្នាប់ជាដើម។ ប្រជាជនត្រូវប្រឈមមុខនឹងជីវភាពខ្វះខាត កង្វះនូវថ្នាំសង្កូវ សាលារៀន មន្ទីរពេទ្យ ។ល។ ទោះជាយ៉ាងណាក៏ដោយភាពលំបាកនេះមិនបានចោទជាបញ្ហាយូប៉ុន្មាននោះទេ។ ក្រោយឆ្នាំ១៩៨០មក ស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ គឺមានភាពប្រសើរឡើងជាបណ្តើរៗ។ ប្រព័ន្ធរូបីយប័ណ្ណប្រាក់រៀលមានទម្រង់ជាក្រដាស និងកាកបានចាប់ផ្តើមបោះពុម្ព និងធ្វើចរាចរណ៍ឡើងវិញ។ ចំណែកឯមធ្យោបាយធ្វើដំណើរ គឺប្រើប្រាស់តែ ម៉ូតូកង់ឌុប ឬរ៉ឺម៉កផាក់ជើងតែប៉ុណ្ណោះ។[6]

[5] *ឃាតករនៃទឹកដីស្លូតបូត*, ប៉ារ៉ឺន, ចន និង អ៊ែនថូនី-ផូល ឆ្នាំ១៩៧៧

[6] របាយការណ៍បូប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ "ការរៀបចំ និងប្រព្រឹត្តទៅនៃសាលាខ័ណ្ឌមានជ័យ" លោក ហ៊ិត ហ៊ុយ ទំព័រ៤

ក្រោយរបបប្រល័យពូជសាសន៍ប៉ុលពតមកដល់បច្ចុប្បន្នរាជធានីភ្នំពេញមានការកែសម្រួលព្រំប្រទល់ចំនួន៤ដំណាក់កាលមកហើយ។[7] កំណែសម្រួលព្រំប្រទល់ ទាំង៤ដំណាក់កាល នោះមានដូចជា៖

- លើកទីមួយ៖ ការបញ្ចូលស្រុកដង្កោ
- លើកទីពីរ៖ ការបង្កើតខណ្ឌឫស្សីកែវ
- លើកទីបី៖ ការបញ្ចូល ៨ ភូមិ របស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ
- លើកទីបួន៖ ការបញ្ចូល ២០ ឃុំ របស់ស្រុកចំនួន ៥ (ពញាឮ, មុខកំពូល, កៀនស្វាយ, កណ្ដាលស្ទឹង, អង្គស្នួល) នៃខេត្តកណ្ដាល មកក្នុងដែលដីរដ្ឋបាលរាជធានីភ្នំពេញ។

យោងតាមសាលារាជធានីភ្នំពេញ ពេលបច្ចុប្បន្នរាជធានីភ្នំពេញមានផ្ទៃដីសរុប ៦៧៨,៤៦ គីឡូម៉ែត្រក្រឡា ស្មើរនឹង០,៣៧% នៃផ្ទៃដីសរុបរបស់ប្រទេស។ ចំពោះប្រជាជនវិញ នៅក្នុងរាជធានីភ្នំពេញគឺមានសរុបចំនួន ១,៤៥៥,៨៨៨ នាក់(២០១៤) ដែលត្រូវជា ២៧៨,៧៥២ គ្រួសារ[8] ។ រាជធានីភ្នំពេញមានដង់ស៊ីតេមនុស្សរស់នៅ ២,១៣២ នាក់នៅក្នុងមួយគីឡូម៉ែត្រការ៉េ។ ចំណែកដែនដីនៅក្នុងរាជធានីវិញគឺបានបែងចែកជា ១២ខណ្ឌ ៩៦សង្កាត់ និង៩០៩ភូមិ។




[7] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧

[8] ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញលេខ១៩ ខែឧសភា ឆ្នាំ២០១៦ ទំព័រទី៤៥

ខណ្ឌទាំង ១២ របស់រាជធានីភ្នំពេញនោះមានដូចតទៅ៖

- ខណ្ឌ៧មករា
- ខណ្ឌទួលគោក
- ខណ្ឌដូនពេញ
- ខណ្ឌដង្កោ
- ខណ្ឌមានជ័យ
- ខណ្ឌឫស្សីកែវ
- ខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌសែនសុខ
- ខណ្ឌចំការមន
- ខណ្ឌច្បារអំពៅ (ថ្មី)
- ខណ្ឌជ្រោយចង្វារ (ថ្មី)
- ខណ្ឌព្រែកព្នៅ (ថ្មី)

ដោយសារតែការរៀបរាប់ពីរាជធានីភ្នំពេញទាំងមូល មានលក្ខណៈធំទូលាយពេក ដូចនេះនៅក្នុងអត្ថបទសារណានេះយើងនឹងកំរិតដែនកំណត់ និយាយតែពីខណ្ឌមានជ័យ មួយតែប៉ុណ្ណោះ។

**១.១.១. មូលហេតុនាំឲ្យមានការរៀបចំ**

ខណ្ឌមានជ័យ គឺជាខណ្ឌដ៏ចំណាស់មួយក្នុងចំណោមខណ្ឌទាំង ១២ នៃរាជធានីភ្នំពេញ។ ដំបូងទឹកដីខណ្ឌមានជ័យត្រូវបាន បង្កើតឡើងដោយមាន៤សង្កាត់។ សង្កាត់ទាំង៤នោះរួមមាន សង្កាត់ច្បារអំពៅ ស្ថិតនៅត្រើយខាងកើតនៃទន្លេបាសាក់ និងសង្កាត់ចំនួន៣ទៀត ដែលរួមមាន សង្កាត់ចាក់អង្រែ សង្កាត់បឹងទំពុន និងសង្កាត់ស្ទឹងមានជ័យ គឺស្ថិតនៅត្រើយខាងលិចនៃទន្លេបាសាក់។




ខណ្ឌមានជ័យមានផ្ទៃក្រលា ទំហំ ៥០,៨៦ គីឡូម៉ែត្រការ៉េ មានប្រជាជន

ចំនួន ១៩២,៨០៥ នាក់ (១៩៩៨) ភូមិចំនួន៦៧ និងសង្កាត់ចំនួន៨[9] នៅមុនពេលពង្រីករាជធានី និងបង្កើតខណ្ឌច្បារអំពៅ។

ប៉ុន្តែ ដោយមានការពង្រីករាជធានី និងមានការបង្កើតនូវខណ្ឌថ្មីចំនួន ៣ កាលពីឆ្នាំ ២០១៣ ដែលមាន ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ ថែមទៀតនោះ ទំហំ និងព្រំដែនរបស់ខណ្ឌមានជ័យក៏មានការប្រែប្រួល។

យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង រាជធានីភ្នំពេញ និងខេត្តកណ្តាល ទំហំ និងស្ថានភាពទូទៅរបស់ខណ្ឌមានជ័យមានការផ្លាស់ប្តូរ។ នៅក្នុងព្រះរាជក្រឹត្យនោះគឺបានសម្រេចកាត់បញ្ចូលឃុំចំនួន២០ ពីខេត្តកណ្តាលចូលមកក្នុង រាជធានីភ្នំពេញ ដែលនៅក្នុងនោះឃុំចំនួន៤ត្រូវបានកាត់បញ្ចូលក្នុងខណ្ឌមានជ័យ។ ឃុំទាំង៤នោះគឺកាត់ ពីស្រុកកៀនស្វាយ ដែលមាន ឃុំវាលស្បូវ ឃុំព្រែកឯង ឃុំក្បាលកោះ និងឃុំព្រែកថ្មី។[10] ការកាត់បញ្ចូលនេះបានធ្វើអោយផ្ទៃក្រឡាខណ្ឌមានជ័យបានកើនទៅដល់១១១.០៨ គីឡូម៉ែត្រការ៉េ ដោយយោងតាម ទិន្នន័យពីគេហទំព័រសាលារាជធានីភ្នំពេញ។

ប៉ុន្តែនៅចុងឆ្នាំ២០១៣ថ្មីៗនេះ ដោយមានការបង្កើតខណ្ឌថែមចំនួន៣ទៀតនាំអោយ ទំហំផ្ទៃដីរបស់ខណ្ឌមានការថយចុះវិញ។ យោងតាមអនុក្រឹត្យចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ បានសម្រេចកាត់យកសង្កាត់ចំនួន៨ ពីខណ្ឌមានជ័យដើម្បីបង្កើតខណ្ឌច្បារអំពៅ ដែលសង្កាត់ទាំង៨នោះមានដូចជា៖ សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី។[11]

បច្ចុប្បន្នខណ្ឌមានជ័យមានផ្ទៃក្រឡាទំហំ ៤៣.៧៩ គីឡូម៉ែត្រការ៉េ[12] មានប្រជាជនសរុបចំនួន ១៥៧,១១២នាក់។[13] ចំណែកឯរចនាសម្ព័ន្ធខណ្ឌវិញ ត្រូវបានបែងចែកជា ៤សង្កាត់ និងមានភូមិចំនួន ១៦។ សង្កាត់ និងភូមិទាំងនោះមានដូចជា៖

- សង្កាត់ស្ទឹងមានជ័យ

---

[9] គេហទំព័រសាលាក្រុងភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/20-communes-data/ដកស្រង់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧

[10] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង រាជធានីភ្នំពេញ និងខេត្តកណ្តាល

[11] អនុក្រឹត្យ ស្តីពី ការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

[12] គេហទំព័រសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧

[13] ស្ថិតិពីក្រសួងផែនការ

  - ភូមិឬស្សី
  - ភូមិថ្មី
  - ភូមិទ្រា
  - ភូមិមានជ័យ
  - ភូមិត្បៀត
  - ភូមិព្រែកទូល
  - ភូមិដំណាក់ធំ
- សង្កាត់បឹងទំពុន
  - ភូមិចំរើនផល
  - ភូមិសន្សំកុសលមួយ
  - ភូមិសន្សំកុសលពីរ
  - ភូមិក្បាលទំនប់
  - ភូមិត្នោតជ្រុំ
- សង្កាត់ចាក់អង្រែលើ
  - ភូមិព្រែកតាគង់
  - ភូមិព្រែកតានូវ
- សង្កាត់ចាក់អង្រែក្រោម
  - ភូមិទួលរការ
  - ភូមិព្រែកតាឡុង



ក្នុងខណ្ឌមានជ័យគឺ មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដែលបង្ករឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ តាមការស្រង់ទិន្នន័យសាលារាជធានីភ្នំពេញបានបង្ហាញឲ្យឃើញថា នៅក្នុងខណ្ឌមានជ័យអាត្រាប្រជាជនក្រីក្រ មានការថយចុះពី ១១,១១% នៅក្នុងឆ្នាំ២០០៥ មកត្រឹមតែ ០,១៣% នៅក្នុងឆ្នាំ២០១០។[14] តាមទិន្នន័យនេះបានបង្ហាញថា ក្នុងកម្លុងពេលត្រឹមតែ ៥ឆ្នាំ អាត្រាប្រជាជនក្រីក្របានថយចុះប្រមាណជា១១% ដែលបញ្ជាក់ថា នៅក្នុងខណ្ឌមានជ័យគឺមានការអភិវឌ្ឍន៍ គួរឲ្យកត់សម្គាល់។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខណ្ឌមានជ័យ គឺនៅតែត្រូវការការអភិវឌ្ឍន៍បន្ថែមទៀត។ កត្តាដែលជំរុញឲ្យមានការអភិវឌ្ឍន៍ទៀតនោះមានដូចជា៖

### ១.១.១.១. បញ្ហាកំណើនប្រជាជន

បញ្ហាកំណើនប្រជាជន គឺជាបញ្ហាមួយចំបង និងអាចចាត់ទុកជាបញ្ហាស្នូលដែលបង្កើតឲ្យមានបញ្ហាផ្សេងៗ ជាច្រើនទៀត។ ដូចដែលបានរៀបរាប់ខាងលើប្រជាជននៅក្នុងរាជធានីភ្នំពេញមានចំនួន១,៨៤៥,៨៨៨នាក់[15] ហើយមានអត្រាកំណើន១,៥៣% ជារៀងរាល់ឆ្នាំ។[16] ដោយសារតែចំនួនប្រជាជនកើនឡើងជារៀងរាល់ថ្ងៃ ទាំងកំណើនតាមរយៈធម្មជាតិ និងជាពិសេសទៅទៀតនោះគឺទាំងកំណើន

[14] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧

[15] ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញលេខ១៩ ខែឧសភា ឆ្នាំ២០១៦ ទំព័រទី៥៤

[16] គេហទំព័រ http://worldpopulationreview.com/countries/cambodia-population/# ដកស្រង់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧

តាមរយៈការធ្វើចំណូលស្រុកក្នុងគោលបំណងស្វែងរកការងារ បានធ្វើឲ្យភាពចង្អៀតកកស្ទះកើនឡើងជារៀងរាល់ថ្ងៃ។ មិនតែប៉ុណ្ណោះ តំរូវការរបស់ប្រជាជន ក៏មានការកើនឡើងជាលំដាប់ផងដែរ។ ដោយហេតុថាកំណើនប្រជាជនចេះតែកើនឡើង ដែលបណ្តាលឲ្យមានបញ្ហាថ្មីៗកើតឡើងនេះហើយ ទើបធ្វើឲ្យមានការអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហា និងបំពេញនូវតំរូវការរបស់ប្រជាពលរដ្ឋដែលកំពុងតែជួបប្រទះ។

#### ១.១.១.២. បញ្ហាចរាចរណ៍

បញ្ហាចរាចរណ៍ គឺជាបញ្ហាមួយដែលបង្ករឡើងដោយសារតែកំណើនប្រជាជន។ ដោយចំនួនប្រជាជនចេះតែកើនឡើង បណ្តាលអោយស្ថានភាពចរាចរណ៍កាន់តែមានភាពមមារញឹក និងចង្អៀតពីមួយថ្ងៃទៅមួយ។ តាមទិន្នន័យដកស្រង់មកពីគេហទំព័រសាលារាជធានីភ្នំពេញ យានយន្តសរុបនៅក្នុងរាជធានីមានចំនួន ៦៧៩,០៩១គ្រឿង។ នៅក្នុងនោះ រថយន្តធនតូចមាន ចំនួន ៩៤,៧៨២គ្រឿង រថយន្តធនធំមានចំនួន ៨២១៣គ្រឿង ទោចក្រក្រយានយន្តមានចំនួន ៥៦២,៦២៣គ្រឿង ដោយឡែកត្រីចក្រក្រយានយន្តចំនួន១,១៣៧គ្រឿង និងទោចក្រក្រយានយន្តសន្ដោងរ៉ឺម៉កមានចំនួន៣,៣៣៦គ្រឿង។[17] ដោយសារចំនួនយានយន្តដ៏ច្រើនដូចបានរៀបរាប់ខាងលើ បានជំរុញឲ្យមានការអភិវឌ្ឍន៍ប្រព័ន្ធគមនាគមន៍ឲ្យកាន់តែប្រសើរឡើង។

#### ១.១.១.៣. បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់

ភាពអសន្តិសុខ និងសំណង់អាណាធិបតេយ្យនៅក្នុងសង្គមក៏ជាកត្តាមួយដែលជំរុញឲ្យមានការអភិវឌ្ឍន៍ផងដែរ។ ដោយសារតែភាពអាណាធិបតេយ្យបានធ្វើអោយមានការគំរាមកំហែងទៅដល់ ការរស់នៅរបស់ប្រជាពលរដ្ឋ ដំណោះស្រាយលើបញ្ហានេះគឺត្រូវរិះរក និងអនុវត្តឲ្យបានឆាប់។ លើសពីនេះទៅទៀត បញ្ហាសំណង់អណាធិបតេយ្យគឺជាប្រភពបំពុលបរិស្ថានមួយធ្ងន់ធ្ងរផងដែរ។

### ១.១.២. រចនាសម្ព័ន្ធខណ្ឌមានជ័យ

អនុលោមតាមប្រកាសលេខ ៣៨៨ ប្រក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក ខណ្ឌ បានចែងថា ស្រុក ខណ្ឌនីមួយៗ ត្រូវដឹកនាំដោយអភិបាលស្រុកខណ្ឌ ០១រូបអមដោយអភិបាលរង ស្រុកខណ្ឌ ០៣រូបជាជំនួយការប៉ុន្តែដោយសារតែរាជធានីភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃបានបន្ថែមអភិបាលរងខណ្ឌមួយទៀត អោយទៅបំពេញការងារតាមសាលាខណ្ឌទាំង ៧ របស់រាជធានី

[17] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧

ភ្នំពេញ។ ដោយឡែកនៅក្នុងខណ្ឌមានជ័យគឺមាននូវអភិបាលខណ្ឌ០១រូប អមដោយអភិបាលរងចំនួន ១១រូប។[18]

អភិបាលខណ្ឌមានតួនាទី ទទួលខុសត្រូវរួមលើកិច្ចការរដ្ឋបាលដែនដី និងទទួលបន្ទុកផ្ទាល់លើកិច្ចការ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងខណ្ឌរបស់ខ្លួន។ ចំណែកឯអភិបាលខណ្ឌវិញ ០១រូប ទទួលបន្ទុកការងាររដ្ឋបាលទូទៅ ០១រូបទៀត ទទួលបន្ទុកការងារសង្គមកិច្ច និង០១រូបចុងក្រោយ ទទួលបន្ទុកការងារទាក់ទងផ្នែកសេដ្ឋកិច្ច និងទទួលភារកិច្ចផ្សេងៗទៀតតាមការប្រគល់នូវភារកិច្ចរបស់អភិបាលខណ្ឌ។

ម្យ៉ាងទៀតសាលាខណ្ឌត្រូវគ្រប់គ្រងដោយប្រធាន ០១រូប ហៅថាប្រធានមន្ទីរខណ្ឌ អមដោយអនុប្រធានមួយរូបជាជំនួយការ។ ប្រធានមន្ទីរខណ្ឌ ត្រូវបំពេញការងារក្រោមការគ្រប់គ្រង ដឹកនាំរបស់អភិបាលខណ្ឌ ក្នុងការដឹកនាំសម្របសម្រួលការងារនានាចំណុះសាលាខណ្ឌ។ អនុប្រធានមន្ទីរមានភារកិច្ចជំនួយការឲ្យប្រធានមន្ទីរខណ្ឌ អនុវត្តការងារតាមការប្រគល់ភារកិច្ចរបស់ប្រធានមន្ទីរខណ្ឌ និងជំនួសប្រធានមន្ទីរខណ្ឌពេលអវត្តមាន។

សាលាខណ្ឌមានការិយាល័យចំណុះចំនួន ០៣ គឺមានការិយាល័យរដ្ឋបាលទូទៅ ការិយាល័យសង្គមកិច្ច និងការិយាល័យសេដ្ឋកិច្ច។ ការិយាល័យចំនុះរបស់ខណ្ឌនីមួយៗ គឺមានការដឹកនាំដោយប្រធានការិយាល័យ ០១រូប និងមានអមដោយអនុប្រធានការិយាល័យ ០១រូប ទៀតជាជំនួយការ។

[18] ប្រកាសលេខ ៣៤៨ ប្រក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក ខណ្ឌ

### រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ




*ប្រភព៖ ក្រសួងមហាផ្ទៃ សៀវភៅណែនាំ "ការិយាល័យច្រកចេញចូលតែមួយ" ឆ្នាំ២០១១*

## ១.២. បច្ចុប្បន្នភាពនៃការរៀបចំខណ្ឌមានជ័យ

ដើម្បីភាពងាយស្រួលក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ ខណ្ឌបានលើកគំពោងក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើន។ ការអភិវឌ្ឍន៍ទាំងអស់នេះ គឺធ្វើឡើងដើម្បីបំរើ និងផ្គត់ផ្គង់ឲ្យបានទាន់តម្រូវការរបស់ប្រជាជនរស់នៅក្នុងខណ្ឌដែលកំពុងតែមានកំណើនជារៀងរាល់ថ្ងៃជាលំដាប់។

មកដល់ឆ្នាំ២០១៧នេះ យើងសង្កេតឃើញថានៅក្នុងខណ្ឌមានជ័យមានការអភិវឌ្ឍន៍ ជាច្រើនគួរឲ្យកត់សម្គាល់។ ការអភិវឌ្ឍន៍នេះ មិនមែនត្រឹមតែនៅក្នុងវិស័យណាមួយនោះទេ ពោលគឺមានការអភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់។ ប៉ុន្តែដោយការរៀបរាប់ពីការអភិវឌ្ឍន៍ ទាំងអស់នោះគឺមានភាពធំទូលាយពេកដូចនេះ យើងនឹងធ្វើការរៀបរាប់ផ្តោតសំខាន់តែទៅលើចំណុចដែលប្រាស្រ័យពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្មតែប៉ុណ្ណោះ។

នៅក្នុងវិស័យនគរូបនីយកម្មយើងឃើញថាមានការអភិវឌ្ឍន៍ដ៏គួរឲ្យកត់សម្គាល់ ដូចជា៖

### ១.២.១. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខណ្ឌមានជ័យ

នៅក្នុងខណ្ឌមានជ័យនេះផ្ទាល់ ការរៀបចំនៃហេដ្ឋារចនាសម្ព័ន្ធ គឺមានភាពល្អប្រសើរដែលបង្ករភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការរស់នៅ និងធ្វើដំណើរ។ បច្ចុប្បន្នភាពនៃក្នុងការរៀបចំនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខណ្ឌមានដូចជា៖

#### ១.២.១.១. ប្រព័ន្ធគមនាគមន៍

ដើម្បីកាត់បន្ថយនូវបញ្ហាកកស្ទះចរាចរណ៍ ក្រសួងសាធារណៈការ និងដឹកជញ្ជូនបានចាប់ផ្ដើមដំណើរការប្រព័ន្ធរថយន្តក្រុង ចំនួន៣ខ្សែ។ នៅក្នុងនោះ មានរថយន្តក្រុងចំនួន២ខ្សែ ធ្វើដំណើរកាត់ខណ្ឌមានជ័យ។ រថយន្តទាំង២ខ្សែនោះ គឺខ្សែទី១ និងខ្សែទី២។ ដើម្បីជំរុញឲ្យប្រជាពលរដ្ឋគាំទ្រ និងធ្វើដំណើរតាមប្រព័ន្ធរថយន្តក្រុង រាល់ការធ្វើដំណើរតាមរថយន្តក្រុងគឺមានតំលៃទាបបំផុត ពោលគឺត្រឹមតែ១៥០០រ ប៉ុណ្ណោះក្នុងការធ្វើដំណើរមួយលើក។ លើសពីនេះ សំរាប់សិស្ស និង និស្សិត ព្រះសង្ឃ ជនពិការ និងមនុស្សចាស់ គឺមិនត្រូវតំរូវឲ្យបង់ប្រាក់នោះឡើយ។

គោលបំណងនៅក្នុងការបង្កើតប្រព័ន្ធគមនាគមន៍សាធារណៈនេះ ក្នុងការចូលជួយរំដោះចរាចរណ៍ កុំឲ្យមានការកកស្ទះ ដើម្បីឲ្យប្រជាជនមានភាពងាយស្រួលក្នុងការធ្វើដំណើរ។ មួយវិញទៀត ការបង្កើតនូវប្រព័ន្ធគមនាគមន៍សាធារណៈ គឺដើម្បីជួយកាត់បន្ថយបញ្ហាបំពុលបរិស្ថានដោយសារឧស្ម័នកាបូនិច ដែលបំភាយចេញពីផ្សែងឡាន និងម៉ូតូផងដែរ។

#### ១.២.១.២. ផ្លូវថ្នល់

ចំពោះស្ថានភាពផ្លូវថ្នល់នៅក្នុងខណ្ឌមានជ័យ ក៏មានភាពល្អប្រសើរផងដែរ។ ស្ទើរគ្រប់ផ្លូវទាំងអស់នៅក្នុងខណ្ឌ ក្រាលដោយកៅស៊ូ និងស៊ីម៉ង់ត៍។ មានតែផ្លូវមួយចំនួនតូចតែប៉ុណ្ណោះដែលនៅមិនទាន់មានការអភិវឌ្ឍន៍ ពោលគឺ ផ្លូវតូចៗនៅតាមតំបន់ដែលចុះទៅជ្រៅ។

ផ្លូវថ្នល់សរុបនៅក្នុងខណ្ឌមានជ័យគឺមានប្រវែង ១៤៣,៤៩០ ម៉ែត្រ។ នៅក្នុងប្រវែងផ្លូវសរុបនេះ មានផ្លូវក្រាលកៅស៊ូAC ប្រវែង ១១,៩៨០ ម៉ែត្រ ផ្លូវក្រាលកៅស៊ូDBST ប្រវែង ១៤,៧២០ ម៉ែត្រ និងផ្លូវក្រាលបេតុងប្រវែង ២២,០៦៧ ម៉ែត្រ។[19]

មិនតែប៉ុណ្ណោះដើម្បីធានាបាននូវសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ភ្លើងបំភ្លឺផ្លូវត្រូវបានផ្លាស់ប្ដូរចេញពីភ្លើងធម្មតាទៅជាភ្លើងបំភ្លឺផ្លូវ LED ដើម្បីកាត់បន្ថយគ្រោះថ្នាក់ អសន្តិសុខ និងអំពើចោរកម្ម។ ភ្លើងសញ្ញាចរាចរណ៍ និងផ្លាកសញ្ញាចរាចរណ៍ក៏ត្រូវបានបំពាក់បន្ថែមផងដែរដើម្បីកាត់បន្ថយការកកស្ទះ

[19] ទិន្នន័យពីមន្ទីសាធារណៈការ និងដឹកជញ្ជូន

និងបញ្ចៀសនូវគ្រោះថ្នាក់ចរាចរណ៍។ លើសពីនេះទៅទៀត ភ្លើងសញ្ញាចរាចរណ៍ចាស់បានប្តូរចេញជំនួសដោយភ្លើងសញ្ញាចរាចរណ៍ថ្មីដែលបានជាជំនួយមកពី JICA។[20] គុណប្រយោជន៍នៃភ្លើងសញ្ញាចរាចរណ៍ថ្មីនេះគឺមានបន្ថែមនូវប្រព័ន្ធស្វ័យប្រវត្តិ ដែលអាចបញ្ជាបានដោយមន្ត្រីទទួលបន្ទុក ចេញពីបន្ទប់ទីស្នាក់ការកណ្តាល ដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍។

លើសពីនេះកាមេរ៉ាសុវត្ថិភាពត្រូវបានបំពាក់នៅតាមដងផ្លូវ ដើម្បីធានានូវសុវត្ថិភាពជូនទៅដល់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរ។ ការបំពាក់កាមេរ៉ានេះ គឺដើម្បីជួយកាត់បន្ថយអំពើដែលបណ្តាលឲ្យមានភាពអសន្តិសុខ នៅក្នុងសង្គម។

នៅតាមបណ្តោយផ្លូវនៅក្នុងខណ្ឌ គឺមានដាក់របាំងបែងចែកទ្រូងផ្លូវដែលជាយុទ្ធសាស្ត្រមួយដើម្បីកាត់បន្ថយការកកស្ទះនូវចរាចរណ៍ និងក៏បានជួយរួមចំណែកក្នុងការកាត់បន្ថយនូវគ្រោះថ្នាក់ចរាចរណ៍ផងដែរ។ តាមការសង្កេតមើលពីប្រសិទ្ធិភាពនៃរបាំងពុះទ្រូងផ្លូវនេះ ក៏ឃើញថាទទួលបានប្រសិទ្ធិភាពខ្ពស់ ដោយបញ្ហាកកស្ទះចរាចរណ៍ត្រូវបានកាត់បន្ថយជាលំដាប់។

ក្រៅពីការបំពាក់ភ្លើងបំភ្លឺផ្លូវ ផ្លាក់សញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងកាមេរ៉ាសុវត្ថិភាពនៅក្នុងខណ្ឌមានជ័យក៏មានការ អភិវឌ្ឍន៍ផ្នែកផ្លូវថ្នល់ថ្មីៗជាច្រើនផងដែរ។ នាពេលបច្ចុប្បន្ន មហាវិថីសម្តេចតេជោ ហ៊ុន សែន ឬផ្លូវ ៦០ម៉ែត្រ ដែលបានចាប់ផ្តើម សាងសង់កាលពី ខែមីនា ឆ្នាំ២០១១ គឺបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៧។ មហាវិថីនេះគឺមានប្រវែងសរុប ៩,១៦០ម៉ែត្រ ទទឹងប្រវែង៣០ម៉ែត្រ និងចិញ្ចើមម្ខាង១៥ម៉ែត្រ សរុបមានទទឹងប្រវែង៦០ម៉ែត្រ។ មហាវិថី សម្តេចតេជោ ហ៊ុន សែន ឬផ្លូវ ៦០ម៉ែត្រនេះ គឺជាមហាវិថីដែលធំជាងគេបំផុត ដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើនេះទៅទៀត មហាវិថី សម្តេចតេជោ ហ៊ុន សែន ឬផ្លូវ ៦០ម៉ែត្រនេះ គឺក៏ទុកសម្រាប់ជា ផ្លូវចុះយន្តហោះនាពេលមានអាសន្នដែលយន្តហោះមិនអាចធ្វើការចុះចតនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបាន។[21]

បន្ថែមលើនេះទៅទៀត ផ្លូវលំមួយកំណាត់ដែលតភ្ជាប់ ពីផ្លូវជាតិលេខ២ នៅចាក់អង្រែលើ កែងសាលារៀនចាក់អង្រែលើ ទៅនឹងមហាវិថី សម្តេចតេជោ ហ៊ុន សែន ឬផ្លូវ ៦០ម៉ែត្រ ត្រូវបានធ្វើការពង្រីកក្រាលកៅស៊ូ យ៉ាងស្អាត សម្រាប់ជួយដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ការពង្រីកផ្លូវនេះគឺបានធ្វើឡើងដោយមានការប៉ះពាល់ដល់ទីធ្លាសាលារៀន និងលំនៅស្ថានរបស់ប្រជាពលរដ្ឋមួយចំនួន ប៉ុន្តែការដកហូតកម្មសិទ្ធិនេះ គឺរដ្ឋមានសិទ្ធិដកហូត ពីព្រោះការដកយកកម្មសិទ្ធិនេះ គឺធ្វើឡើងក្នុងការ

[20] ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញ លេខ១៩ ខែឧសភា ឆ្នាំ២០១៦ ទំព័រទី១៨

[21] អនុសាសន៍ សម្តេចតេជោ ហ៊ុន សែន

បំរើនូវផលប្រយោជន៍សាធារណៈ។[22] ទោះជាយ៉ាងណាក៏ដោយ ក៏ការដកហូតនេះ គឺត្រូវបានធ្វើឡើងដោយមានការទូទាត់នូវសំណងជូនម្ចាស់កម្មសិទ្ធិ ដោយមានភាពសមស្របតាមគោលការណ៍ច្បាប់។[23]

ក្រៅពីការអភិវឌ្ឍន៍ ទៅលើគំរោងធំៗ ការអភិវឌ្ឍន៍នៅលើចំណុចតូចៗ ក៏មានច្រើនគួរឲ្យកត់សម្គាល់ផងដែរ។ ផ្លូវថ្នល់ដែលខូចខាតត្រូវបានជួសជុលកែលំអដោយការចាក់បំពេញនិងអ៊ុតឡើងវិញជៀសវាងការស្រុត។ លូនៅតាមបណ្តោយផ្លូវត្រូវបានស្តាសំរាមចេញដើម្បីកុំឲ្យលិចផ្លូវនៅខែវស្សា។ ចំពោះកន្លែងដែលមានភាពកកស្ទះខ្លាំងវិញ ខណ្ឌបានចេញវិធានការដោះស្រាយ ដូចជាការដាក់កម្លាំងសមត្ថកិច្ចចរាចរណ៍ដើម្បីជួយសម្រួលបញ្ហាចរាចរណ៍ ឬរកវិធីផ្សេងទៀតដូចជាការដាក់របាំងពុះទ្រូងផ្លូវ ឬការបិទផ្លូវកាត់ទទឹងជាដើមដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន។

ទន្ទឹមនឹងការអភិវឌ្ឍន៍ បញ្ហាមួយចំនួនក៏នៅតែបង្កឲ្យមានផលលំបាកផងដែរ។ បញ្ហាមួយដែលជាបញ្ហាចំបងចំពោះមុខ និងគំរាមកំហែងដល់អាយុជីវិតរបស់ប្រជាពលរដ្ឋផងនោះគឺការធ្វើដំណើរឆ្លងផ្លូវ របស់អ្នកដំណើរថ្មើរជើង។ ដើម្បីជាដំណោះស្រាយនឹងបញ្ហានេះ ស្ពានឆ្លងផ្លូវសម្រាប់អ្នកថ្មើរជើងគួរតែសាងសង់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតមានឡើង។ នៅរាជធានីភ្នំពេញ គឺមាននូវការសាងសង់នូវស្ពានឆ្លងផ្លូវសម្រាប់អ្នកថ្មើរជើង មួយកន្លែងហើយ គឺមានទីតាំងស្ថិតនៅលើផ្លូវជាតិលេខ៤នៅត្រង់ចំណុចមុខផ្សារជម្ពូវ័ន្ត។ ផ្អែកលើលទ្ធផលដែលទទួលបាន ស្ពាននេះគួរតែសាងសង់បន្ថែមទៀតដើម្បីភាពងាយស្រួល និងសុវត្ថិភាពដល់អ្នកដំណើរថ្មើរជើង។

#### ១.២.១.៣. ស្ពានអាកាស

ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ នៅក្នុងខណ្ឌមានជ័យស្ពានអាកាសសរុបចំនួន២ត្រូវបានស្ថាបនា និងដាក់ឲ្យប្រើប្រាស់រួចមកហើយ។ ស្ពានទាំង២នោះគឺស្ពានអាកាសក្បាលថ្នល់ និងស្ពានអាកាសស្ទឹងមានជ័យ។

ស្ពានអាកាសក្បាលថ្នល់ គឺជាស្ពានអាកាសដំបូងគេបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្ពានអាកាសនេះ បានចាប់ផ្តើមសាងសង់ឡើងនៅខែឧសភា ឆ្នាំ២០០៩ ដោយក្រុមហ៊ុន O.C.I.C ហើយត្រូវបានបញ្ចប់ការសាងសង់ និងដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១០។ ស្ពានអាកាសក្បាលថ្នល់ គឺមានបណ្តោយ ៣០៨ម៉ែត្រ លាតសន្ធឹងពីកំណាត់ផ្លូវជាតិលេខ២ ចាប់ពីអតីតមន្ទីរពេទ្យការងារ រហូតដល់អគ្គស្នងការនគបាលជាតិ មានទទឹងប្រវែង ១៤,២ម៉ែត្រ និងកំពស់ត្រង់ចំណុចកណ្តាលប្រវែង៨ម៉ែត្រ។

---

[22] មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០

[23] ច្បាប់ស្តីពី អស្សាមិករណ៍

ស្ពានអាកាសមួយខ្សែទៀតដែលមានទីតាំងស្ថិតនៅក្នុងខណ្ឌមានជ័យដែរនោះ គឺស្ពានអាកាសស្ទឹងមានជ័យ។ ស្ពានអាកាសស្ទឹងមានជ័យជាស្ពានអាកាសទី៣នៅរាជធានីភ្នំពេញ។ ដោយឃើញពីស្ថានភាពចរាចរណ៍មានការកកស្ទះចង្អៀត រាជរដ្ឋាភិបាលបានសាងសង់ស្ពានអាកាសមួយនេះឡើងដើម្បីសម្រួលដល់បញ្ហាចរាចរណ៍នៅក្នុងខណ្ឌ។ ស្ពានអាកាសស្ទឹងមានជ័យបានចាប់ផ្តើមបើកការដ្ឋានសាងសង់នៅ ខែវិច្ឆិកា ឆ្នាំ២០១២ ហើយបានបញ្ចប់ការសាងសង់ និងដាក់ឲ្យប្រើប្រាស់នៅ ខែកក្កដា ឆ្នាំ២០១៤។ ស្ពានអាកាសនេះគឺមានស្ពានសរុបចំនួន៥ ក្នុងនោះស្ពានមេចំនួន១ ស្ពានតូចចំនួន៣ និងស្ពានក្រោមដីចំនួន១។ ស្ពានមេម្ខាងទី១ មានប្រវែង៤២៩,២២ម៉ែត្រ និងទទឹង៩ម៉ែត្រ។ ស្ពានទី២ មានប្រវែង៣៧៦,៣៨ម៉ែត្រ និងទទឹង៩ម៉ែត្រ និងមានស្ពានមួយកំណាត់ទៀតដែលតភ្ជាប់ស្ពានមេនៅក្នុងភូមិសាស្ត្រខណ្ឌចំការមន ដែលមានទទឹង១៥,២០ម៉ែត្រ។ ស្ពានអាកាសតូចជាស្ពានឯកទិស មានប្រវែង១១២,៥០ម៉ែត្រ និងទទឹង៨,៥០ម៉ែត្រ បែកខ្នែងរាងព័ទ្ធកោងពីផ្លូវព្រះមុនីវ៉េត ឡើងទៅភ្ជាប់ស្ពានមេ។ រីឯស្ពានកាត់ប្រឡាយស្ទឹងមានជ័យ២ទៀត គឺស្ពានទី១ មានបណ្តោយប្រវែង១៨ម៉ែត្រ និងទទឹង១១ម៉ែត្រ និងស្ពានទី២ មានបណ្តោយប្រវែង២០ម៉ែត្រ និងទទឹងប្រវែង១២,៧០ម៉ែត្រ។ ផ្លូវអមសងខាងស្ពាន គឺមានទទឹងប្រវែង៥,៥០ម៉ែត្រ និងប្រវែងសរុប១.១៣៤ម៉ែត្រ។ ចំណែកឯផ្លូវក្រោមស្ពានវិញ គឺមានបណ្តោយ ប្រវែង៤៨៧ម៉ែត្រ និងទទឹងប្រវែង៦,៥០ម៉ែត្រ ។

ដូចដែលបានបកស្រាយខាងលើ នៅក្នុងខណ្ឌមានជ័យមានស្ពានអាកាសចំនួន២រួចមកហើយ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ស្ពានទាំង២ នោះគឺមានស្ពានអាកាសក្បាលថ្នល់ ដែលជាស្ពានអាកាសដំបូងគេ និងស្ពានអាកាសមួយទៀត គឺស្ពានអាកាស ស្ទឹងមានជ័យ ដែលជាស្ពានអាកាសទី៣ របស់រាជធានីភ្នំពេញ។ ប៉ុន្តែទោះជាមានស្ពានអាកាសទាំង២នេះក៏ដោយ ដោយសារប្រជាជនចេះតែមានកំណើនឥតឈប់ឈរ នោះការកកស្ទះចរាចរណ៍នៅតែចោទជាបញ្ហាដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋដដែល។ ដោយមើលឃើញទៅលើបញ្ហានេះ សាលារាជធានីភ្នំពេញក៏បានសម្រេចសាងសង់ស្ពានអាកាសក្បាលថ្នល់ថ្មីមួយទៀត ជំនួសឲ្យស្ពានអាកាសក្បាលថ្នល់ចាស់។ ស្ពានអាកាសក្បាលថ្នល់ថ្មី នេះបានចាប់ផ្តើមបើកការដ្ឋានសាងសង់កាលពី ខែធ្នូ ឆ្នាំ២០១៦។ ស្ពានអាកាសថ្មីនេះ គឺបានរៀបចំឡើងដោយមានលំនាំ ស្រដៀងទៅនឹង ស្ពានអាកាស ស្ទឹងមានជ័យ ពោលគឺមាននូវស្ពានពីលើបត់បែន និងមានផ្លូវក្រោមដីពីក្រោម។

យោងតាមសាលារាជធានីភ្នំពេញ ស្ពានអាកាសក្បាលថ្នល់ថ្មីនេះត្រូវបានស្ថាបនាឡើងដោយមានស្ពានអាកាសចំនួន៣ និងផ្លូវក្រោមដីចំនួន១។ ស្ពានអាកាសថ្មីនេះ គឺមានបណ្តោយប្រវែងមិនស្មើគ្នានោះទេ គឺមានប្រវែងចាប់ពី២២០ ដល់២៤០ម៉ែត្រ និងទទឹងមានប្រវែងចាប់ពី៥ ទៅ៧ម៉ែត្រ ចំណែក

ឯផ្លូវមុជក្រោមដីវិញ គឺមានបណ្ដោយប្រវែង ៣០៦ម៉ែត្រ។ តាមការបញ្ជាក់របស់សាលារាជធានីភ្នំពេញបានឲ្យដឹងថា ក្រោយពេលដែល ស្ពានអាកាសក្បាលថ្នល់ថ្មីនេះសាងសង់រួចរាល់ហើយនោះបញ្ហាកកស្ទះចរាចរណ៍នៅតំបន់ក្បាលថ្នល់នឹងត្រូវកាត់បន្ថយ ហើយស្ថានភាពចរាចរណ៍នឹងមានសភាពរលូនដូចនៅតំបន់ស្ទឹងមានជ័យដែរ។

**១.២.២. ការអភិវឌ្ឍន៍ផ្នែក សំណង់ លំនៅស្ថាន**

នៅក្នុងខណ្ឌមានជ័យសព្វថ្ងៃ យើងអាចឃើញនូវការអភិវឌ្ឍន៍ផ្នែកសំណង់ជាច្រើនដែលគួរឲ្យកត់សម្គាល់។ ប៉ុន្តែបើប្រៀបធៀបនឹងខណ្ឌដទៃ ការអភិវឌ្ឍន៍ផ្នែកសំណង់នៅមានភាពអន់ថយជាងគេនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយបើប្រៀបធៀបនឹងទិដ្ឋភាពនៃការអភិវឌ្ឍន៍ផ្នែកសំណង់នៅក្នុងខណ្ឌកាលពីមុន យើងឃើញថាវិស័យសំណង់នៅក្នុងខណ្ឌមានការរីកចំរើនខ្លាំង។ ការអភិវឌ្ឍន៍នៅក្នុងខណ្ឌមានជ័យ គឺមានការអភិវឌ្ឍន៍ទៅលើសំណង់ស្ទើរគ្រប់វិស័យទាំងសំណង់លំនៅស្ថាន និងសំណង់សម្រាប់ធ្វើអាជីវកម្ម។

សំណង់ទាំងនោះមានដូចជា៖

**១.២.២.១. រោងចក្រ**

ខណ្ឌមានជ័យ គឺជាខណ្ឌដែលមានសំណង់រោងចក្រជាច្រើនជាងគេនៅក្នុងរាជធានីភ្នំពេញ។ យើងសង្កេតឃើញថា ភាគច្រើនរោងចក្រទាំងនោះគឺជារោងចក្រផលិតសំលៀកបំពាក់។ ភាគច្រើនរោងចក្រនៅក្នុងខណ្ឌគឺជារោងចក្រចាស់ៗដែលសាងសង់យូរមកហើយ។ មិនតែប៉ុណ្ណោះថ្មីៗនេះនៅក្នុងតំបន់ចាក់អង្រែរោងចក្រមួយចំនួន ក៏ត្រូវបានបិទទ្វាឈប់ដំណើរការដែលធ្វើឲ្យចំនួនរោងចក្រមានការថយចុះផងដែរ។ យោងតាមសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដោយសារការប្រកួតប្រជែងខ្លាំងពីសំណាក់ប្រទេសវៀតណាម ប៉ង់ក្លាដេស និងមីយ៉ាន់ម៉ា និងបញ្ហាអស្ថេរភាពនយោបាយនៅកម្ពុជាបានបង្ខំឲ្យរោងចក្រកាត់ដេរប្រមាណ៧០រោងចក្រត្រូវបិទទ្វា។[24]

**១.២.២.២. លំនៅស្ថាន**

ចំពោះសំណង់លំនៅស្ថាន នៅក្នុងខណ្ឌមានជ័យវិញ គឺមានផ្ទះជាច្រើនប្រភេទ ចាប់ពីផ្ទះល្វែងទៅដល់ផ្ទះដីឡូត៍។ មិនតែប៉ុណ្ណោះ ដោយហេតុតែខណ្ឌសំបូរទៅដោយរោចក្រ នៅក្នុងតំបន់នេះគឺមានការកកើត នូវការសាងសង់បន្ទប់ជួលសម្រាប់កម្មករ កម្មការនីផងដែរ។ បន្ទប់ជួលទាំងនោះ គឺសាង

[24] គេហទំព័រ http://www.khmertimeskh.com/news/28810/garment-factories--close-amid-political-uncertainty/ ដកស្រង់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧

សង់ឡើងពីឈើ ដែក និងឥដ្ឋ។ ប៉ុន្តែគុណភាពសំណង់បន្ទប់ជួលភាគច្រើន គឺមិនបានសាងសង់ដោយគោរពតាមស្តង់ដារត្រឹមត្រូវនោះទេ។

នៅក្នុងខណ្ឌមានជ័យ រាល់សំណង់លំនៅស្ថានស្ទើរតែទាំងអស់ គឺត្រូវបានសាងសង់ឡើងដោយគោរពបានត្រឹមត្រូវទៅតាម ច្បាប់សាងសង់ដែលបានកំណត់ ដូចជាប្លង់ជួរតំរង់ និងប្លង់កំពស់ជាដើម។ យើងមិនសូវឃើញសំណង់ណាដែលសាងសង់បំពាន នឹងច្បាប់នោះទេ។ ហេតុនេះហើយទើបខណ្ឌមានសោភ័ណ្ឌភាព សណ្តាប់ល្អ និងទាក់ទាញ។

**១.២.២.៣. បុរី និងសំណង់អាគារសហកម្មសិទ្ធិ**

ក្រៅពីសំណង់លំនៅស្ថាន និងរោងចក្រ នៅក្នុងខណ្ឌមានជ័យក៏មាននូវការសាងសង់បុរីជាច្រើនផងដែរ។ ដោយយោងតាមទិន្នន័យទទួលបានពីគេហទំព័រសាលារាជធានីភ្នំពេញ បច្ចុប្បន្ននេះនៅក្នុងខណ្ឌមានជ័យគឺមានសំណង់បុរីចំនួន៨កន្លែង។[25] រាល់សំណង់បុរី ទាំង៨កន្លែងនេះគឺបានសាងសង់ឡើងដោយមានការសុំនូវលិខិតអនុញ្ញាតិសាងសង់ត្រឹមត្រូវតាមច្បាប់ដែលបានកំណត់។[26] មិនតែប៉ុណ្ណោះរាល់បុរីទាំងអស់គឺត្រូវបានគ្រប់គ្រង ដោយច្បាប់ដែលមានជាធរមាន។[27] និយាយជារួមបុរីនៅក្នុងខណ្ឌមានជ័យគឺសុទ្ធតែជាសំណង់បុរីស្របច្បាប់ ដែលធ្វើអោយខណ្ឌមានសណ្តាប់ធ្នាប់ល្អគ្មានភាពអណាធិបតេយ្យ។

ចំណែកឯសំណង់អាគារសហកម្មសិទ្ធិដែលមានលក្ខណៈធំៗវិញគឺមិនសូវមានអ្វីដែលគួរឲ្យកត់សម្គាល់នោះទេនៅក្នុងសង្កាត់ចាក់អង្រែលើ និងសង្កាត់ចាក់អង្រែក្រោម។ ដោយឡែកនៅក្នុងសង្កាត់ស្ទឹងមានជ័យ និងសង្កាត់បឹងទំពុងវិញ សំណង់អាគារសហកម្មសិទ្ធិគឺមានភាពរីកចំរើនគួរអោយកត់សំគាល់ ។ ជាពិសេសនៅក្នុងសង្កាត់ស្ទឹងមានជ័យយើងឃើញមាន អាគារសហកម្មសិទ្ធិមួយចំនួនបានសាងសង់រួចរាល់ និងមួយចំនួនទៀតកំពុងតែស្ថិតនៅក្នុងការសាងសង់។

**១.២.២.៤. សំណង់អាគារផ្សេងៗ**

ក្រៅពីប្រភេទសំណង់ដែលបានរៀបរាប់ ខណ្ឌមានជ័យក៏មាននូវប្រភេទសំណង់ផ្សេងៗទៀតជាច្រើន។ សំណង់ទាំងនោះមានដូចជា សាលារៀន មន្ទីរពេទ្យ ដែលបំរើឲ្យទាំងវិស័យឯកជន និងរដ្ឋ។ ជាក់ស្តែងសាលាឯកជនល្បីៗដូចជា ISPP AIS BELTI សុវណ្ណភូមិ ជាដើមបានបង្កើតនិងចាប់ផ្តើមដំណើរការ។ ចំពោះផ្សារក៏មានការសាងសង់បន្ថែមផងដែរទាំងផ្សារប្រភេទប្រពៃណី និងផ្សារទំនើប

---

[25] គេហទំព័រនៃសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ ដកស្រង់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧

[26] អនុក្រឹត្យស្តីពីលិខិត អនុញ្ញាតិការសាងសង់ លេខ៨៦អនក្រ/បក ថ្ងៃទី១៨ ធ្នូ ១៩៩៧

[27] អនុក្រឹត្យស្តីពីការគ្រប់គ្រងបុរី

ដូចជាផ្សារស្ទឹងមានជ័យថ្មីជាដើម។ វត្តអារាម និងសំណង់បំរើឲ្យវិស័យផ្សេងៗដ៏ទៃទៀត ក៏មានជាច្រើនគួរឲ្យកត់សំគាល់ផងដែរ។ ដែលទាំងនេះហើយជាសញ្ញាណមួយបញ្ជាក់ថាខណ្ឌកំពុងតែមានការអភិវឌ្ឍន៍ ដែលទៅថ្ងៃមុខខណ្ឌនឹងមានការអភិវឌ្ឍន៍ខ្លាំងជាងនេះទៀត។

# ជំពូកទី២

# បរិស្ថានក្នុងខណ្ឌមានជ័យ

# ជំពូកទី២៖ បរិស្ថានក្នុង ខ័ណ្ឌមានជ័យ

យើងដឹងហើយថា ទន្ទឹមនឹងការអភិវឌ្ឍន៍ ច្បាស់ណាស់បញ្ហាផ្សេងៗទៀតនឹងកើតមានជាមួយគ្នាដែរ។ ហើយក្នុងចំណោមបញ្ហាទាំងអស់នោះ បរិស្ថានគឺទទួលការគំរាមកំហែង និងប៉ះពាល់ខ្លាំងជាងគេ។ ជាក់ស្តែងនៅក្នុងការអភិវឌ្ឍន៍ គឺជៀសមិនផុតនោះទេពីការបំពុល។ ដូចនេះឲ្យតែមានការអភិវឌ្ឍន៍ គឺត្រូវតែមានការបំពុលនេះហើយទើបយើងត្រូវរកនូវវិធីយ៉ាងណាដើម្បីដោះស្រាយបញ្ហាបំពុលទាំងនេះ។

## ២.១. ហេតុបង្កនាំឲ្យមានការបំពុលបរិស្ថាន

សព្វថ្ងៃនេះ ដោយសារតែប្រទេសមានការអភិវឌ្ឍន៍ ការបំពុលមានការកើនឡើងខ្លាំង បើប្រៀបធៀបទៅនឹងកាលពីអតីតកាល។ ការបំពុលទាំងនោះគឺមានគ្រប់ទម្រង់ទាំងអស់ដែលបង្កឡើងពីមូលហេតុផ្សេងៗគ្នា។ ដូចនេះដើម្បីស្វែងរកដំណោះស្រាយទាក់ទងទៅនឹងការបំពុលទាំងនោះយើងគួរដឹងពីមូលហេតុនៃការបំពុលជាមុនសិន។

ប៉ុន្តែដើម្បីឲ្យកាន់តែមានភាពងាយស្រួលក្នុងការយល់ឲ្យបានស៊ីជម្រៅ យើងគួរយល់ពាក្យគន្លឹះសំខាន់ៗ ជាមុនសិន។

- ការបំពុល ៖ គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឲ្យពុល។[28]
- សំណល់រឹង ៖ គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬកំទេចកំទី ដែលលែងត្រូវបានប្រើប្រាស់ ហើយត្រូវបានគេបោះចោល មានបំណងបោះចោល ឬត្រូវតែបោះចោល។[29]
- សំណល់រាវ ៖ គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី។[30]

### ២.១.១. ហេតុបង្កនាំឲ្យមានការបំពុល ទឹក ដី និងខ្យល់

ទឹក ដី និងខ្យល់ គឺជាធនធានដែលមានស្រាប់នៅក្នុងធម្មជាតិ។ ធនធានទាំង ៣ នេះគឺសំខាន់ណាស់ដើម្បីទ្រទ្រង់ជីវិតរស់នៅរបស់មនុស្ស។ ប៉ុន្តែសព្វថ្ងៃ ធនធានធម្មជាតិទាំងនោះកំពុងតែរងការបំពុលពីសំណាក់កត្តាផ្សេងៗ មូលហេតុទាំងនោះមានដូចជា៖

---

[28] វចនានុក្រម សម្តេចសង្ឃ ជួន ណាត

[29] មាត្រា៣នៃ អនុក្រឹត្យស្តីពីការគ្រប់គ្រង សំណល់រឹង លេខ៣៦អនក្រ/បក ចុះថ្ងៃទី ២៧ មេសា ១៩៩៩

[30] មាត្រា៣នៃ អនុក្រឹត្យស្តីពីការត្រួតពិនិត្យ ការបំពុលទឹក លេខ២៧អនក្រ/បក ចុះថ្ងៃទី ០៦ មេសា ១៩៩៩

### ២.១.១.១. ហេតុបង្កឲ្យមានការបំពុលទឹក

ភាវៈរស់គ្រប់រូបដែលមានជីវិតរស់នៅទាំងអស់គឺសុទ្ធតែត្រូវការទឹក។ ប៉ុន្តែសព្វថ្ងៃ ទឹកកំពុងតែរងការបំពុលដែលការបំពុលទាំងនោះគឺបង្កឡើងពីមូលហេតុដូចជា៖

#### ក. ហេតុបង្ក

- រោងចក្រ

រោងចក្រគឺជាប្រភពមួយដ៏ចំបងដែលនាំឲ្យមានការបំពុលទឹក។ នៅក្នុងសង្វាក់ផលិតកម្មរបស់រោងចក្រ គឺមានការបញ្ចេញចោលកាកសំណល់គ្រោះថ្នាក់ទៅក្នុងបរិស្ថាន។ កាកសំណល់គ្រោះថ្នាក់ដែលចេញពីរោងចក្រទាំងនោះ គឺត្រូវឆ្លងកាត់ធ្វើប្រព្រឹត្តកម្មសិនទើបអាចបន្សាបសារជាតិពុល និងមិនបង្ករគ្រោះថ្នាក់នៅពេលបញ្ចេញចោល។ ប៉ុន្តែកាកសំណល់ភាគច្រើនគឺត្រូវបញ្ចេញចោល ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មនោះទេ។ នៅពេលដែលកាកសំណល់រោងចក្រទាំងនោះ បង្ហូរចូលទៅក្នុងបឹង ឬទន្លេ នឹងធ្វើឲ្យមានការបំពុលដល់ប្រភពទឹកដែលបានបង្ហូរចូលនោះ។[31]

- ការបង្ហូរទឹកកខ្វក់

មិនមែនមានតែរោងចក្រនោះទេដែលជាប្រភពនៅក្នុងការបំពុលទឹក ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងក៏រួមចំណែកក្នុងការបំពុលផងដែរ។ ទឹកកខ្វក់ដែលកើតឡើងពីការប្រើប្រាស់របស់យើង ដូចជាទឹកកខ្វក់ពីបន្ទប់ទឹក ពីផ្ទះបាយ ក៏ជាប្រភពបង្ករឲ្យមានការបំពុលទឹកដែរ នៅពេលទឹកកខ្វក់ទាំងនោះត្រូវបានបង្ហូរចូលក្នុងប្រភពទឹក ដូចជាបឹង និងទន្លេ។ ការបំពុលដោយការបង្ហូរទឹកកខ្វក់ចូលក្នុងទន្លេគឺមានផលប៉ះពាល់ខ្លាំងដល់ប្រភពទឹកជាពិសេសនៅរដូវប្រាំង ព្រោះនៅរដូវប្រាំងទឹកទន្លេរាក់ដូចនេះនៅពេលដែលមានការបង្ហូរទឹកកខ្វក់ចូល នោះបរិមាណទឹកទន្លេមិនគ្រប់គ្រាន់នៅក្នុងការបន្សាបទឹកកខ្វក់ ដែលបានហូរចូលហេតុដូចនេះបណ្តាលឲ្យមានការបំពុលទឹកខ្លាំង។[32]

- សំរាម

មតិភាគច្រើនគិតថា សំរាមគឺមិនសូវមានការប៉ះពាល់ដល់ការបំពុលទឹកប៉ុន្មានទេ ប៉ុន្តែផ្ទុយទៅវិញ សំរាមគឺមានការប៉ះពាល់ខ្លាំងណាស់ដល់ប្រភពទឹក។ នៅពេលដែលសំរាមទាំងនោះធ្លាក់ចូល ឬទឹកពីសំរាមហូរចូលក្នុងទន្លេ ឬបឹង គឺបង្ករឲ្យមានការកើតឡើងនូវបាក់តេរី និងសារជាតិពុលដែល

---

[31] គេហទំព័រ http://www.waterwise.co.za/ ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

[32] គេហទំព័រ http://www.wepa-db.net/ ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

បណ្តាលឲ្យមានការបំពុលទឹកកើតឡើង។[33] ជាក់ស្តែង យើងអាចឃើញការបំពុលទឹកដោយសំរាមនេះនៅតាមបណ្តោយទន្លេបាសាក់ក្រោមស្ពានច្បារអំពៅ។

**ខ. ផលប៉ះពាល់**

យោងតាមការវិភាគរបស់អ្នកឯកទេសបានឲ្យដឹងថា ទឹកដែលទទួលការបំពុលគឺបណ្តាលឲ្យមានផលប៉ះពាល់ខ្លាំងណាស់ដល់សុខភាពមនុស្ស។ នៅពេលដែលមនុស្សទទួលទាន ឬប្រើប្រាស់ទឹកដែលទទួលរងការបំពុលនោះនឹងបង្ករឲ្យមានជំងឺផ្សេងៗ ដូចជារាគ មួរ និងជំងឺសើរស្បែក ជាដើម។ លើសពីនេះទៅទៀតផលប៉ះពាល់របស់ការបំពុលទឹកក៏មានលក្ខណៈប្រយោលផងដែរដល់សុខភាពមនុស្ស នៅពេលដែលមនុស្សទទួលទានត្រីដែលបាននេសាទមកពីទឹកដែលត្រូវបានបំពុល ដោយសារតែសារធាតុពុលដែលនៅក្នុងទឹកនោះគឺបានជ្រាបចូលទៅក្នុងសាច់របស់ត្រីដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាពនៅពេលបរិភោគ។

មិនតែប៉ុណ្ណោះ ទឹកដែលទទួលរងការបំពុលក៏មានផលប៉ះពាល់ដល់ជីវៈចំរុះដែលរស់នៅក្នុងទឹកផងដែរ។ សារជាតិពុលនៅក្នុងទឹក បណ្តាលឲ្យរុក្ខជាតិ និងសត្វនៅក្នុងទឹកស្លាប់ក៏ជាហេតុដែលបណ្តាលឲ្យបាត់នូវលំនឹងប្រព័ន្ធជីវៈចំរុះក្នុងទឹក។[34]

**២.១.១.២. ហេតុបង្កឲ្យមានការបំពុលដី**

កត្តាដែលនាំឲ្យមានការបំពុលដីគឺបណ្តាលមកពីកត្តាច្រើនយ៉ាង។ ប៉ុន្តែគួរតែបញ្ជាក់ផងដែរថា បញ្ហាបំពុលដីនេះគឺមិនសូវមានការគំរាមកំហែងដល់ប្រជាជនរស់នៅក្នុងទីក្រុងនោះនៅឡើយទេ លើកលែងប្រជាជនដែលប្រកបរបរកសិកម្មនៅតាមជាយក្រុង។

**ក. ហេតុបង្ក**

- សំរាម

សំរាមគឺជាមូលហេតុមួយដែលបណ្តាលឲ្យមានការបំពុលដី។ ពេលដែលសំរាមត្រូវបានគេទុកចោលនៅកន្លែងណាមួយ ដូចជានៅទីលានចាក់សំរាមជាដើម គឺបណ្តាលឲ្យដីនៅតំបន់នោះបាត់បង់នូវជីវជាតិ។ ហេតុបង្ករឲ្យដីបាត់ជីវជាតិនេះដោយសារតែពេលដែលសំរាមត្រូវបានទុកចោលរយៈពេលយូរ វាបញ្ចេញនូវសារជាតិពុលក្នុងទំរង់ជាសារធាតុរាវចេញមកចូលក្នុងដីដែលបណ្តាលឲ្យដីនៅតំបន់នោះមានការខូចខាត។

- ការប្រើប្រាស់សារជាតិគីមីពុល

---

[33] គេហទំព័រ https://urbanvoicecambodia.net/ ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

[34] គេហទំព័រ http://www.gogreenacademy.com/ ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

នៅពេលដែលយើងប្រើប្រាស់នូវសារធាតុគីមីមិនត្រឹមត្រូវលើដំណាំកសិផលសារជាតិពុលទាំងនោះនឹងជ្រៀបចូលក្នុងដីដែលធ្វើឲ្យមានផលប៉ះពាល់ទៅលើគុណភាពដី។ ប៉ុន្តែដោយឡែកវិញ បើការប្រើប្រាស់សារធាតុគីមីតាមការនែនាំត្រឹមត្រូវនេះនឹងមិនបណ្តាលឲ្យមានការប៉ះពាល់ដល់គុណភាពដីនោះទេ។[35]

**ខ. ផលប៉ះពាល់**

ដូចដែលបានរៀបរាប់នៅខាងលើបញ្ហាការបំពុលដីនេះគឺមិនសូវមានការប៉ះពាល់ដល់ប្រជាជនរស់នៅក្នុងទីក្រុងប៉ុន្មាននោះទេ  ពោលគឺវាមានផលប៉ះពាល់ខ្លាំងដល់ប្រជាជនដែលប្រកបរបរកសិកម្មរស់នៅតាមជាយក្រុងតែប៉ុណ្ណោះ។ នៅពេលដែលដីត្រូវបានបំពុលនោះដីនឹងបាត់បង់ជីវជាតិ ឬដីក្លាយជាហិរបណ្តាលឲ្យប៉ះពាល់ទិន្នផលកសិកម្មមានការថយចុះ។[36]

**២.១.១.៣. ហេតុបង្កឲ្យមានការបំពុលខ្យល់**

តាមរយៈឯកសារសិក្សាអំពីកំរិតគុណភាពខ្យល់នៅរាជធានីភ្នំពេញរបស់អ្នកស្រាវជ្រាវជនជាតិជប៉ុន  បានបង្ហាញថាគុណភាពខ្យល់សព្វថ្ងៃគឺបានទទួលរងការបំពុលខ្លាំង។  តាមការប្រៀបធៀបកំរិតការបំពុលខ្យល់នៅក្នុងរាជធានីភ្នំពេញទៅនឹងទីក្រុងកាណាស្សាវ៉ា នៃប្រទេសជប៉ុន និងទីក្រុងបាំងកកនៃប្រទេសថៃ បានបង្ហាញអោយថាខ្យល់នៅរាជធានីភ្នំពេញទទួលរងការបំពុលខ្លាំងជាងនៅទីក្រុងកាណាស្សាវ៉ា  នៃប្រទេសជប៉ុនរហូតទៅដល់៤០ដង  និងទីក្រុងបាំងកកប្រទេសថៃរហូតទៅដល់៦ដង។[37]  នៅក្នុងសន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន (EPI) សម្រាប់គុណភាពខ្យល់ ឆ្នាំ២០១៦បានបង្ហាញថាកម្ពុជាស្ថិតក្នុងលំដាប់ទី១៤៨  ក្នុងចំណោម១៨០ប្រទេស។[38] មូលហេតុដែលបណ្តាលឲ្យរាជធានីភ្នំពេញមានការបំពុលខ្យល់ខ្លាំងបែបនេះដោយសារតែៈ

**ក. ហេតុបង្ក**

---

35 គេហទំព័រ http://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php ដកស្រង់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

36 គេហទំព័រ http://www.conserve-energy-future.com/causes-effects-solutions-of-land-pollution.php ដកស្រង់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧

37 ការបំពុលខ្យល់នៅរាជធានីភ្នំពេញ, ម៉ាសាមី ហ្សូរ៉ូធី

38 គេហទំព័រ http://epi.yale.edu/country/cambodia ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

- ការបំពុលពីរោងចក្រ

ប្រទេសកម្ពុជាគឺមិនមានភាពរីកចំរើនខ្លាំងលើវិស័យឧស្សាហកម្មនោះទេ ដោយមានរោងចក្រឧស្សាហកម្មភាគច្រើន គឺជារោងចក្រផលិតក្រណាត់ និងសំលៀកបំពាក់។ ប៉ុន្តែការបំពុលភាគច្រើនមានប្រភពមកពីរោងចក្រដោយមកពីរោងចក្រភាគច្រើន ប្រើប្រាស់នូវគ្រឿងចក្រចាស់ៗដែលបញ្ចេញសារធាតុពុលច្រើន។ មិនតែប៉ុណ្ណោះរោងចក្រនៅកម្ពុជាភាគច្រើនគឺមានទីតាំងនៅក្នុងរាជធានីដែលជាហេតុមួយដែលបង្ករឲ្យការបំពុលខ្យល់នៅក្នុងរាជធានីភ្នំពេញ មានកំរិតខ្ពស់ជាងនៅតំបន់ដទៃទៀតនៅប្រទេសកម្ពុជា។ ជាក់ស្តែងនៅខណ្ឌមានជ័យ និងខណ្ឌសែនសុខជាដើមគឺសំបូរដោយរោងចក្រផលិតសំលៀកបំពាក់ និងស្បែកជើង។[39]

- ការបំពុលពីយានយន្ត

មូលហេតុមួយទៀតដោយសារតែចំនួនប្រជាជននៅក្នុងទីក្រុងមានចំនួនច្រើន ដូចនេះតំរូវការនៃយាន្តយន្តនៅក្នុងការធ្វើដំណើរក៏ច្រើនដែលជាហេតុនាំឲ្យ កំរិតឧស្ម័នពុលដែលត្រូវបានបញ្ចេញទៅក្នុងបរិយាកាសខ្ពស់។ លើសពីនេះទៅទៀត នៅក្នុងប្រទេស ប្រជាជនភាគច្រើនប្រើប្រាស់នូវយានយន្តចាស់ៗប្រើប្រាស់រួច ដែលនាំចូលពីប្រទេសដទៃដែលវាបញ្ចេញផ្សែងពុលទៅក្នុងបរិស្ថាន ច្រើនជាងយាន្តយន្តថ្មី។

កត្តាមួយទៀតដែរ ដោយសារតែចំនួនយាន្តយន្តនៅក្នុងរាជធានីមានកំណើនខ្លាំង ធ្វើឲ្យមានការស្ទះចរាចរណ៍ច្រើន។ នៅពេលដែលមានការស្ទះចរាចរណ៍រយៈពេលដែលបញ្ចេញផ្សែងពុលក៏យូរជាងមុនផងដែរ។ ម្យ៉ាងទៀត គុណភាពសាំងក៏ជាមូលហេតុមួយក្នុងការបំពុលខ្យល់ដែរ។ នៅពេលដែលមានការប្រើប្រាស់សាំងដែលមានគុណភាពអន់ ផ្សែងដែលបញ្ចេញមកក៏មានកំរិតជាតិពុលខ្លាំងចូលក្នុងខ្យល់។[40]

- ការបំពុលដោយធូលីដី

---

[39] មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្តាន់ វិន ទំព័រ១៣៨

[40] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment ទំព័រ១

ធូលីក៏ជាមូលហេតុដែលបណ្តាលឲ្យមានការបំពុលខ្យល់ដែរ។ កត្តាចំបងនៅក្នុងការធ្វើឲ្យមានធូលីនោះ មកពីការដឹកជញ្ជូនសម្ភារៈសំណង់ដោយមិនមានការគ្របឲ្យត្រឹមត្រូវ។ មួយវិញទៀត ការទុកដាក់សម្ភារៈសំណង់ទាំងនោះមិនបានល្អ ដូចជាការដាក់សម្ភារៈនៅតាមចិញ្ចើមផ្លូវ បានធ្វើឲ្យធូលីទាំងនោះហើរចូលក្នុងបរិយាកាសដែលយើងអាចឃើញជាក់ស្តែងនៅតាមការដ្ឋានសំណង់នៅក្នុងរាជធានីភ្នំពេញ។ មិនតែប៉ុណ្ណោះ ធូលីដែលជាប់តាមកង់យានយន្តក៏ជាមូលហេតុមួយបណ្តាលឲ្យមានធូលីដីផងដែរ។[41]

- ការបំពុលដោយចំហេះអូស ធ្យូង

ការប្រើប្រាស់អូសធ្យូងជាប្រភពថាមពលចំអិនអាហារ គឺជាទំនៀមទំលាប់មួយរបស់ប្រជាជនខ្មែរ។ ទោះជាអ្នករស់នៅក្នុងរាជធានីក៏ដោយ ក៏ការប្រើប្រាស់អូស ធ្យូង នៅតែជាវិធីពេញនិយមក្នុងការចំអិនអាហារ។[42] ប៉ុន្តែការប្រើប្រាស់អូសនិងធ្យូងនេះ គឺមានផលប៉ះពាល់ខ្លាំងណាស់ដល់បរិស្ថាន។ នៅក្នុងចំហេះអូស ធ្យូង បានបង្កើតនូវឧស្ម័នកាបូនិច និងឧស្ម័នកាបូណាត រួមទាំងឧស្ម័នពុលដ៏ច្រើនទៀតចូលក្នុងបរិស្ថាន។ ឧស្ម័នពុលទាំងនោះគឺប៉ះពាល់ខ្លាំងណាស់ដល់គុណភាពខ្យល់។[43]

### ខ. ផលប៉ះពាល់

ខ្យល់គឺជាធាតុសំខាន់មួយនៅក្នុងការទ្រទ្រង់ជីវិតមនុស្ស។ ដូចនេះបើខ្យល់ត្រូវបានបំពុលនោះសុខភាពមនុស្សក៏ទទួលរងនូវការប៉ះពាល់ផងដែរ។ ការរស់នៅក្នុងបរិស្ថានដែលខ្យល់ត្រូវបានបំពុលគឺនឹងធ្វើឲ្យសុខភាព មនុស្សអន់ថយ ដោយប្រឈមនឹងជំងឺជាច្រើនដូចជា ជំងឺបេះដូង ជំងឺផ្លូវដង្ហើម ជំងឺសើរស្បែក ជំងឺមហារីកជាដើម។[44]

ភ្លៀងអាស៊ីតក៏ជាលទ្ធផលមួយបណ្តាលមកពីការបំពុលខ្យល់ផងដែរ។ ឧស្ម័នពុលដែលបានបញ្ចេញទៅក្នុងបិយាកាសបានធ្វើឲ្យទឹកភ្លៀងមានជាតិអាស៊ីត។ នៅពេលដែលមនុស្សប្រើប្រាស់ទឹកភ្លៀងផ្ទុកជាតិអាស៊ីតនេះនឹងធ្វើឲ្យកើតនូវជំងឺសើរស្បែក និងជំងឺជាច្រើនទៀត។ មិនតែប៉ុណ្ណោះ ភ្លៀង

[41] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment ទំព័រ២

[42] National Reporting Guidelines for CDS-14/15 Thematic Areas, Ministry of Environment ទំព័រ២

[43] មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្ពាន់ វិន ទំព័រ១៣៩

[44] គេហទំព័រ http://www.conserve-energy-future.com/causes-effects-solutions-of-air-pollution.php ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

អាស៊ីតក៏បណ្ដាលឲ្យមានផលប៉ះពាល់ដល់សំណង់អាគារផងដែរ។ សារជាតិអាស៊ីតដែលនៅក្នុងភ្លៀងនោះគឺធ្វើឲ្យសំណង់អាគារឆាប់ស្លេកពណ៌ និងធ្វើឲ្យដែកងាយនឹងច្រែសផងដែរ។[45]

## ២.១.២. ហេតុបង្កនាំឲ្យមានការបំពុលដោយ សំណល់រឹង រាវ និងសំលេង

### ២.១.២.១. ហេតុបង្កឲ្យមានការបំពុលដោយសំណល់រឹង

កំណើនប្រជាជន កំណើនកម្រិតជីវភាពរស់នៅ និងកំណើននគរូបនីយកម្ម បានធ្វើឲ្យបរិមាណសំណល់រឹងកាន់តែច្រើន។ ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវ និងបណ្ដាលអោយមាននូវផលប៉ះពាល់ខ្លាំងទៅដល់សោភ័ណភាពនៃរាជធានី សុខភាព និងផ្លូវចិត្តរបស់មនុស្ស និងបរិស្ថាន។

#### ក. ហេតុបង្ក

- សំណល់រឹងតាមគេហដ្ឋាន

តាមទិន្នន័យស្រាវជ្រាវពីសំណល់រឹងនៅរាជធានីភ្នំពេញរបស់លោក Sarin បានឲ្យឃើញថានៅក្នុងចំណោមសំណល់រឹងទាំងអស់ ៦៦,៦% មានប្រភពពីតាមលំនៅស្ថាន។[46] ម្យ៉ាងទៀត តាមការសិក្សាស្រាវជ្រាវរបស់ JICA បានឲ្យដឹងថា មនុស្សម្នាក់ក្នុងមួយថ្ងៃបង្កើតសំណល់រឹងជាមធ្យម ៤៨៧ ក្រាម។[47] តាមរយៈទិន្នន័យនេះយើងអាចសន្និដ្ឋានបានថា សំណល់រឹងនៅរាជធានីភ្នំពេញមួយចំនួនធំគឺត្រូវបានបង្កើតឡើងដោយមនុស្សក្នុងជីវភាពប្រចាំថ្ងៃនេះតែម្ដង។

- សំណល់រឹងពីទីផ្សារ សណ្ឋាគារ និងភោជនីយដ្ឋាន

យោងតាមទិន្នន័យរបស់លោក Sarin ដដែលបានបង្ហាញថា សំណល់ដែលបានមកពីផ្សារភោជនីយដ្ឋាន និងសណ្ឋាគារមានចំនួនសរុប ២៧,២% នៃសំណល់រឹងសរុប ដែលនេះជាចំនួនច្រើនទីពីរបន្ទាប់ពី សំណល់រឹងដែលបានមកពីលំនៅស្ថាន។

[45] មូលដ្ឋានគ្រឹះនៃបរិស្ថាន ដោយលោក ស្ពាន់ វិន ទំព័រ១៩៦ និង១៩៧

[46] Urban Solid Waste Disposal: A case study of the city of Phnom Penh, Sarin 1998

[47] The study of Solid Waste Management in the Municipality of Phnom Penh, JICA 2004

- សំណល់រឹងពីរោងចក្រឧស្សាហកម្ម ពាណិជ្ជកម្ម និងមន្ទីរពេទ្យ

ប្រភពចុងក្រោយនៃការបំពុលដោយសំណល់រឹងគឺមកពីរោងចក្រឧស្សាហកម្ម ពាណិជ្ជកម្ម និងមន្ទីរពេទ្យ។ សំណល់រឹងដែលបង្កើតចេញពីនេះ គឺមានបរិមាណ ៦,២% នៃសំណល់រឹងសរុប ដែលជាចំនួនដែលតិចជាងប្រភពផ្សេងៗខាងលើ។

**ខ. ផលប៉ះពាល់**

ចំពោះផលប៉ះពាល់របស់សំណល់រឹងវិញគឺមានកំរិតនៃការប៉ះពាល់ផ្សេងៗគ្នា។ ចំពោះសំណល់ដែលបានមកពីគេហដ្ឋាន សណ្ឋាគារ និងភោជនីយដ្ឋាន គឺជាប្រភេទសំណល់មិនគ្រោះថ្នាក់។ សំណល់ប្រភេទនេះគ្រាន់តែបង្ករឲ្យកកស្ទះលូ បាត់បង់សោភ័ណភាព និងមានក្លិនមិនល្អបើទុកដាក់មិនបានត្រឹមត្រូវតែប៉ុណ្ណោះ។ ដោយឡែក ចំពោះសំណល់រឹងដែលបានមកពីរោងចក្រឧស្សាហកម្ម ពាណិជ្ជកម្ម និងមន្ទីរពេទ្យវិញ គឺមានផលប៉ះពាល់យ៉ាងខ្លាំងណាស់ដល់សុខភាពមនុស្ស និងបរិស្ថាន។ សារធាតុពុលដែលនៅក្នុងសំណល់ទាំងនោះអាចបណ្តាលឲ្យមនុស្សមានជំងឺដូចជារមាស់ ក្អួត ឬ ខ្វាក់ភ្នែកបណ្តោះអាសន្ន វាក៏អាចបណ្តាលឲ្យមានការបាត់បង់ជីវិតផងដែរបើក្នុងស្ថានភាពធ្ងន់ធ្ងរ។ លើសពីនេះទៅទៀត សំណល់រឹងនេះហើយដែលជាដើមហេតុដែលបណ្តាលឲ្យមាននូវបញ្ហាបំពុលបរិស្ថានផ្សេងទៀតដូចជាការបំពុលខ្យល់ ការបំពុលទឹក និងការបំពុលដីជាដើម។[48]

## ២.១.២.២. ហេតុបង្ករឲ្យមានការបំពុលដោយសំណល់រាវ

**ក. ហេតុបង្ក**

- រោងចក្រកាត់ដេរ

សំណល់រាវដែលផលិតចេញពីរោងចក្រ គឺជាសំណល់ដែលបង្កើតមកតាមរយៈដំណើរសង្វាក់ផលិតកម្មដែលរួមមានដូចជាសំណល់រាវពីការបោកសំអាតក្រណាត់ និងទឹកថ្នាំប្រើប្រាស់ដើម្បីជួយធ្វើឲ្យគុណភាពក្រណាត់ល្អ ទន់ និងរឹងមាំ។ បន្ថែមលើនេះទៀតរោងចក្រខ្លះក៏មានប្រើប្រាស់សារធាតុគីមីដើម្បីជ្រលក់ពណ៌ដែរ។ សំណល់រាវដែលប្រើប្រាស់រួច ត្រូវបានបង្ហូរចូលក្នុងលូដើម្បីបញ្ចេញចោល។[49]

---

[48] មូលដ្ឋានគ្រឹះនៃបរិស្ថាន លោក ស្តាន់ វិន ទំព័រ១១៨ ដល់១២០

[49] គេហទំព័រ http://www.open.edu/openlearncreate/mod/oucontent/view.php?id=80454&printable=1 ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

- សំណល់រាវពីលំនៅស្ថាន និងកន្លែងអាជីវកម្ម

សំណល់រាវដែលបញ្ចេញពីលំនៅស្ថាន គឺជាប្រភេទសំណល់រាវដែលបានមកពីសកម្មភាពរស់នៅប្រចាំថ្ងៃ ហើយត្រូវបែងចែកជាពីរប្រភេទ គឺសំណល់រាវពណ៌ខ្មៅ និងសំណល់រាវពណ៌ប្រផេះ។ សំណល់រាវពណ៌ខ្មៅជាសំណល់ដែលបានមកពីការបង្ហូរបញ្ចូលគ្នារវាងលាមក និងទឹកមូត្រ។ ចំណែកឯសំណល់រាវពណ៌ប្រផេះជាសំណល់ដែលបង្កើតមកពីទឹកដែលយើងប្រើប្រាស់ដូចជា សំណល់ពីការងូតទឹក បោកខោអាវ លាងបន្លែ។ល។ សំណល់រាវទាំងពីរប្រភេទនេះត្រូវបានបង្ហូរចូលក្នុងលូរួមមួយដើម្បីបញ្ចេញចោល។ ចំណែកឯសំណល់រាវចេញពីកន្លែងអាជីវកម្មដូចជា អាគារពាណិជ្ជកម្ម ផ្សារ ភោជនីយដ្ឋាន និងហាងកាហ្វេរិញក៏ស្រដៀងនឹងសំណល់រាវពីលំនៅស្ថានដែរ គ្រាន់តែសំណល់រាវពីកន្លែងទាំងនេះគឺសំបូរសារជាតិប្រេងខ្លាញ់ជាងតែប៉ុណ្ណោះ។[50]

### ខ. ផលប៉ះពាល់

ការដែលគ្រប់គ្រងសំណល់រាវមិនបានល្អនឹងបង្ករឲ្យមានការបំពុលជាច្រើនកើតឡើងដូចជាការបំពុលទឹក ការបំពុលដី និងការបំពុលទឹកនៅក្នុងដី។ នៅពេលសំណល់រាវបានបង្ហូរចូលក្នុងទឹកនិងដីនឹងធ្វើឲ្យទឹកពុល និងដីអស់ជីវជាតិ។ មិនតែប៉ុណ្ណោះ នៅពេលដែលសំណល់រាវជ្រាបចូលក្នុងដី វានឹងអាចប៉ះពាល់ដល់គុណភាពទឹកដែលនៅក្នុងដីទៀតផង។ នៅពេលដែលមនុស្សជីកអណ្តូងដើម្បីយកទឹកបំពុលនោះមកប្រើប្រាស់នឹងធ្វើឲ្យប៉ះពាល់សុខភាពដូចការប្រើប្រាស់ទឹកដែលត្រូវបំពុលដែរ។[51]

### ២.១.២.៣. ហេតុបង្ករឲ្យមានការបំពុលដោយសំលេង

មនុស្សភាគច្រើនមិនគិតថា ការបំពុលដោយសំលេងមានផលប៉ះពាល់ប៉ុន្មានទេ ប៉ុន្តែផ្ទុយមកវិញ វាមានផលប៉ះពាល់ខ្លាំង និងផ្ទាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃដែលប្រភពបំពុលមានដូចខាងក្រោម៖

---

[50] គេហទំព័រ http://www.open.edu/openlearncreate/mod/oucontent/view.php?id=80454&printable=1 ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

[51] គេហទំព័រ http://www.groundwater.org/get-informed/groundwater/contamination.html ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៧

### ក. ហេតុបង្ក

យោងតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីអំពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ បានបង្ហាញថាមូលហេតុបង្កឲ្យមានការបំពុលដោយសំលេងគឺមានប្រភពមកពីពីរប្រភពធំៗ។[52]

- ការបំពុលដោយប្រភពចល័ត

ការបំពុលដោយប្រភពចល័តនេះ គឺសំដៅទៅលើការបំពុលដោយសំលេងចេញពីយានយន្តនៅលើផ្លូវសាធារណៈ។ ដោយសារតែចំនួនយាន្តយន្តនៅក្នុងទីរាជធានីមានការកើនឡើងខ្លាំង ការបំពុលដោយសំលេងក៏មានការកើនឡើងដែរ។ ដូចបានរៀបរាប់នៅក្នុងជំពូក១ នៅក្នុងរាជធានីភ្នំពេញសព្វថ្ងៃមានយានយន្តចំនួន៦៧៩,០៩១គ្រឿងកំពុងធ្វើចរាចរណ៍ ដែលនាំឲ្យការបំពុលដោយសំលេងក៏កាន់តែខ្លាំងផងដែរ។

- ការបំពុលដោយប្រភពអចល័ត

ចំពោះប្រភពអចល័តវិញ សំដៅទៅលើប្រភពបំពុលដែលចេញមកពីទីតាំងជាក់លាក់ណាមួយដែលមិនមានបំលាស់ទីដូចប្រភពអចល័តនោះទេ។ ប្រភពបំពុលអចល័តនេះអាចជា រោងចក្រ កន្លែងកំសាន្ត ទីកន្លែងសិប្បកម្ម ការដ្ឋានសំណង់ ជាដើម។ ជាក់ស្តែងសំលេងបុកគ្រឹះនៅការដ្ឋានសំណង់ឬតន្ត្រីនៅក្លឹបកំសាន្តរាត្រី ជាដើមកំពុងតែធ្វើឲ្យមានការបំពុលជារៀងរាល់ថ្ងៃ។

### ខ. ផលប៉ះពាល់

ផលប៉ះពាល់ពីការបំពុលដោយសំលេង មានតែទៅលើមនុស្សតែប៉ុណ្ណោះ។ នៅពេលដែលមនុស្សស្ថិតនៅក្នុងទីកន្លែងដែលមានការបំពុលដោយសំលេងខ្លាំងក្នុងរយៈពេលយូរនោះ នឹងបណ្តាលឲ្យមានផលប៉ះពាល់ដល់លទ្ធិភាពក្នុងការស្តាប់។ បើក្នុងករណីធ្ងន់ធ្ងរនោះក្រដាសត្រចៀកនឹងចាប់ផ្តើមមានបញ្ហា ដែលអាចបណ្តាលឲ្យបាត់បង់នូវលទ្ធភាពក្នុងការស្តាប់ទៀតផង។ លើសពីនេះទៅទៀត ទោះបីការបំពុលដោយសំលេងតិចតួចក៏ដោយ បើមនុស្សស្ថិតនៅក្នុងបរិយាកាសដែលមានការបំពុល

[52] មាត្រា៣នៃ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីអំពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

សំលេងក្នុងរយៈពេលយូរនោះ នឹងបណ្តាលឲ្យសម្ពាធឈាមឡើង។ មិនតែប៉ុណ្ណោះ ក៏នឹងធ្វើឲ្យមានការពិបាកក្នុងការគេង ឬជំងឺគេងមិនលក់ផងដែរ។ ម្យ៉ាងទៀត វាក៏ធ្វើឲ្យមនុស្សមានចរិតឆេវឆាវ ខុសពីធម្មតា និងមានការពិបាកក្នុងការធ្វើសន្ទនាជាមួយនឹងអ្នកដទៃ។[53] ដូចនេះយើងគួរតែស្វែងរកនូវវិធានដំណោះស្រាយនឹងការបំពុលទាំងនេះ។

## ២.២ បញ្ហាបរិស្ថានចំបងៗក្នុងខណ្ឌមានជ័យ

យោងតាមការសង្កេតក្នុងទិត្ថភាពជាក់ស្តែង ខណ្ឌមានជ័យគឺជាខណ្ឌដែលពោរពេញទៅដោយប្រជាជនរស់នៅ និងជាតំបន់សំបូរទៅដោយរោងចក្រ។ ពោល ការបង្កនូវបញ្ហាផ្នែកបរិស្ថានជាកត្តាដែលកើតឡើងជាប្រចាំក្នុងតំបន់នេះ ដោយកត្តាមនុស្សជាចំបង។ បញ្ហាក្នុងពេលបច្ចុប្បន្ន នេះមានការប៉ះពាល់ជាខ្លាំងក្នុងតំបន់នេះ។

ដោយហេតុនេះ បញ្ហាមួយចំនួនដែលប៉ះពាល់ធ្ងន់ធ្ងរដល់តំបន់មានដូចតទៅ៖

### ២.២.១. ការបំពុលដោយកាកសំណល់រឹង និងរាវ

ក្នុងខណ្ឌមានជ័យ នៅតាមដងផ្លូវ ក៏ដូចជានៅតាមមុខផ្ទះរបស់ពលរដ្ឋ យើងអាចសង្កេតឃើញនូវកាកសំណល់ជាច្រើនប្រភេទដែលមិនត្រូវបានរាប់រង និងរៀបចំអោយមានលំដាប់។ ការគ្រប់គ្រងកាកសំណល់រឹង និងរាវនៅតំបន់នេះ នៅមានកំរិតនៅឡើយដោយមូលហេតុចំបង ហើយការបង្កអោយគ្មានសណ្តាប់ធ្នាប់ក្នុងការដាក់សំរាមរឹងនិងរាវនេះគឺបណ្តាលមកពីមូលហេតុចំបងបីយ៉ាង។

ក្នុងការបង្កើននូវឥទ្ធិពលនៃការបំពុលដោយសំណល់រឹង និងរាវ ប្រជាជនរស់នៅក្នុងតំបន់បានលាយឡំ នូវសំណល់រឹង និងរាវ ជាមួយគ្នាក្នុងថង់តែមួយក្នុងការវេចខ្ចប់ ដែលបណ្តាលឲ្យសំណល់តាមពីរប្រភេទក្លាយជាល្បាយ។ ពោលគឺការចោលសំរាមពុំមានការបែងចែកនូវប្រភេទសំណល់ច្បាស់លាស់។ ការប្រមូលផ្តុំចោលសំណល់ជាល្បាយនេះក៏អាចលាយលំជាមួយសំណល់ដែលមានលក្ខណៈជាសរីរាង្គ ដែលអាចរលួយនឹងធ្វើអោយមានក្លិនស្អុយ និងបំពុលទៅដល់ដីដែលជាទីតាំងចោលសំរាមដែលអាចប៉ះពាល់ យ៉ាងខ្លាំងដល់គុណភាពរស់នៅរបស់ប្រជាជន។

---

[53] គេហទំព័រ http://www.conserve-energy-future.com/causes-and-effects-of-noise-pollution.php ដកស្រង់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

បញ្ហាទី ២ ដែលបណ្តាលអោយមានការបំពុលនេះក្នុងខណ្ឌមានជ័យ គឺមកពីការខ្វះខាតនូវទីតាំងត្រឹមត្រូវក្នុងការចោលសំរាម និងវិធីសាស្ត្រក្នុងការគ្រប់គ្រងសំរាម។[54] ក្នុងតំបន់នេះផងដែរ ការទុកចោលសំរាម និង ការប្រមូលនូវមានកំរិតជាខ្លាំង ដោយការចាក់សំរាមត្រូវបានយកមកទុកនៅតាមដងផ្លូវដែលបណ្តាលអោយមានការស្ទះនូវចរាចរណ៍ និង បង្កជាក្លិនស្អុយដែលអាចប៉ះពាល់សុខភាព។[55] ក្រៅពីនេះទៅទៀត ទីតាំងដែលចាក់សំរាមក្នុងតំបន់នេះពុំមានច្បាស់លាស់និងត្រឹមត្រូវឡើយ ពោលគឺការចាក់សំរាម មានលក្ខណៈអាណាធិបតេយ្យដោយគ្មានការគ្រប់គ្រង។[56]

ក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង ការចូលរួម ពីសំណាក់ស្ថាប័ន និងភ្នាក់ងាររដ្ឋនូវមានកំរិតនៅឡើយក្នុងការគ្រប់គ្រងបរិស្ថានក្នុងតំបន់នេះដែលគឺជាកត្តាមួយដ៏ចាំបាច់ក្នុងធានានូវ ការបង្កើតនូវទីតាំង និងការគ្រប់គ្រងនូវសំរាមនូវមានការខ្វះខាតយ៉ាងខ្លាំងផងដែរ។

### ២.២.២. ការបំពុលខ្យល់

ក្រៅពីការបំពុលដោយសំណល់រឹង និងរាវ ក្នុងខណ្ឌនេះផងដែរ ក៏មានបញ្ហានូវការបំពុលខ្យល់កើតឡើងផងដែរ។ ភ្នាក់ងារចំបងក្នុងការបំពុលខ្យល់ក្នុងតំបន់នេះ មាន ៣ កត្តាដែលធ្វើអោយខ្យល់ក្នុងតំបន់នេះមានគុណភាពមិនស្តង់ដា ក្នុងការផ្តល់ការរស់នៅដោយមានគុណភាព។

ក្នុងតំបន់នេះ គំណរសំរាម និងលូរបង្ហូរទឹកកង្វក់ បានក៏នូវការបញ្ចេញក្លិនមិនល្អ ដែលបានផ្តល់ឥទ្ធិពលដល់ការរស់នៅ ជាប្រចាំរបស់មនុស្សក្នុងតំបន់នោះ។ ក្លិនដែលបង្កដោយសំរាម ត្រូវបានបញ្ចេញដោយសារតែ ការខ្វះខាតក្នុងបច្ចេកទេសនៃការវេចខ្ចប់ និងការប្រមូល ដែលធ្វើអោយសំរាមហូរនូវទឹកកង្វក់នៅតាមដងផ្លូវ។ បន្ថែមពីនេះទៅទៀត ប្រព័ន្ធបង្ហូរទឹកកង្វក់ ឬលូរដែលមានទីតាំងនៅជិតផ្ទះរបស់ប្រជាពលរដ្ឋ ដែលនៅតំបន់នោះក៏ចូលរួមក្នុងការបង្កក្លិនមិនល្អដែលអាចប៉ះពាល់ដល់ទៅសុខភាពរបស់ប្រជាជន។

---

[54] គេហទំព័រ http://www.maciejdakowicz.com/features/stung-meanchey-garbage-dump-phonm-penh-cambodia/ ដកស្រង់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧

[55] គេហទំព័រ http://www.phnompenhpost.com/scavengers-linger-long-dead-dump-site ដកស្រង់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧

[56] គេហទំព័រ https://www.theguardian.com/cities/2016/oct/11/hell-earth-great-urban-scandal-life-rubbish-dump ដកស្រង់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧

ការចរាចរណ៍នៃរថយន្តក្នុងតំបន់នេះក៏មានភាពមមៀរញឹកផងដែរ ដោយរថយន្តទាំងនោះត្រូវចរាចរណ៍ចូលមកកាន់ទីប្រជុំជន។ ដោយការចរាចរណ៍នេះ បាននាំមកនូវជាមួយដី និងធូលីដែលបានលាយលំចូលជាមួយខ្យល់ ដែលធ្វើអោយមានកំណើនធូលីចូលក្នុងខ្យល់ដែលធ្វើអោយមានលក្ខណៈពិបាកក្នុងការដកដង្ហើម។ បន្ថែមទៅទៀត កំនើននៃចរាចរណ៍នេះ ក៏បានចូលរួមបង្កើននូវការបញ្ចេញផ្សែងរបស់រថយន្តចាស់ៗ ដែលបន្ថយគុណភាពនៃខ្យល់។

ក្រៅពីនេះទៅទៀត ការចូលរួមបំពុលខ្យល់ដោយរោងចក្រក៏ជាកត្តាដែលគួរអោយកត់សំគាល់ផងដែរ។ ដោយក្នុងតំបន់នេះ រោងចក្រ មួយចំនួនត្រូវបានសាងសង់ហើយត្រូវដំណើរការរាល់ថ្ងៃដែលបណ្តាលអោយបញ្ចេញឧស្ម័នដែលមានការប៉ះពាល់ដល់ប្រជាជនរស់ដែលនៅតំបន់នោះ ហើយក៏ដូចជាកម្មករ និងកម្មការនីដែលបំរើការងារក្នុងនោះផងដែរ។ ក្រៅពីនេះ ក្នុងតំបន់នេះក៏ សំបូរនូវរោងចក្រ និងទីតាំងស្តុក និងផលិតខ្សាច់ និងស៊ីម៉ង់ដែលបញ្ចេញធូលី និងដីចូលក្នុងខ្យល់ដែលបង្ខូចគុណភាពខ្យល់។

### ២.២.៣ ការបំពុលទឹក

ក្រៅពីការបំពុលដោយសំណល់ និងការបំពុលខ្យល់ ការបំពុលទឹកក៏ជាបញ្ហាដែលជាកត្តាមួយចំបងដែលប៉ះពាល់ទៅដល់ការរស់នៅរបស់ប្រជាជន និងសោភ័ណ្ឌភាពនៃការរៀបចំក្រុងក្នុងតំបន់នេះផងដែរ។ ការបំពុលទឹកក្នុងតំបន់នេះត្រូវបានបង្កដោយកត្តា ៣ ជាចំបង។

ការបំពុលទឹកត្រូវបានបង្កឡើងដោយការបង្ហូរទឹក និងទង្វើនៃការបោះចោលសំរាមរបស់ទៅក្នុងទឹកដែលធ្វើអោយកង្វក់ទឹក។ ការបង្ហូរទឹកស្អុយ និងចោលសំរាមចូលទឹកនេះធ្វើអោយមានការបំពុលទឹក ដែលមិនអាចប្រើប្រាស់បាន និងប៉ះពាល់ដល់ជីវៈចំរុះដែលនៅក្នុងទឹកនោះផង។ ក្រៅពីនេះ ការបង្ហូរទឹកកង្វក់ និងចោលសំរាមចូលទៅក្នុងទឹកធ្វើអោយទឹកមានលក្ខណៈកករដែលបណ្តាលអោយទឹកមានភាពកង្វក់ដែលធ្វើអោយប៉ះពាល់ទៅដល់សុខភាព និងសោភ័ណ្ឌភាពរបស់បរិស្ថាន។

ការបំពុលទឹកនេះផងដែរក៏ត្រូវបានបង្កើនដោយភាពកង្វះខាតនូវបច្ចេកទេស និងសមត្ថភាពក្នុងការគ្រប់គ្រងរបស់ប្រព័ន្ធលូ ដែលធ្វើអោយការចាត់ចែង និងគ្រប់គ្រងទៅលើការបង្ហូរទឹកកង្វក់នូវមានកំរិតដែលនាំអោយបញ្ហាទឹកលូ ប៉ះពាល់ទៅដល់ប្រជាជនដែលរស់នៅតំបន់នោះផង ម្យ៉ាងទៀត

ការខ្វះខាតក្នុងការគ្រប់គ្រងនេះក៏ប៉ះពាល់យ៉ាងខ្លាំងទៅដល់សោភ័ណ្ឌភាពនៃការរៀបចំក្រុងដែលទឹកល្វ នោះបានបញ្ចេញក្លិនមិនសមរម្យ និងស្ថិតនៅតំបន់ដែលមានប្រជាពលរដ្ឋរស់នៅច្រើន។

## ២.៣. វិធានការដោះស្រាយទៅនឹងការបំពុលបរិស្ថាន

ជាទូទៅ រាល់ការបង្កឡើងអោយមានការបំពុលបរិស្ថាន ទោះជាកំរិតណាក្តី វិធានការចាំបាច់ និងត្រូវរៀបចំឡើងដើម្បីធានាដល់គុណភាពរស់នៅរបស់ប្រជារាស្ត្រក្នុងតំបន់ និងស្ថេរភាពរបស់ប្រព័ន្ធជីវសាស្ត្រ ដោយសារការបំពុលបិរស្ថានអាចផ្តល់អោយមានលទ្ធផលអវិជ្ជមានច្រើនសំរាប់បុគ្គល និងសង្គមជារួម។ ម្យ៉ាងវិញទៀតចំពោះការបំពុលដែលបានបកស្រាយខាងលើ ដំណោះស្រាយគឺជាកត្តាមួយដ៏ចាំបាច់ក្នុងការធានានូវនិរន្តភាពនៃបរិស្ថានស្អាត ហើយវិធានការទាំងនោះត្រូវរៀបចំ និងសិក្សាយ៉ាងល្អិតល្អន់ដោយក្រសួង និងអង្គការជំនាញដើម្បីរក្សានូវវិធានការដែលមានប្រសិទ្ធិភាពបំផុតក្នុងការដោះស្រាយនូវកត្តាបរិស្ថានផ្សេងៗគ្នា។

ដោយឡែកវិញ ក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការដំណោះស្រាយទៅលើបញ្ហាបរិស្ថាន និងធនធានធម្មជាតិជារួមត្រូវបានធ្លាក់ទៅលើសម្តតកិច្ចរបស់រាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដោយចូលរួមសហការជាមួយក្រសួងពាក់ព័ន្ធ[57] ដោយវិធានការនោះត្រូវប្រកបដោយនិរន្តភាព និងស្ថេរភាព។[58] ក្នុងគោលការជារួម ការការពារបរិស្ថាន និងដំណោះស្រាយការបំពុលបរិស្ថានត្រូវស្ថិតក្រោមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី១៨ វិច្ឆិកា ១៩៩៦ ដែលមានគោលដៅជារួមដូចតទៅ៖

- ការពារ លើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងត្រួតពិនិត្យការបំពុល
- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គំរោងដែលបានស្នើរឡើង

---

[57] មាត្រា២ នៃ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី១៨ វិច្ឆិកា ១៩៩៦

[58] មាត្រា៣ នៃ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី១៨ វិច្ឆិកា ១៩៩៦

- ធានាអោយមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល ដែលប្រកបទៅដោយនិរន្តភាពនិងភាពស្ថិតស្ថេរនៃធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា។
- លើកទឹកចិត្តនិងផ្តល់លទ្ធភាពអោយសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- បង្ក្រាបអំពើទាំងឡាយដែលធ្វើអោយប៉ះពាល់ដល់បរិស្ថាន។[59]

ទោះយ៉ាងណាក្តី ក្រៅពីការធានាបាននូវវិធានការពារនិងដំណោះស្រាយពីសំណាក់ស្ថាប័នរដ្ឋ សាធារណជន ក៏ជាបុគ្គលសំខាន់ក្នុងការចូលរួមដោះស្រាយនូវបញ្ហាបរិស្ថានដែលកើតដោយមានការជំរុញអោយចូលរួម។[60]

ចំណុចដែលគួរអោយកត់សំគាល់ គឺទាក់ទងទៅការចេញសេចក្តីសម្រេចទៅលើការការពារទៅលើបរិស្ថាន។ ពោលគឺ ដើម្បីធានានូវការការពារដ៏មានប្រសិទ្ធិភាព មុនការសម្រេចអនុញ្ញាតអោយមានការសាងសង់គំរោងណាមួយ ក្រសួងបរិស្ថានត្រូវធ្វើការចុះត្រួតពិនិត្យយ៉ាងល្អិតល្អន់ជាមុនសិនដើម្បីកំណត់ទំហំនៃផលប៉ះពាល់ទៅលើបរិស្ថាន មុនឈានទៅដល់ការសម្រេចចិត្ត ហើយវិធាននេះមានឈ្មោះបច្ចេកទេសហៅថា Environmental Impact Assessment (EIA)។

### ២.៣.១. វិធានការដោះស្រាយទៅនឹងការបំពុលទឹក ដី និងខ្យល់

#### ២.៣.១.១ វិធានការដោះស្រាយទៅនឹងការបំពុលទឹក

យោងតាមការបកស្រាយខាងលើ ប្រភពចំបងដែលបានបង្កអោយមានការបំពុលទឹកមានដូចជា រោងចក្រ ការបង្ហូរទឹកកង្វក់ និងសំរាមជាដើម។ ការបង្កអោយមានការបំពុលទឹកនេះធ្វើអោយប៉ះពាល់ជាធ្ងន់ធ្ងរទៅលើគុណភាពរស់នៅរបស់មនុស្ស ព្រមទាំងសត្វ និងជីវសាស្ត្រដែលពាក់ព័ន្ធ ដែលជាហេតុដែលតម្រូវអោយមានដំណោះស្រាយ។ ជាទូទៅ នៅព្រះរាជាណាចក្រកម្ពុជា មុនឈានដល់ដំណោះស្រាយ ក្រសួងបរិស្ថានមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនិងវាស់គុណភាពនៃទឹក និងស្វែងរកប្រភពនៃការបំពុលមុនការចេញដំណោះស្រាយដែលពាក់ព័ន្ធ។[61]

---

[59] មាត្រា១ នៃ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី១៨ វិច្ឆិកា ១៩៩៦

[60] មាត្រា១៦ នៃ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី១៨ វិច្ឆិកា ១៩៩៦

[61] មាត្រា ១៨ និង ១៩ នៃ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃ០៦ មេសា ១៩៩៩

ដោយឡែកវិញ ដំណោះស្រាយទាក់ទងទៅនឹងការបំពុលទឹកត្រូវបានបែងចែកជា ២ គឺវិធានការកាត់បន្ថយ និងដោះស្រាយការបំពុលទឹក។

### ក. វិធានការកាត់បន្ថយការបំពុលទឹក

វិធានការក្នុងការកាត់បន្ថយការបំពុលទឹក ត្រូវកំណត់ធានានិងតម្រូវអោយមានការចូលរួមយ៉ាងស្អិតស្អាលរវាងប្រជាជន និងស្ថាប័នជំនាញ។ ក្នុងការកាត់បន្ថយការបំពុលទឹក វិធានការមួយចំនួនត្រូវបានរៀបចំឡើងដូចជា៖

- ការគ្រប់គ្រងយ៉ាងតឹងរឹងទៅលើការបញ្ចេញសំណល់រាវពីរោងចក្រដែលមានសារធាតុបំពុលដែលបង្ហូរចូលដល់ទឹក ដោយហេតុថានេះជាកត្តាចំបងក្នុងការបំពុល។
- ការកាត់បន្ថយការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងថ្នាំបាញ់ដីដែលជ្រៀបចូលទឹកក្នុងដី (Groundwater) ដែលអាចធ្វើខូចគុណភាពទឹក ដែលធ្វើអោយទឹកនោះមិនអាចបរិភោគបាន។
- ពង្រឹងការអប់រំទៅដល់ប្រជារាស្ត្រទៅការគ្រប់គ្រងសំណល់រាវ នៅតាមលំនៅដ្ឋាន ក្នុងការរក្សានិងវេចខ្ចប់អោយបានត្រឹមត្រូវ និងធានាជៀសវាងការបង្ហូរតាមបង្គន់ដែលអាចប៉ះពាល់ទៅដល់ប្រព័ន្ធទឹក។
- ជាងនេះទៅទៀត ប្រជារាស្ត្រត្រូវទទួលការពន្យល់ដោយមានចំណេះដឹងច្បាស់លាស់ទាក់ទងទៅនឹងការចោលសំរាមចូលក្នុងទឹកជាពិសេសការបន្ទោរបង់ក្នុងទឹកនិងការចោលកាកសំណល់រឹង។
- រាជរដ្ឋាភិបាលក៏បានតួនាទីសំខាន់ក្នុងការកាត់បន្ថយការបំពុលទឹកតាមរយៈការរឹតបន្តឹងច្បាប់គ្រប់គ្រងការបំពុលទឹកដោយមានការទោសនិងពិន័យធ្ងន់ធ្ងរដល់ជនដែលល្មើស។

### ខ. វិធានការដោះស្រាយការបំពុលទឹក

ដោយឡែក ក្នុងករណីទឹកត្រូវរងការបំពុលហើយ ដំណោះស្រាយដើម្បីធានាអោយមានទឹកដែលមានគុណភាពត្រូវបានធ្វើតាមវិធីសាស្ត្រម្យ៉ាងដែលមានឈ្មោះថា Community Water Treatment ដើម្បីដោះស្រាយ និងសំអាតទឹកដែលមានសារធាតុបំពុល ដោយក្នុងវិធានការនេះតម្រូវអោយមានការ

សាងសង់អាងសំអាតទឹក (Water treatment planation)។[62] ការបង្កើតនូវអាងសំអាតទឹកនេះជាវិធានការដ៏មានប្រសិទ្ធិភាព ព្រោះអាងសំអាតទឹក ក៏អាចស្តុកនូវទឹកភ្លៀងសំរាប់ការបង្កើតនូវទឹកស្អាត។

ការសំអាតទឹកដែលមានជាតិបំពុលនេះត្រូវបានធ្វើឡើងតាមលំដាប់ដូចតទៅ[63]៖

- ដំណាក់កាលទី ១ (Coagulation/Flocculation) ៖ ក្នុងដំណាក់កាលនេះ ការប្រើប្រាស់សារធាតុអាលុយមីញ៉ូមស៊ុលផាត ត្រូវបានដាក់បញ្ចូលជាមួយទឹកកខ្វក់ ដើម្បីអោយធូលីក្នុងទឹករួមបញ្ចូលគ្នាដើម្បីបង្កើតជាដុំធូលីធំដើម្បីងាយស្រួលសំអាត។
- ដំណាក់កាលទី ២ (Sedimentation) ៖ ក្នុងដំណាក់កាលនេះដុំធូលីធំ ឬធាតុកខ្វក់បានទៅផ្តុំនៅផ្នែកក្រោមនៃទឹក ហើយនឹងត្រូវសំអាតដោយមានការប្រើប្រាស់សន្ទះ Filter។
- ដំណាក់កាលទី ៣ (Filtration) ៖ ក្នុងដំណាក់កាលនេះទឹកដែលមានសារធាតុបំពុលហូរឆ្លងកាត់សន្ទះ Filter ដែលប្រមូលយកធាតុកខ្វក់ពីទឹក។
- ដំណាក់កាលទី ៤ (Disinfection) ៖ ទឹកត្រូវបានសំអាតនូវមេរោគនិងធាតុកខ្វក់ដោយការប្រើប្រាស់សារធាតុក្លរីន ក្នុងការកំទេចមេរោគមុនចូលដល់ប្រព័ន្ធចែកចាយការប្រើប្រាស់ទឹក។
- ដំណាក់កាលទី ៥ (Sludge drying) ៖ ធូលីដី និងសារធាតុកខ្វក់ត្រូវបានប្រមូលក្នុងដំណាក់កាលនេះដើម្បីសំអាតចោល។
- ដំណាក់កាលទី ៦ (Fluoridation) ៖ ក្នុងដំណាក់កាលនេះទឹកសំអាតហើយត្រូវបានបន្ថែមសារធាតុ Fluoride ដើម្បីធានាគុណភាពទឹកសំរាប់ប្រើប្រាស់និងបរិភោគ។
- ដំណាក់កាលទី ៧ (Ph correction) ៖ គុណភាពរបស់ត្រូវបានវាស់ដើម្បីរក្សា កំរិត Ph ក្នុងទឹកសំរាប់ការប្រើប្រាស់និងបរិភោគ។

[62] គេហទំព័រ https://www.hunterwater.com.au/Water-and-Sewer/Water-Supply/Water-Treatment-Processes.aspx ដកស្រង់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧

[63] គេហទំព័រ https://www.hunterwater.com.au/Water-and-Sewer/Water-Supply/Water-Treatment-Processes.aspx ដកស្រង់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧

### ២.៣.១.២. វិធានការដោះស្រាយទៅនឹងការបំពុលដី

ចំណែកការបំពុលដីវិញ ការបំពុលជាទូទៅកើតឡើងតាមរយៈការបំពុលដោយសំរាម និងការបំពុលដោយសារធាតុគីមី។ ក្នុងការគ្រប់គ្រងនិងវិធានការទាក់ទងទៅនឹងការបំពុលដីមានដូចតទៅ[64]៖

- កត្តាចំបងក្នុងការអនុវត្តបានសំរេចនូវវិធានការដោះស្រាយនូវការបំពុលដីតម្រូវចាំបាច់នូវការអប់រំផ្នែកចំនេះដឹងរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសំណល់ និងវិធានការវេចខ្ចប់និងបែងចែកច្បាស់លាស់រវាងសំណល់នីមួយៗ។
- ទាក់ទងនឹងសំរាមនេះផងដែរ ស្ថាប័នរដ្ឋក៏ត្រូវធានាអោយមានការបង្កើតទីកន្លែងមួយដែលប្រាកដជាក់លាក់ដើម្បីប្រជាជនអាចប្រមូលដាក់ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រមូលផ្តុំ ជៀសវាងការបោះចោលពាសវាលពាសកាលដែលបណ្តាលអោយមានការប៉ះពាល់ដល់ដីជាច្រើនកន្លែង។
- ចាត់ចែងផែនការក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងកាកសំនល់អោយមានប្រសិទ្ធិភាព និងជំរុញអោយប្រជាជានកាត់បន្ថយការប្រើប្រាស់សំភារៈ។
- កាត់បន្ថយការប្រើប្រាស់ថ្នាំបាញ់សត្វល្អិត និងជីគីមីត្រូវជំនួសវិញដោយការប្រើប្រាស់ជីធម្មជាតិ។

### ២.៣.១.៣. វិធានការដោះស្រាយទៅនឹងការបំពុលខ្យល់

ជាទូទៅ បញ្ហាក្នុងការបំពុលខ្យល់ត្រូវបានចាត់ចែងនិងគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលមានតួនាទីមួយក្នុងការត្រួតពិនិត្យ និងអនុញ្ញាតទៅលើការបញ្ចេញខ្យល់ដែលអាចផ្តល់ការប៉ះពាល់ទៅដល់បរិស្ថាន ដោយយោងតាមជំពូកទី ៣ និងជំពូកទី ៤ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃ១០ កក្កដា ២០០០។ បន្ថែមពីលើនេះទៅទៀត គុណភាពរបស់ខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានត្រួតពិនិត្យ និងតាមដានជាប្រចាំដោយក្រសួងបរិស្ថាន។[65]

---

[64] ដកស្រង់ចេញ សៀវភៅ "Global Studies 302" រៀបចំដោយ លោក អ៊ោម សូរីយ៉ុង ទំព័រ ៧៦

[65] មាត្រា ២៦ នៃ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ថ្ងៃ១០ កក្កដា ២០០០

ភ្នាក់ងារដែលបានចូលរួមក្នុងការបំពុលខ្យល់ដែលបានបកស្រាយខាងលើ គឺជាកត្តាដែលជំរុញអោយមានការរៀបចំវិធានការក្នុងការដោះស្រាយទៅលើបញ្ហាបំពុលខ្យល់។ ក្នុងវិធានការដោះស្រាយនូវបញ្ហាបំពុលខ្យល់ ដំណោះស្រាយត្រូវបានបែងចែកទៅតាមកត្តាខាងក្រោម។

កត្តាបំពុលខ្យល់ជាទូទៅត្រូវបានបង្កើតឡើងដោយភាគច្រើនដោយមនុស្សដែលជាកត្តាចំបង។ ក្នុងកត្តានេះ ការបំពុលខ្យល់កើតឡើងដោយទាក់ទងទៅនឹងការរស់នៅប្រចាំថ្ងៃដែលដំណោះស្រាយអាចមានដូចតទៅ[66]៖

- តួនាទីរាជរដ្ឋាភិបាល
  - ក្នុងការបំពុលខ្យល់តាមការប្រើប្រាស់រថយន្តរបស់ប្រជាជន រាជរដ្ឋាភិបាលត្រូវធានាការបង្កើតឡើងនូវសេវាដឹកជញ្ជូនសាធារណៈក្នុងការកាត់បន្ថយនូវការប្រើប្រាស់រថយន្តផ្ទាល់ខ្លួន។
  - រាជរដ្ឋាភិបាលត្រូវចាត់ជាវិធានការទៅលើការប្រើប្រាស់រថយន្តចាស់ៗ ដោយបង្កើនពន្ធនាំចូលទៅលើរថយន្តចាស់ៗ និងកាត់បន្ថយពន្ធលើរថយន្តថ្មីៗ ក្នុងគោលបំណងដើម្បីកាត់បន្ថយបរិមាណរថយន្តចាស់ៗដែលបញ្ចេញឧស្ម័នពុលដល់បរិយាកាស។
  - ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលត្រូវធានានូវការការពារ និងការបង្កើតទិវាដាំដើមឈើដែលជាភ្នាក់ងារសំខាន់ក្នុងការសំអាតខ្យល់ក្នុងបរិយាកាស រួមទាំងដើម្បីបង្កើនសោភ័ណ្ឌភាព។
  - រាជរដ្ឋាភិបាលត្រូវចាត់វិធានការតឹងរឹងចំពោះការគ្រប់គ្រងឧស្ម័នដែលអាចមានជាតិពុល និងការបញ្ចេញផ្សែងរបស់រោងចក្រ ដែលអាចទាក់ទងទៅនឹងកំរិតនៃការបញ្ចេញ និងធានារាល់ការសាងសង់ត្រូវបានពិនិត្យយ៉ាងជាក់លាក់ដូចដែលអនុក្រឹត្យបានចែង។[67]
- តួនាទីរបស់សាធារណជន
  - សាធារណជនអាចចូលរួមប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ឬប្រើប្រាស់រថយន្តសំរាប់ដឹកមនុស្សច្រើននាក់ដើម្បីកាត់បន្ថយការប្រើប្រាស់រថយន្ត។

[66] សៀវភៅ "Global Studies 302" រៀបចំដោយ លោក អ៊ោម សូរីយ៉ុង ទំព័រ ៦៤

[67] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ថ្ងៃ១០ កក្កដា ២០០០

- ក្រៅពីនេះ ការកំនត់និងធានានូវភាពស្អាតនៃរថយន្តតាមការលាងសំអាតអាចចូលរួមកាត់បន្ថយនូវការបំពុលខ្យល់ដោយធូលី។
- លើសពីនេះទៅទៀត សាធារណជនក៏អាចចូលរួមតាមការកាត់បន្ថយការប្រើប្រាស់ធ្យូងឬអុសដែលបញ្ចេញផ្សែងប៉ះពាល់ដល់ខ្យល់ដោយប្តូរមកប្រើចង្រ្កានអគ្គិសនីវិញ។
- ការកាត់បន្ថយនូវប្រើប្រាស់ម៉ាស៊ីនត្រជាក់ដែលបញ្ចេញសារធាតុ CFCs ក៏អាចបន្ថយការបំពុលខ្យល់ផងដែរ។

## ២.៣.២. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំណល់រឹង រាវ និងសំលេង

### ២.៣.២.១. វិធានការដោះស្រាយទៅនឹងការបំពុលដោយសំណល់រឹង

ក្នុងព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងសំណល់រឹងក៏ត្រូវបានរៀបចំ និងអនុវត្តដោយបន្ថែមអនុក្រឹត្យស្តីពីការគ្រប់គ្រង សំណល់រឹង[68] ដែលបានចែងទាក់ទងទៅការគ្រប់គ្រងសំរាមពីរប្រភេទៈ សំរាមធម្មតា និងសំរាមប្រកបដោយគ្រោះថ្នាក់។ ក្នុងនោះផងដែរ ការរៀបចំនិងចាត់ចែងសំរាមទាំងពីរប្រភេទត្រូវស្ថិតនៅក្រោមការសម្រេចរបស់ក្រសួងបរិស្ថាន ក្នុងការពិនិត្យលើការអនុវត្តន៍ក្នុងការរៀបចំបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយ និងការចាក់ចោលសំរាម។[69]

ដោយឡែកវិញ ការកើនឡើងនូវសំណល់រឹងគឺបណ្តាលមកពីកំនើននៃតំរូវការក្នុងការប្រើប្រាស់របស់មនុស្ស។ ជាទូទៅ វិធានការក្នុងការដោះស្រាយបំពុលដោយសំណល់រឹងមាន ៥ យ៉ាងៈ

- កន្លែងចាក់សំរាម (Landfill)

ក្នុងវិធានការនេះ ការគ្រប់គ្រងទៅលើសំណល់រឹងត្រូវបានដឹកទៅកាន់ទីតាំងមួយដែលស្ថិតនៅឆ្ងាយពីទីប្រជុំជន ហើយកាក់សំណល់រឹងនោះនឹងត្រូវបានយកទៅចាក់ចោលនៅតំបន់នោះដោយមានការចាក់ស្រទាប់ដីពីលើដើម្បីធ្វើការកប់សំរាម។

[68] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ថ្ងៃ២៧ មេសា ១៩៩៩
[69] មាត្រា ៦ នៃ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ថ្ងៃ២៧ មេសា ១៩៩៩

- ការកែច្នៃឡើងវិញ (Recycle)

ក្នុងការគ្រប់គ្រងទៅលើសំណល់រឹង បំណែងចែកនៃសំណល់រឹងត្រូវបានធ្វើឡើងដោយការបែងចែកនេះអនុញ្ញាតអោយដឹងថាប្រភេទសំណល់រឹងណាអាចធ្វើការកែច្នៃឡើងវិញ។ ជាដំណោះស្រាយការប្រើប្រាស់នូវវិធីសាស្ត្រខាងក្រោមអាចផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជា[70]៖

- ការថយចុះនូវក្នុងការចាក់ចោលសំណល់ នឹងកាត់បន្ថយការប៉ះពាល់ទៅដល់បរិស្ថាន ។
- ពន្យាពេលអាយុប្រើប្រាស់វត្ថុចាស់ និង លើកកំពស់ការគ្រប់គ្រងទៅលើកន្លែងចាក់សំរាម។
- ថែរក្សាធនធានធម្មជាតិ និងសន្សំសំចៃថាមពលក្នុងការផលិតវត្ថុធាតុថ្មី។
- បង្កើតនូវសកម្មភាពសេដ្ឋកិច្ច និងការងារថ្មី។
- កាត់បន្ថយការនាំចូលទំនិញនិងរូបធាតុដើម។

- កំប៉ុសកម្ម

ទាក់ទងទៅនឹងកំប៉ុសកម្ម ការរៀបចំនូវសំណល់រឹងគឺអនុវត្តទៅលើសំណល់បែបសរីរាង្គ ដែលសំណល់ប្រភេទនេះត្រូវបានរាប់រងដោយការយកសំណល់ប្រភេទនេះត្រូវបានយកទៅបំលែងទៅជាជីដើម្បីប្រើប្រាស់ក្នុងកសិកម្ម។

- ការដុតសំណល់

ក្នុងការរាប់រង់ការសំណល់រឹង វិធីនេះត្រូវបានធ្វើដោយ ការយកកាក់សំណល់រឹងត្រូវបានយកទៅដុត នៅក្នុងសីតុណ្ហភាពខ្ពស់ នៅក្នុងឡកំដៅមួយ។ ផេះដែលបន្សល់ពីការដុតសំណល់រឹងនេះ ត្រូវបានយកទៅប្រើប្រាស់ជាជី សំរាប់ប្រើប្រាស់ក្នុងកសិកម្ម។

- ការកាត់បន្ថយនៅនឹងប្រភព និងការប្រើប្រាស់ឡើងវិញ

គោលការណ៍ដែលបានកំណត់នេះ មានទ្រឹស្តីជាមូលដ្ឋានផ្តោតទៅលើ គោលការណ៍ដែលហៅថា Three R(s) ដែលមានចែងដូចតទៅ[71]៖

---

[70] មូលដ្ឋានគ្រឹះនៃបរិស្ថាន លោក ស្អាន់ វិន ទំព័រ១១៨ ដល់១២៥

- ការកាត់បន្ថយនៅនឹងប្រភព (Reduce)៖ ដើម្បីអោយមានការថយចុះនៃកាកសំណល់រឹង យើងរមែងធ្វើនូវការរៀបចំ និងការប្រើប្រាស់ដែលមានលក្ខណៈសន្សំសំចៃ ដើម្បីរក្សាបរិមាណនៃការប្រើប្រាស់។
- ការប្រើប្រាស់ឡើងវិញ (Reuse) ៖ ក្នុងការប្រើប្រាស់វត្ថុ មុននឹងឈានដល់ការបោះចោល យើងអាចប្រមូលផ្តុំនូវវត្ថុខ្លះដែលអាចប្រើប្រាស់បានយកមកទុកដើម្បីបន្ថយបរិមាណសំណល់។
- ការកែច្នៃឡើងវិញ (Recycle) ៖ គឺសំដៅទៅការផលិតវត្ថុឡើងវិញដូចដែលបានបកស្រាយខាងលើ។

### ២.៣.២.២. វិធានការដោះស្រាយនៅនឹងការបំពុលដោយសំណល់រាវ

ជាទូទៅ សំណល់រាវមានប្រភពបង្កចំបងមកពីរោងចក្រ លំនៅដ្ឋាន និងកន្លែងអាជីវកម្មមួយចំនួនដូចដែលបានបកស្រាយខាងលើ។ ចំពោះការគ្រប់គ្រងសំណល់រាវ ដោយសារផ្នែកបច្ចេកវិទ្យានៅមានកំរិត ពោលការរាប់រងនិងគ្រប់គ្រងទៅលើសំណល់រាវនៅមានកំរិតដែលបង្កើតអោយមានផលប៉ះពាល់ដល់ជីវភាពរស់នៅនិងបរិស្ថាន។ ក្នុងការរាប់រងនូវសំណល់រាវ វិធានការក្នុងគ្រប់គ្រងត្រូវបានបែងចែកទៅតាមតួនាទីដូចតទៅ៖

- តួនាទីរាជរដ្ឋាភិបាល៖
  - ធានាអោយបាននូវការផ្តល់សេវាក្នុងការប្រមូលសំរាមដែលមានផ្តល់នូវការវេចខ្ចប់ត្រឹមត្រូវជៀសវាងការហូរទឹកស្អុយចេញពីសំរាម។
  - ត្រូវរៀបចំនូវប្រព័ន្ធគ្រប់គ្រងសំណល់រាវដែលអាចសំអាតសារធាតុរាវដែលកង្វក់ក្នុងសំរាមមុនការបោះចោល។[72]
  - ការរៀបចំនូវការអប់រំដល់ប្រជាពលរដ្ឋដើម្បីអោយមានការស្វែងយល់ដល់ក្នុងការរាប់រងសំណល់រាវ។
- តួនាទីសាធារណជន៖
  - ចូលរួមក្នុងការទទួលបានការណែនាំនិងការអប់រំទៅលើការគ្រប់គ្រងសំណល់រាវ។

---

[71] មូលដ្ឋានគ្រឹះនៃបរិស្ថាន លោក ស្ពាន់ វិន ទំព័រ១១៨ ដល់១២៥

[72] គេហទំព័រ http://www.signalwaste.com.au/Article-The-Best-Liquid-Waste-Disposal-Methods-pg25548.html ដកស្រង់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

- ធ្វើការបែងចែកនូវប្រភេទសំណល់អោយច្បាស់លាស់មុនធ្វើការវេចខ្ចប់ដើម្បីអោយមានភាពងាយស្រួលក្នុងការប្រមូល។
- ការបង្ហូតទឹកពីសំរាមមុនការបោះចោល ឬ ការវេចខ្ចប់ក៏អាចចូលរួមក្នុងការពារមិនអោយមានការហូរទឹកចេញពីសំរាម។[73]

### ២.៣.២.៣. វិធានការដោះស្រាយនៅនឹងការបំពុលដោយសំលេង

ក្នុងការគ្រប់គ្រងទៅលើសំលេងដែលបង្កជាការប៉ះពាល់ដល់បរិស្ថាន គឺស្ថិតក្នុងកំរិតមួយដែលទាប។ ពោលគឺការចេញវិធានការដំណោះស្រាយទាក់ទងការបំពុលដោយសំលេង នាពេលបច្ចុប្បន្នត្រូវបានកំរិតដោយមជ្ឈដ្ឋានមួយចំនួនដូចជា បញ្ហាផ្នែកបច្ចេកទេស និងបច្ចេកវិទ្យាដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែផ្ទុយទៅវិញការបំពុលដោយសំលេងមួយចំនួនមានវិធានការដែលអាចប្រើប្រាស់បានតាមរយៈដូចខាងក្រោម៖

- ការធានានិងរៀបចំឡើងនូវប្រព័ន្ធការពារសំលេង ដែលការពារនិងកាត់បន្ថយសំលេងរំខានដែលមានកម្រិតគ្រោះថ្នាក់ដល់ការស្តាប់។
- ការរៀបចំបន្លាស់ទីតាំងរបស់ស្ថានីយ៍សេវាដឹកជញ្ជូនសាធារណៈទៅតំបន់ដាច់ស្រយាលដើម្បីកាត់បន្ថយការប៉ះពាល់។
- ការប្រើប្រាស់ប្រដាប់បិទត្រចៀក អាចជាឧបករណ៍ដ៏ចាំបាច់ក្នុងការការពារសំលេងរំខានជាពិសេសសំរាប់សំលេងរំខាន់ដែលចេញមកពីការសាងសង់។
- ការប្រើប្រាស់នូវរថយន្តដែលចាស់ហើយមានសំលេងរំខានខ្លាំងត្រូវមានការគ្រប់គ្រងយ៉ាងតឹងរឹងដោយហេតុដែលផ្តល់ផលប៉ះពាល់។[74]

---

[73] គេហទំព័រ http://www.signalwaste.com.au/Article-The-Best-Liquid-Waste-Disposal-Methods-pg25548.html ដកស្រង់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

[74] គេហទំព័រ http://eschooltoday.com/pollution/noise-pollution/noise-pollution-prevention.html ដកស្រង់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយក្នុងការរៀបចំទីក្រុងអោយមានសោភ័ណ្ឌភាព និង មានលក្ខណៈជាទីក្រុងដែលស្តង់ដា ការរៀបចំនូវខណ្ឌមានលក្ខណៈសំខាន់ខ្លាំងណាស់ ក្នុងការសម្រេចទិសដៅនៃភាពជោគជ័យរបស់ការរៀបចំទីក្រុង។ ដោយឡែកវិញ ការធានាអោយបាននូវបានការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌមានជ័យ គឺជាកត្តាមួយដ៏សំខាន់ដើម្បីអោយការរៀបចំទីក្រុង និងការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះមានលក្ខណៈស្តង់ដា និងល្អប្រសើរ។ ក្នុងការរៀបចំខណ្ឌនេះផងដែរ កត្តាពីរសំខាន់ៗត្រូវបានផ្តោតទៅលើដូចដែលបានបកស្រាយខាងលើ។

ដើម្បីអោយធានាបាននូវការរៀបចំសណ្តាប់ធ្នាប់ ក្នុងខណ្ឌនេះ ការបែងចែក និងសិក្សាទៅលើបុព្វហេតុដែលនាំអោយមានការរៀបចំខណ្ឌកើតឡើង ដែលក្នុងនោះផងដែរមានបញ្ហាដូចជា កំណើនប្រជាជន ចរាចរណ៍ សន្តិសុខ និងសណ្តាប់ធ្នាប់ ត្រូវបានចោទជាបញ្ហាចំបងដែរបណ្តាលអោយមានការរៀបចំនេះ។ ហើយក្នុងការធានាបានូវការរៀបចំមួយដ៏មានប្រសិទ្ធិភាព ការបែងចែក និងស្វែងយល់ពីហេដ្ឋារចនាសម្ព័ន្ធជាគន្លឹះនៃការរៀបចំផែនការអភិវឌ្ឍន៍តំបន់នេះដើម្បីធ្វើអោយការរៀបចំខណ្ឌមានភាពងាយស្រួលក្នុងការចង្អុលបង្ហាញបញ្ហាដែលត្រូវដោះស្រាយ។

ក្រៅពីការសិក្សាទៅលើហេដ្ឋារចនាសម្ព័ន្ធ ការសិក្សាទៅលើបរិស្ថាននៃតំបន់នេះ គឺជាកត្តាមួយដ៏ចំបងដែលសំរួលក្នុងការរៀបចំបរិស្ថានអោយមានគុណភាពសំរាប់ការរស់នៅ និងសោភ័ណ្ឌភាពល្អផងដែរ។ ដោយការសិក្សានេះត្រូវបានផ្តោតទៅលើការកំណត់បញ្ហាជារួមក្នុងខណ្ឌនេះ ដែលមានបញ្ហាជាចំបងៗ មួយចំនួនដូចជា បញ្ហាបំពុលទឹក បញ្ហាបំពុលដី និងបញ្ហាបំពុលដោយសំណល់រឹង និងរាវដែលជាបញ្ហាដែលមានភាពប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននៃខណ្ឌនេះ ដែលបញ្ហាបានកើតពីច្រើនប្រភពហើយនោះវាបានធ្វើអោយគុណភាពនៃការរស់នៅក្នុងខណ្ឌនេះធ្លាក់ចុះ។ ដោយឡែកវិញ បញ្ហាទាំងនោះក៏ត្រូវបានភ្ជាប់ជាមួយនឹងដំណោះស្រាយយ៉ាងសមស្រប ដែលជាគន្លិះក្នុងការបង្កើនគុណភាពនៃបរិស្ថាន។

សរុបសេចក្តីមក ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌមានជ័យតំរូវអោយមានការសិក្សាស៊ីជម្រៅទៅការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានរបស់ខណ្ឌដើម្បីឈានដល់ការរៀបចំដែលមានប្រសិទ្ធិភាព។ ដោយការរៀបចំនេះ អាចប្រព្រឹត្តិទៅដោយរលូនបានដោយមានការចូលរួមរវាងសំណាក់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ និងសមត្ថកិច្ចដែលមានត្រូវចាត់ចែង ក្នុងតំបន់នោះផងដែរ។ ក្នុងការរៀបចំនេះ ភាពជោគជ័យនៃការអនុវត្តន៍នូវផែនការក្នុងការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថា

នក្នុងខណ្ឌមានជ័យ នឹងផ្តល់អោយមានសោភ័ណ្ឌភាពដល់ទីក្រុង និងការបង្កើនគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ។

# អនុសាសន៍

# អនុសាសន៍

ក្នុងនាមជានិស្សិតដែលបានធ្វើការតាក់តែងសារណានេះ យើងខ្ញុំបាទមាននូវអនុសាសន៍ជាចុងក្រោយក្នុងការស្នើរសុំអោយមានកែសំរួលមួយចំនួនដើម្បីឈានទៅរកការអភិវឌ្ឍន៍ដ៏មានប្រសិទ្ធិភាពសំរាប់ការអភិវឌ្ឍន៍ទៅលើខណ្ឌដែលបានសិក្សាក៏ដូចជាការអភិវឌ្ឍន៍ទៅដល់ខណ្ឌដទៃ។ យើងខ្ញុំបាទសូមស្នើរ៖

- ទៅដល់គណៈអ្នកដឹកនាំទាំងអស់ដែលពាក់ព័ន្ធ សុំចូលរួមក្នុងការពង្រីក និងស្វែងរកវិធានការដែលមានប្រសិទ្ធិភាពក្នុងការដោះស្រាយនូវបញ្ហាផ្នែកបរិស្ថាន ក៏ដូចជាការទប់ស្កាត់នូវចរាចរណ៍របស់រថយន្តធំៗ ដែលប៉ះពាល់ដល់គុណភាពនៃការរស់នៅក្នុងតំបន់នោះ។
- ទៅដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ និងភ្នាក់ងារមានសមត្ថកិច្ចក្នុងតំបន់នោះចូលរួមក្នុងការថែរក្សា និងការពារបរិស្ថាន និងសណ្តាប់ធ្នាប់ក្នុងខណ្ឌ។
- ទៅដល់គណៈអ្នកដឹកនាំទាំងអស់ដែលពាក់ព័ន្ធចូលរួម ក្នុងការបង្កើតជាវេទិកា ក្នុងការអប់រំដល់ប្រជាពលរដ្ឋ អោយយល់ដឹងពីបរិស្ថាន និងគោលការណ៍អភិវឌ្ឍន៍ខណ្ឌ។
- អោយមានការរឹតបន្តឹងនូវការអនុវត្តច្បាប់ និងពិន័យក្នុងការល្មើស ឬក៏បានបំផ្លាញនូវបរិស្ថាន។
- អោយមានការធានាបាននូវបានការអនុវត្តជាក់ស្តែងនូវគំរោងដែលបានរៀបចំ និងធានាអោយមានការអនុវត្តយ៉ាងខ្ជាប់ខ្ជួន។
- អោយមានដំណោះស្រាយសំរាប់បញ្ហាសំណល់ក្នុងតំបន់ជាអសន្នដោយហេតុថា តំបន់នេះកំពុងរងគ្រោះជាធ្ងន់ធ្ងរដោយសំណល់រឹង និងរាវដែលគ្មានការគ្រប់គ្រង។
- ទៅដល់និស្សិត និងអ្នកដែលបានអានសិក្សាលើសារណានេះទាំងអស់ ក្នុងការចូលរួមចែករំលែកចំណេះដឹងលើបញ្ហានេះ ដើម្បីអោយមានការចូលរួមក្នុងការដោះស្រាយនិងការរៀបចំខណ្ឌនេះផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣
- ប្រកាសលេខ ៣៩៨ ប្រក របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក ខណ្ឌ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០០

## សៀវភៅនៃឯកសារ

- សៀវភៅនីតិនគរូបនីយវិទ្យា របស់លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា បង្រៀនឆ្នាំ២០១៦ ២០១៧
- សៀវភៅមូលដ្ឋានគ្រឹះនៃបរិស្ថាន របស់លោក ស្ពាន់ វិន និពន្ធខែឧសភា ឆ្នាំ២០០៦
- សៀវភៅសិក្សាពីបរិស្ថាន សំរាប់ឆ្នាំមូលដ្ឋាន IFL របស់លោក ឌីម សូរយង់ ឆ្នាំ២០១១
- វចនានុក្រមខ្មែរ របស់សម្តេចសង្ឃរាជ ជួន ណាត
- ព្រឹត្តិបត្ររដ្ឋបាលរាជធានីភ្នំពេញលេខ១៩ ខែឧសភា ឆ្នាំ២០១៦
- អត្ថបទស្រាវជ្រាវស្តីពីការបំពុលខ្យល់នៅរាជធានីភ្នំពេញ របស់លោក ម៉ាសាមី ហ្សូរ៉ឆី
- អត្ថបទ National Reporting Guidelines for CDS-14/15 Thematic Areas របស់ក្រសួងបរិស្ថាន
- អត្ថបទស្រាវជ្រាវស្តីពី Urban Solid Waste Disposal: A case study of the city of Phnom Penh របស់លោក Sarin ឆ្នាំ១៩៩៨
- អត្ថបទស្រាវជ្រាវស្តីពី The study of Solid Waste Management in the Municipality of Phnom Penh របស់ JICA ឆ្នាំ២០០៤

# គេហទំព័រ

- គេហទំព័រ http://phnompenh.gov.kh/ (គេហទំព័រសាលារាជធានីភ្នំពេញ)
- គេហទំព័រ http://worldpopulationreview.com/
- គេហទំព័រ http://www.khmertimeskh.com/
- គេហទំព័រ http://www.waterwise.co.za/
- គេហទំព័រ http://www.wepa-db.net/
- គេហទំព័រ https://urbanvoicecambodia.net/
- គេហទំព័រ http://www.gogreenacademy.com/
- គេហទំព័រ http://www.conserve-energy-future.com/
- គេហទំព័រ http://epi.yale.edu/country/cambodia
- គេហទំព័រ http://www.open.edu/
- គេហទំព័រ http://www.groundwater.org/
- គេហទំព័រ https://www.hunterwater.com.au/
- គេហទំព័រ http://www.signalwaste.com.au/
- គេហទំព័រ http://eschooltoday.com/
- គេហទំព័រ http://www.maciejdakowicz.com/
- គេហទំព័រ http://www.phnompenhpost.com/
- គេហទំព័រ https://www.theguardian.com/

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦

ឧបសម្ព័ន្ធទី២ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០

ឧបសម្ព័ន្ធទី៣ ៖ អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៣

ឧបសម្ព័ន្ធទី៤ ៖ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩

ឧបសម្ព័ន្ធទី៥ ៖ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

ឧបសម្ព័ន្ធទី៦ ៖ អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

ឧបសម្ព័ន្ធទី៧ ៖ តារាងបែងចែកសំណល់តាមប្រភេទ

ឧបសម្ព័ន្ធទី៨ ៖ តារាងសមាសធាតុសំណល់រឹងនៅភ្នំពេញ

ឧបសម្ព័ន្ធទី៩ ៖ តារាងស្តង់ដារគុណភាពខ្យល់សាធារណៈ

ឧបសម្ព័ន្ធទី១០ ៖ រូបភាពស្ពានអាកាសក្បាលថ្នល់

ឧបសម្ព័ន្ធទី១១ ៖ រូបភាពស្ពានអាកាសស្ទឹងមានជ័យ

ឧបសម្ព័ន្ធទី១២ ៖ រូបភាពស្ពានអាកាសក្បាលថ្នល់ថ្មី

# ឧបសម្ព័ន្ធទី១

# ច្បាប់

ស្តីពី

# កិច្ចការពារបរិស្ថាន

និង

# ការគ្រប់គ្រងធនធានធម្មជាតិ

# ព្រះរាជក្រម

នស.រកម.១២៩៦.៣៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

*************

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រី ក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅ :

-ការពារ លើកកំពស់គុណភាពបរិស្ថាននិងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយនិងការត្រួតពិនិត្យការបំពុល

-វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង

-ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

-លើកទឹកចិត្តនិងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ

-បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

## ជំពូកទី ២

## ផែនការបរិស្ថានជាតិនិងផែនការបរិស្ថានតំបន់

**មាត្រា ២.-**

ផែនការបរិស្ថានជាតិនិងផែនការបរិស្ថានតំបន់ ត្រូវសំរេចដោយរាជរដ្ឋាភិបាលនិងក្រសួងបរិស្ថានដោយសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣.-**

ផែនការបរិស្ថានជាតិជាផែនការសំរាប់កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរសំរាប់អនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផែនការបរិស្ថានជាតិត្រូវ :

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗនិងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

-លើកឡើងពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាន ។

មាត្រា ៤.-

ផែនការបរិស្ថានតំបន់ ត្រូវអនុលោមតាមផែនការបរិស្ថានជាតិ ។ ផែនការបរិស្ថានតំបន់ត្រូវ :

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗនិងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃតំបន់នីមួយៗ

-លើកឡើងពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាននៃតំបន់នោះ ។

មាត្រា ៥.-

ផែនការបរិស្ថានជាតិនិងផែនការបរិស្ថានតំបន់ត្រូវពិនិត្យនិងកែសំរួលយ៉ាងយូរមួយដងក្នុងរយៈពេលប្រាំឆ្នាំ ។

## ជំពូកទី ៣

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មាត្រា ៦.-

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គំរោងនិងសកម្មភាពរបស់ឯកជនឬសាធារណៈហើយត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ប្រភេទនិងទំហំគំរោងនិងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការទាំងឯកជននិងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

មាត្រា ៧.-

ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគនិងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## ការគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ៨.-**

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើនិងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរ ។

តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជំរកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៩.-**

ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិនិងផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាអោយធនធានធម្មជាតិដូចមានចែងក្នុងមាត្រា ៨ ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរ ។

**មាត្រា ១០.-**

មុនពេលចេញសេចក្តីសំរេចនានាឬធ្វើសកម្មភាពផ្សេងៗ ទាក់ទិនដល់ការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធត្រូវពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានអំពីនិរន្តរភាពនិងភាពស្ថិតស្ថេរនៃធនធានធម្មជាតិ ។

**មាត្រា ១១.-**

ក្រសួងបរិស្ថានត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាក់ព័ន្ធ នៅពេលណាដែលក្រសួងបរិស្ថានពិនិត្យឃើញថា ធនធានធម្មជាតិមិនមានការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងការប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តភាពនិងភាពស្ថិតស្ថេរទេនោះ ។

## ជំពូកទី ៥

## កិច្ចការពារបរិស្ថាន

**មាត្រា ១២.-**

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី :

-ប្រភព ប្រភេទនិងបរិមាណនៃសារធាតុបំពុលនិងសំណល់ដែលបាននាំចូល បង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោលឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដីឬលើដី

-ប្រភព ប្រភេទនិងបរិមាណនៃសារធាតុពុលនិងសារធាតុប្រកបដោយគ្រោះថ្នាក់ដែលបាននាំចូល ផលិត ដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើង បានប្រព្រឹត្តកម្ម កែច្នៃឡើងវិញ បោះបង់ចោលឬដែលបានបញ្ចេញចោលទៅក្នុងអាកាស ទឹកឬទៅក្នុងដីឬលើដី

-ប្រភព ប្រភេទនិងទំហំនៃការរំខានដោយសម្លេងនិងរំញ័រ ។

**មាត្រា ១៣.-**

ការទប់ស្កាត់ ការកាត់បន្ថយនិងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខានដោយសម្លេងនិងរំញ័រព្រមទាំងសំណល់ សារធាតុពុលនិងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## ការត្រួតពិនិត្យ កំណត់ត្រា អធិការកិច្ច

**មាត្រា ១៤.-**

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ឱ្យម្ចាស់កម្មសិទ្ធិឬអ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្មឬតំបន់មានសកម្មភាពអភិវឌ្ឍន៍ធនធានធម្មជាតិនានា :

-តម្លើងឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ

-ផ្តល់គំរូតាង

-រៀបចំឬរក្សាទុកនិងផ្ញើជូនពិនិត្យនូវកំណត់ត្រានិងរបាយការណ៍នានា ។

មាត្រា ១៥.-

ដើម្បីអនុវត្តការកិច្ចរបស់ខ្លួននិងក្នុងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ ទីក្នុងបរិវេណ អាគារ លើឬក្នុងមធ្យោបាយដឹកជញ្ជូនឬទីកន្លែងណាមួយ ។ ល ។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពនោះធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន ។

មន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថាននិងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណនិងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅមុនពេលធ្វើអធិការកិច្ច ។

នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌកើតឡើង នោះមន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់ ។

នីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

## ជំពូកទី ៧
## ការចូលរួមរបស់សាធារណជននិងការស្រង់យកពត៌មាន

មាត្រា ១៦.-

ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវពត៌មានពីសកម្មភាពរបស់ខ្លួននិងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ១៧.-

បែបបទនៃការចូលរួមរបស់សាធារណជននិងការស្រង់យកពត៌មានក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

មាត្រា ១៨.-

ពត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថានឬការគ្រប់គ្រងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមក រវាងក្រសួងបរិស្ថាននិងក្រសួងនានា ។

## ជំពូកទី ៨
## មូលនិធិទាយជ្ជទានបរិស្ថាន

**មាត្រា ១៩.-**

ត្រូវបង្កើតគណនីពិសេសរបស់រតនាគារជាគណនីមូលនិធិទាយជ្ជទានបរិស្ថាន សំរាប់ឱ្យក្រសួងបរិស្ថានយកទៅចាត់ចែងក្នុងកិច្ចការពារបរិស្ថាននិងការអភិរក្សធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានបរិស្ថាន ដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាលនិងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិដើម្បីផ្តល់ឱ្យគណនីពិសេសខាងលើ ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

ចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតម្រូវឱ្យ :

-កែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ឬ

-ផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ឬ

–លុបបំបាត់ការបំពុលជាបន្ទាន់ ។

**មាត្រា ២១.-**

បុគ្គលណាមិនអនុញ្ញាតឬរារាំងមិនឱ្យមន្ត្រីអធិការកិច្ចចូលធ្វើការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចលើទីតាំងដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៥ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីប្រាំសែនរៀល(៥០០.០០០រៀល) ដល់មួយលានរៀល(១.០០០.០០០រៀល) ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ប្រាំលានរៀល(៥.០០០.០០០រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ដល់ ៣ ខែ ឬទោសទាំងពីរនេះ ។

បុគ្គលណាប្រព្រឹត្តល្មើសនឹងមាត្រា ២០ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីមួយលានរៀល( ១.០០០.០០០រៀល ) ដល់ដប់លានរៀល( ១០.០០០.០០០រៀល ) ។ ក្នុងករណីកុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីម្ភៃមួយលានរៀល ( ២១.០០០.០០០រៀល ) ដល់សាមសិបលានរៀល ( ៣០.០០០.០០០រៀល ) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ២២.-**

បើការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយឬជីវិតមនុស្ស ដល់ទ្រព្យសម្បត្តិឯកជន ដល់ទ្រព្យសម្បត្តិសាធារណៈ ដល់បរិស្ថាន ដល់ធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លានរៀល ( ១០.០០០.០០០រៀល ) ដល់ហាសិបលានរៀល (៥០.០០០.០០០រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំឬទោសទាំងពីរនេះ ។

បុគ្គលដែលប្រព្រឹត្តល្មើសត្រូវទទួលជួសជុលសងការខូចខាតនិងសងជំងឺចិត្តថែមទៀត។

**មាត្រា ២៣.-**

ក្នុងករណីដែលការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះមហន្តរាយធ្ងន់ធ្ងរចំពោះសង្គមជាតិ តុលាការអាចនឹងយកកាលៈទេសៈទម្ងន់ទោស ទៅប្រកបផ្សំនឹងបទល្មើសណាមួយខាងលើនេះដើម្បីផ្តន្ទាទោស ។

**មាត្រា ២៤.-**

មន្ត្រីឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាលឬនឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ។

**មាត្រា ២៥.-**

ក្រសួងបរិស្ថាន ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០ ខាងលើចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនិងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្នុងករណីរឹងទទឹង ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

**រក្សាសិទ្ធិគ្រប់បែបយ៉ាង**

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

មាត្រា ២៦.-

ក្រោយពេលច្បាប់នេះចូលជាធរមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ចំពោះសកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន រាជរដ្ឋាភិបាលអាចពន្យារពេលការប្រតិបត្តិអនុក្រឹត្យ ដែលចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ក្នុងការសម្រេចពន្យារពេលនេះត្រូវ :

-ថ្លឹងថ្លែងពីប្រភេទនិងទំហំនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដល់បរិស្ថាននិងដល់ធនធានធម្មជាតិ ដែលអាចកើតឡើងពីការពន្យារពេលនេះ

-ពិនិត្យទៅលើលទ្ធភាព មធ្យោបាយ បច្ចេកទេសនិងហិរញ្ញវត្ថុរបស់សកម្មភាពដែលកំពុងដំណើរការនេះ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

មាត្រា ២៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

*ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦*

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះបរមរាជក្រម

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា | ហត្ថលេខា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

លេខ : ០១ [illegible]

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

[illegible]

# ឧបសម្ព័ន្ធទី២

នស/រកត/០៩១០/៧៦៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកឃុំចំនួន ២០ នៃខេត្តកណ្តាល មកបញ្ចូលក្នុងរាជធានីភ្នំពេញ មានដូចខាងក្រោម :

១-ឃុំព្រែកព្នៅ ឃុំសំរោង និងឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល ត្រូវបានបញ្ចូលមកក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ

២-ឃុំពន្សាំង ឃុំស្នោរ ឃុំឪឡោក ឃុំបឹងធំ ឃុំកំបូល និងឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ត្រូវបានបញ្ចូលមកក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ

៣-ឃុំគងនយ ឃុំទៀន ឃុំរលួស ឃុំស្ពានថ្ម និងឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ត្រូវបានបញ្ចូលមកក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ

៤-ឃុំវាលស្បូវ ឃុំព្រែកឯង ឃុំក្បាលកោះ និងឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ត្រូវបានបញ្ចូលមកក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ

៥-ឃុំបាក់ខែង និងឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ត្រូវបានបញ្ចូលមកក្នុងខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវបានកំណត់ដូចមានក្នុងផែនទីឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.១០០៥.៧៧៩

នរោត្តម សីហមុនី

លេខ: ៦៨១ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ កញ្ញា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ឃុន ចិនកេន

# ឧបសម្ព័ន្ធទី៣

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

# ការគ្រប់គ្រងសំណល់រឹង

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី ២ ខែមេសា ឆ្នាំ១៩៩៩ ។

# សំរេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១** អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុកប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- " **សំណល់រឹង** " គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវឱ្យបោះបង់ចោល ។

ខ- " **សំរាម** " គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធាណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ល។

គ- " **សំណល់ប្រកបដោយគ្រោះថ្នាក់** " គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈនិងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្ម អាជីវកម្មរ៉ែ ។ល។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

**មាត្រា ៤** ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

**មាត្រា ៥** ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា ៦** ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧** ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៨** ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ៩** ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាម៉ីប្រទេស ជាមុនសិន ។

**មាត្រា ១០** ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ១១** ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

**មាត្រា ១២** ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ១៣** ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព ។

**មាត្រា ១៤** ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក- ប្រភេទ និងបរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់ ។

**មាត្រា ១៥** ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភពឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

**មាត្រា ១៦** ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សង្កាត់ មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាននិងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា ១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្តីពី គោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ១៧** ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ១៨** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក- ប្រភេទ និងបរិមាណសំណល់

ខ- ប្រភពដើមរបស់សំណល់

គ- ការដឹកជញ្ជូន និងមធ្យោបាយវេចខ្ចប់

ឃ- ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

**មាត្រា ១៩** ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

**មាត្រា ២០** ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាម៉ីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពី ការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ១៩៩២ ។

**មាត្រា ២១** ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ៤
## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច
## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

**មាត្រា ២២** ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣** ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ២៣ នេះ ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២៤** ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

មាត្រា ២៥ ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតិពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ចដល់ទីកន្លែងនោះ ដោយអនុវត្តន៍តាមនិតិវិធី ដែលមានចែងខាងក្រោម :

ក - បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ - ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុនិងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ - ត្រូវសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ - ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

មាត្រា ២៦ ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥
## ទោសបញ្ញត្តិ

មាត្រា ២៧ ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោសដោយយោងទៅតាម មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ២៨ មន្ត្រីឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិន គោរពបទបញ្ជារបស់ក្រសួង ឃុបឃិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៩** កំណត់ហេតុនិងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី ៦
## អវសានបញ្ញត្តិ

**មាត្រា ៣០** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣២** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៧ខែមករា ឆ្នាំ ១៩៩*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល***
- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣១*
- *កាលប្បវត្តិ-ឯកសារ*

*បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី*
*ដើម្បីចុះហត្ថលេខា*

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១ - សំណល់សរសៃអំបោះ និងកំទេចក្រណាត់ដែលមានពណ៌ ( ក្នុងករណីយកទៅដុត )

២ - សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស

៣ - សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និងទឹកល្អ

៤ - សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម

៥ - សំណល់ចាស្ទិច "ប៉ូលីវីនីលក្លរ"

៦ - សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល។

៧ - សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៊ុយទីលីន

៨ - សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩ - សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០- សំណល់ដែលមានផ្ទុកជាតិបាស

១១- សំណល់លោហៈ និងសមាសធាតុរបស់វា រួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១២- លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣- សំណល់អំពូលអគ្គីសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គីសនី

១៤- សំណល់អាគុយ និងថ្មពិល

១៥- សំណល់ថ្នាំលាបនិងថ្នាំជ្រលក់ពីណ និងសំភារៈវេចខ្ចប់ថ្នាំពីណ

១៦- សំណល់បានមកពីការផលិត និងការប្រើប្រាស់ទឹកខ្មៅបោះពុម្ភ

១៧- សំណល់គ្រឿងផ្ទុះ

១៨- សំណល់ដែលនាំអោយមានការចំលងមេរោគ ឬជំងឺ

១៩- សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសំភារៈវេចខ្ចប់

២០- សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រភពដោយគ្រោះថ្នាក់

២១- ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២- សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ

២៣- សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤- សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

២៥- សំណល់ដែលជាសមាសធាតុសរីរាង្គក្លរអរីន

២៦- សំណល់ដែលជាសមាសធាតុស៊ីអានីត

២៧- សំណល់ដែលជាសមាសធាតុអាសបេស្តូស

២៨- សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$ )

២៩- សំណល់ដែលជាសមាសធាតុអេទែ ( $R\text{-}COO\text{-}R_1$ )

៣០- សំណល់ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១- សំណល់ដែលជាសមាសធាតុឌីអុកស៊ីន និងហ្វូរ៉ាន

៣២- សំណល់ធាតុវិទ្យុសកម្ម

៣៣- សារធាតុ ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែង ពីចំនុចទី ១ ដល់ទី ៣២

# ឧបសម្ព័ន្ធទី៤

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

(ꧮ)

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៩៩ ។

# សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១** អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២** អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ៣** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- " **តំបន់ទឹកសាធារណៈ** " : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ- " **ប្រភពបំពុល** " : គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូននិងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ។

គ- " **សំណល់រាវ** " : គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ- " **ទឹកលូ** " : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង- " **សំណល់រឹង** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច- " **សំរាម** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ- "**សារធាតុបំពុល**" : គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទ ដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា: ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹក ដោយចេតនាក្តី ឬអចេតនាក្តី ។

ជ- "**បរិមាណសារធាតុបំពុល**" : គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ- "**សារធាតុប្រកបដោយគ្រោះថ្នាក់**" : គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមាន គ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយ ប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុង តារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤** កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥** ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់និមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្ស ជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦** ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

មាត្រា ៧ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

កំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៨ ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

មាត្រា ៩ ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣
## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

មាត្រា ១០ ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

មាត្រា ១១ ប្រភេទនៃប្រភពបំពុល ដែលតំរូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹតនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

- ក- ប្រភពបំពុលប្រភេទថ្នាក់ទី ១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។
- ខ- ប្រភពបំពុលប្រភេទថ្នាក់ទី ២ ចាំបាច់តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ។

មាត្រា ១២ ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានលួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

មាត្រា ១៣ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន ៖

- អោយបានមុន ៤០ ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ ថ្ងៃសំរាប់គំរោងនៅតាមខេត្តក្រុង នៃការចាប់ផ្តើមដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

- អោយបានក្នុងរយៈពេល ៣០ ថ្ងៃសំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

មាត្រា ១៤ លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះ ត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំណត់ដោយក្រសួងបរិស្ថាន ។

មាត្រា ១៥ ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ ថ្ងៃនៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

មាត្រា ១៦ បុគ្គលដែលផ្ទេរ ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម ដែលបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំណុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការផ្ទេរ ឬការកាន់កាប់បន្តរបស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការផ្ទេរ ឬកាន់កាប់បន្តនោះ ។

មាត្រា ១៧ លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅអោយម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាស័ន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងមាត្រាណាមួយ នៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

មាត្រា ១៨ ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ១៩ ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

មាត្រា ២០ ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

មាត្រា ២១ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

មាត្រា ២២ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

មាត្រា ២៣ ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវ :

ក- ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាត និងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រិត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ- មានសំភារៈនិងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ- ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុល ដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវធ្វើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ ខែម្តង ។

មាត្រា ២៤ ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក- ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយះពេលជាក់លាក់មួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ- ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

**មាត្រា ២៥** កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់ការពារសុខភាពសាធារណៈ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៦** ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ២៧** ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨** ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩** ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦
## - នីតិវិធីនៃការធ្វើអធិការកិច្ច

មាត្រា ៣០ នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនិតិវិធី ដូចមានចែងខាងក្រោម :

ក - បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម របស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុល ដើម្បីធ្វើអធិការកិច្ច យកគំរូតាងឬពិនិត្យកំណត់ត្រា

ខ - កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ - មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ - របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

មាត្រា ៣១ ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

មាត្រា ៣២ ក្នុងករណីមានឧប្បទ្ទវហេតុឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣** ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវៈ

ក- ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ- ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤** ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៥** កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៦** មន្ត្រីឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣៧** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្ដីជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

# តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១ - សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក

២ - សមាសធាតុសរីរាង្គផូស្វរ

៣ - សមាសធាតុសរីរាង្គទីន

៤ - សារធាតុដែលបង្កអោយមានជំងឺមហារីក

៥ - បារត និងសមាសធាតុរបស់វា

៦ - កាត់ម្ញូម និងសមាសធាតរបស់វា

៧ - សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨ - សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹក ហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩ - សារធាតុវិទ្យុសកម្ម

១០- លោហះនិងសមាសធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១- សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២- សមាសធាតុអសរីរាង្គផូស្វរ

១៣- សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤- សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥- សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

# តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតិឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^0C$ | < 45 | < 45 |
| 2 | pH | | 6 – 9 | 5 - 9 |
| 3 | $BOD_5$ | mg/l | < 30 | < 80 |
| 4 | COD | mg/l | < 50 | < 100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | < 60 | < 120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | < 1000 | < 2000 |
| 7 | ប្រេង រឺខ្លាញ់ | mg/l | < 5.0 | < 15 |
| 8 | សាប៊ូ | mg/l | < 5.0 | < 15 |
| 9 | ផេណុល | mg/l | < 0.1 | < 1.2 |
| 10 | នីត្រាត | mg/l | < 10 | < 20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | < 1.0 | < 2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | < 500 | < 700 |
| 13 | ស៊ុលផាត | mg/l | < 300 | < 500 |
| 14 | ស៊ុលហ្វីត | mg/l | < 0.2 | < 1.0 |
| 15 | ផូស្វាត | mg/l | < 3.0 | < 6.0 |
| 16 | ស៊ីអានីត ( $CN^{-1}$ ) | mg/l | < 0.2 | < 1.5 |
| 17 | បារ្យ៉ូម ( Ba ) | mg/l | < 4.0 | < 7.0 |
| 18 | អាសេនិច ( As ) | mg/l | < 0.10 | < 1.0 |
| 19 | សំណប៉ាហាំង ( Sn ) | mg/l | < 2.0 | < 8.0 |
| 20 | ដែក (Fe) | mg/l | < 1.0 | < 20 |
| 21 | បរ ( B ) | mg/l | < 1.0 | < 5.0 |
| 22 | ម៉ង់កាណែស ( Mn ) | mg/l | < 1.0 | < 5.0 |

| | | | | |
|---|---|---|---|---|
| 23 | កាត់ម្យ៉ូម ( Cd ) | mg/l | < 0.1 | < 0.5 |
| 24 | ក្រូម ( Cr )$^{+3}$ | mg/l | < 0.2 | < 1.0 |
| 25 | ក្រូម ( Cr )$^{+6}$ | mg/l | < 0.05 | < 0.5 |
| 26 | ទង់ដែង ( Cu ) | mg/l | < 0.2 | < 1.0 |
| 27 | សំណ ( Pb ) | mg/l | < 0.1 | < 1.0 |
| 28 | បារត (Hg) | mg/l | < 0.002 | < 0.05 |
| 29 | នីកែល ( Ni ) | mg/l | < 0.2 | < 1.0 |
| 30 | សេលេញ៉ូម ( Se ) | mg/l | < 0.05 | < 0.5 |
| 31 | ប្រាក់ ( Ag ) | mg/l | < 0.1 | < 0.5 |
| 32 | ស័ង្កសី ( Zn ) | mg/l | < 1.0 | < 3.0 |
| 33 | ម៉ូលីបដែន ( Mo ) | mg/l | < 0.1 | < 1.0 |
| 34 | អាម៉ូញាក់ ( $NH_3$ ) | mg/l | < 5.0 | < 7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | > 2.0 | > 1.0 |
| 36 | ប៉ូលីក្លរ បីផេនីល ( PCB ) | mg/l | < 0.003 | < 0.003 |
| 37 | កាល់ស្យូម ( Ca ) | mg/l | < 150 | < 200 |
| 38 | ម៉ាញ៉េស្យូម ( Mg ) | mg/l | < 150 | < 200 |
| 39 | កាបូនតេត្រាក្លរ | mg/l | < 3 | < 3 |
| 40 | អ៊ិចសាក្លរបង់សែន | mg/l | < 2 | < 2 |
| 41 | ដេដេតេ | mg/l | < 1,3 | < 1,3 |
| 42 | អង់ទ្រីន | mg/l | < 0,01 | < 0,01 |
| 43 | ឌីអលទ្រីន | mg/l | <0,01 | < 0,01 |
| 44 | អេនទ្រីន | mg/l | < 0,01 | < 0,01 |
| 45 | អ៊ីសូទ្រីន | mg/l | < 0,01 | < 0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | < 2,5 | < 2,5 |
| 47 | អ៊ិចសាក្លរប៊ុយតាឌីអែន | mg/l | < 3 | < 3 |
| 48 | ក្លរហ្វម | mg/l | < 1 | < 1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | < 2,5 | < 2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | < 1 | < 1 |
| 51 | ទ្រីក្លរបង់សែន | mg/l | < 2 | < 2 |
| 52 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | mg/l | < 2 | < 2 |

**កំណត់សំគាល់** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវសហការរៀបចំកំរិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

# តារាងឧបសម្ព័ន្ធ ៣

## ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | - ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | - ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | - ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | - ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | - ទីតាំងផលិតម្សៅមី | ទី១ |
| 6 | - ទីតាំងផលិតស្ករស | ទី១ |
| 7 | - ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | - ទីតាំងផលិតស្មូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | - ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | - ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | - ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | - ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | - ទីតាំងផលិតដំបែ និងមេស្រា | ទី១ |
| 14 | - ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | - ទីតាំងផលិតបារី | ទី១ |
| 16 | - ទីតាំងកាត់ដេរគ្មានក្រឡុកជោក | ទី១ |
| 17 | - សណ្ឋាគារ | ទី១ |
| 18 | - ភោជនីយដ្ឋាន | ទី១ |
| 19 | - ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | - ទីតាំងសត្តឃាត | ទី១ |
| 21 | - ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | - ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | - ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | - ទីតាំងផលិតរបស់ផ្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | - ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | - ទីតាំងផលិតជ័រកាវ | ទី១ |

| | | |
|---|---|---|
| 27 | - ទីតាំងបង្កក និងកែច្នៃជ័រក្រេប | ទី១ |
| 28 | - ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | - ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | - ការដ្ឋានយកថ្ម | ទី១ |
| 31 | - ការដ្ឋានយកគ្រួស | ទី១ |
| 32 | - ទីតាំងផលិតក្ដារបន្ទះ | ទី១ |
| 33 | - ទីតាំងផលិត រឺកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | - ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | - នាវាដឹកសារធាតុរាវ | ទី២ |
| 36 | - ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | - ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | - ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | - ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | - ទីតាំងកប់ រឺចាក់ចោលសំណល់រឹង | ទី២ |
| 41 | - ទីតាំងតំបាញ រឺជ្រលក់ពណ៌ | ទី២ |
| 42 | - ទីតាំងកាត់ដេរមានក្រឡុកចោក | ទី២ |
| 43 | - ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | - ទីតាំងបោះពុម្ពទសនាវដ្ដី និងឯកសារផ្សេងៗ | ទី២ |
| 45 | - ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | - ទីតាំងផលិតថ្មពិល-អាគុយ | ទី២ |
| 47 | - ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | - ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | - ទីតាំងផលិតជ័រក្រាលថ្នល់ | ទី២ |
| 50 | - ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | - ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | - ទីតាំងផលិតឱសថ | ទី២ |
| 53 | - ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | - ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | - ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | - ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | - ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | - ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | - ទីតាំងទីតាំងក្លូម៉េរបស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | - ទីតាំងដុត រឺកែច្នៃសំណល់រឹង | ទី២ |
| 61 | - ទីតាំងប្រព្រឹត្តកម្មសំអាតជី | ទី២ |
| 62 | - ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | - ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់វាវឧស្សាហកម្ម | ទី២ |
| 64 | - មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | - រោងចក្រអគ្គីសនី | ទី២ |
| 66 | - ទីតាំងកែច្នៃឈើ | ទី២ |
| 67 | - ការដ្ឋានស្រែបង្គា | ទី២ |

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក

### ១_ សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 25-100 |
| 4 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម ( Coliform ) | MPN/100ml | <5000 |

### ២_ សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 1-15 |
| 4 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម ( Coliform ) | MPN/100ml | <1000 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,005-0,05 |

### ៣_ សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កំរិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម ( Coliform ) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង (Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

# តារាងឧបសម្ព័ន្ធ ៥

## កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ
## សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លរ | µg/l | < 12 |
| 2 | អ៊ិចសាក្លរូបង់សែន | µg/l | < 0,03 |
| 3 | ដេដេតេ | µg/l | < 10 |
| 4 | អង់ឌ្រីន | µg/l | < 0,01 |
| 5 | ឌីអលឌ្រីន | µg/l | < 0,01 |
| 6 | អេនឌ្រីន | µg/l | < 0,005 |
| 7 | អ៊ីសូឌ្រីន | µg/l | < 0,005 |
| 8 | ពែក្លរូអេទីឡែន | µg/l | < 10 |
| 9 | អ៊ិចសាក្លរូប៊ុយតាឌីអែន | µg/l | < 0,1 |
| 10 | ក្លរូហ្វម | µg/l | < 12 |
| 11 | 1,2 ឌីក្លរូអេទីឡែន | µg/l | < 10 |
| 12 | ទ្រីក្លរូអេទីឡែន | µg/l | < 10 |
| 13 | ទ្រីក្លរូបង់សែន | µg/l | < 0,4 |
| 14 | អ៊ិចសាក្លរូស៊ីក្លូអ៊ិចសែន | µg/l | < 0,05 |
| 15 | បង់សែន | µg/l | < 10 |
| 16 | តេត្រាក្លរូអេទីឡែន | µg/l | < 10 |
| 17 | កាត់ម្យូម | µg/l | < 1 |
| 18 | បារតសរុប | µg/l | < 0,5 |
| 19 | បារតសរីរាង្គ | µg/l | 0 |
| 20 | សំណ | µg/l | < 10 |
| 21 | ក្រូមវ៉ាឡង់ ៦ | µg/l | < 50 |
| 22 | អាសេនិច | µg/l | < 10 |
| 23 | សេលេញ៉ូម | µg/l | < 10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល ( PCB ) | µg/l | 0 |
| 25 | ស៊ីអានីត ( $CN^-$ ) | µg/l | <0,005 |

# ឧបសម្ព័ន្ធទី៥

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការត្រួតពិនិត្យការបំពុលខ្យល់

## និងការរំខានដោយសំលេង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០ ។

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- "ប្រភពបំពុល" ចែកចេញជាពីរគឺ :

- ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ប្រភេទ
- ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ- "សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ- "សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ- "កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំរិតអតិបរមានៃសារធាតុបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលនូវសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណ បង់សែន ឬអ៊ីដ្រូកាប៊ូប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងតំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែតំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុខ ៤០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុខ ៦០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គំរោងនៅតាមខេត្ត-ក្រុង ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុនេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីអោយឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក- ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ។

ខ- ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរសុំអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កអោយមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

**មាត្រា ២៦.-**

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារទូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

# ជំពូកទី ៦
# នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ២៩.-**

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាងក្រោម :

ក- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ច យកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ- កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅទីកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ- មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ- របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថាប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក- ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ- ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

# ជំពូកទី ៧
# ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ១
## កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល ១ ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម $mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនម៉ូណូអុកស៊ីត $CO$ | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត $NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូហ្សូន $O_3$ | 0,2 | | | |
| 5 | សំណ $Pb$ | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

**កំណត់សំគាល់**

- កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។
- វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។
- TSP - Total Suspended Particulate

## តារាងឧបសម្ព័ន្ធ ២
## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់
## ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា (mg/m³) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0.03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3\ COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វីត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វរ | $CHCl_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរីត | $CCl_4$ | 3 |
| 11 | កាតស៊ីតដែលមាន asbestos | | គ្មាន |
| 12 | ដេ ដេ តេ | $C_5H_{11}Cl$ | 0,5 |
| 13 | ហ្វរម៉ាល់ដេអ៊ីត | $HCOH$ | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីយ៉ានីត | $HCN$ | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | $HF$ | 0,002 |
| 17 | អ៊ីដ្រូសែន ស៊ុលហ្វីត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $ClCHCCl_2$ | 0,2 |
| 23 | តូលុយអែន | $C_6H_5CH_3$ | 0,4 |
| 24 | វីនីលក្លរ | $ClCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេនិច ( សមាសធាតុអសរីរាង្គ ) | As | 0,00001 |
| 26 | កាត់ម្ញូម ( សមាសធាតុលោហៈ និងអុកស៊ីត ) | Cd | 0,003 |
| 27 | ក្រូម ( លោហៈ និងសមាសធាតុ ) | Cr | 0,0015 |
| 28 | នីកែល ( លោហៈ និងសមាសធាតុ ) | Ni | 0,0001 |
| 29 | បារត ( លោហៈ និងសមាសធាតុ ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

## តារាងឧបសម្ព័ន្ធ ៣
## កម្រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ
## ពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត្រ | | កម្រិតអតិបរមានៃការបញ្ចេញ |
|---|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | | |
| | - ឡដុត | | 400 mg/m³ |
| | - រោងចក្រផលិតលោហធាតុ | | 400 mg/m³ |
| | - រោងចក្រស៊ីម៉ង់ត៍ កំបោ និងថ្មស្លុយ | | 400 mg/m³ |
| | - រោងចក្របេតុងអាស្វាល់ | | 500 mg/m³ |
| 2 | ធូលី ដែលមានភ្ជាប់ : | | |
| | - សារធាតុ ស៊ីលីកាត $SiO_2$ | | 100 mg/m³ |
| | - សារធាតុ Asbetos | | 27µg/m³ |
| | សារធាតុគីមីអសរីរាង្គ : | | |
| 3 | អាលុយមីញ៉ូម | Al | (ធូលី) 300mg/m³ , (Al) 50mg/m³ |
| 4 | អាម៉ូញ៉ាក់ | $NH_3$ | 100 mg/m³ |
| 5 | អាង់ទីម៉ូន | Sb | 25 mg/m³ |
| 6 | អាសេនិច | As | 20 mg/m³ |
| 7 | បេរីល្យូម | Be | 10 µg/m³ |
| 8 | ក្លរ | Cl | 20 mg/m³ |
| 9 | អ៊ីដ្រូសែនក្លរីត | HCl | 200 mg/m³ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត | HF | 10 mg/m³ |
| 11 | អ៊ីដ្រូសែនស៊ុលភីត | $H_2F$ | 2 mg/m³ |
| 12 | កាត់ម៉្យូម | Cd | 1 mg/m³ |
| 13 | ទង់ដែង | Cu | (ធូលី) 300 mg/³ (Cu) 20 mg/m³ |
| 14 | សំណ | Pb | (ធូលី) 100 mg/m³ , (Pb) 30 mg/m³ |
| 15 | ស័ង្កសី | Zn | 30 mg/m³ |
| 16 | បារត | Hg | 0,1 mg/m³ |
| 17 | កាបូនម៉ូណូអុកស៊ីត | CO | 1000 mg/m³ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត ( គ្រប់ប្រភេទ ) $NO_x$ | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត ( ចេញពីការផលិតអាស៊ីត ) $NO_x$ | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត $SO_3$ | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វរិច $H_3PO_4$ | 3 $mg/m^3$ |
| | <u>សារធាតុគីមីសរីរាង្គ</u> : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2\ CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ីន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,p-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរបង់សែន $C_6H_5CL$ | 350 $mg/m^3$ |
| 34 | ក្លរហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរពិគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O - ឌីក្លរបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1,1 - ឌីក្លរអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,p-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2\text{-}CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ $HCHO$ | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 $mg/m^3$ |

| | | | |
|---|---|---|---|
| 49 | នីត្រូបង់សែន | $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន | $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន | $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល | $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្ស៊ីន | $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន | $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរែន | $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គីណូន | $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរែន | $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1;2,2- តេត្រាក្លរូអេតាន | $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន | $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន | $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន | $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន | $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2,4-ឌីអ៊ីសូស៊ីអាណោត | $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន | $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន | $(CH_3)_2 C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត | $CH_2CHCl$ | 150 mg/m$^3$ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC (ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | 50 |

**កំណត់សំគាល់**

កំរិតកំហេង់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពចល័តចូលទៅក្នុងបរិយាកាស ។

ក- គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេលប្រាំឆ្នាំ គិតចាប់ពីឆ្នាំដែលផលិត ។

ខ- គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេលប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ-បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

# កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភេទយានយន្ត

| ល.រ | ប្រភេទយានយន្ត | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1- | ម៉ូតូក្រយានយន្តចំណុះស៊ីឡាំង (cc) < 125 $cm^3$ | 85 |
| 2- | ម៉ូតូក្រយានយន្តចំណុះស៊ីឡាំង (cc) ≥ 125 $cm^3$ | 90 |
| 3- | ត្រីចក្រយានយន្ត | 90 |
| 4- | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ < 12នាក់ | 80 |
| 5- | រថយន្តដឹកអ្នកដំណើរ ≥ 12នាក់ | 85 |
| 6- | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ <3.5 តោន | 85 |
| 7- | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ ≥ 3.5 តោន | 88 |
| 8- | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9- | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភេទយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ-បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៦
# កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់
# សាធារណៈ និងតំបន់លំនៅដ្ឋាន (dB (A) )

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង៦ ព្រឹកដល់ ម៉ោង១៨ ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ ម៉ោង២២ យប់ | ពីម៉ោង២២ យប់ ដល់ម៉ោង៦ ព្រឹក |
| 1- | តំបន់ស្ងប់ស្ងៀម<br>- មន្ទីរពេទ្យ<br>- បណ្ណាល័យ<br>- សាលារៀន<br>- មត្តេយ្យសាលា | 45 | 40 | 35 |
| 2- | តំបន់លំនៅដ្ឋាន<br>- សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>- ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3- | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4- | ឧស្សាហកម្មធុនស្រាល លាយចំរុះនៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

# តារាងឧបសម្ព័ន្ធ ៧
# កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង
# ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB (A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំហោត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧
# កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន
# និងអ៊ីដ្រូកាប៊ួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| លរ | សារធាតុចំហេះ | ស្ពាន់ធ័រ (S) | សំណ (Pb) | បង់សែន | អ៊ីដ្រូកាប៊ួប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15 ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើ ដែលអនុញ្ញាតអោយមាននៅក្នុង ប្រេងឥន្ធនៈ និងធ្យូងថ្ម ។

# ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន ០៨ ពីខណ្ឌមានជ័យ នៃរាជធានីភ្នំពេញគឺ សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី។

ព្រំប្រទល់រដ្ឋបាលខណ្ឌច្បារអំពៅ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌមានជ័យដែលស្ថិតនៅក្នុងសង្កាត់ច្បារអំពៅទី១ ទៅឱ្យសាលាខណ្ឌច្បារអំពៅ។

**មាត្រា ៣.-**

ទីតាំងសាលាខណ្ឌមានជ័យ ត្រូវស្ថិតនៅក្នុងសង្កាត់ចាក់អង្រែលើ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌមានជ័យ អភិបាលខណ្ឌមានជ័យ និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៥ ឆ្នាំ២០១៣

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៧

# តារាងអត្រាបែងចែកសំណល់តាមប្រភេទ

| លក្ខណៈគ្រួសារ | ចំណូលជាមធ្យម (រៀល) | ចំនួនប្រជាជនតាមចំណូល ភ្នំពេញ | អត្រាបរិមាណសំណល់ (g/person/day) | |
|---|---|---|---|---|
| | | | រដូវប្រាំង | រដូវវស្សា |
| គ្រួសារចំណូលខ្ពស់ | ១ លាន- លើសជាង | ១០% | ៦៦៨.៥ | ៦៤៦.២ |
| គ្រួសារចំណូលមធ្យម | ៥០ម៉ឺន-៧៥ម៉ឺន | ៣០% | ៥៤៥.៣ | ៥០១.៤ |
| គ្រួសារចំណូលទាប | ក្រោម ៥០ម៉ឺន | ៦០% | ៤៤៥.៩ | ៤៣៥.២ |
| ទំងន់មធ្យម | --- | --- | ៤៩៨.០ | ៤៧៦.១ |

ប្រភព: JICA, 2003 and Vin, 2005.

# ឧបសម្ព័ន្ធទី៨

# តារាងសមាសធាតុសំណល់រឹងនៅភ្នំពេញ

| ចំណាត់ថ្នាក់សំណល់ | | | | សំណល់រឹង | | |
|---|---|---|---|---|---|---|
| | | | | រដូវប្រាំង | រដូវវស្សា | មធ្យម |
| សមាសធាតុរូបធាតុ (ផ្អែកលើគីរិតសំណើម) | ទំងន់ស្រូប | | kg/l | ០.២៥ | ០.២៤ | ០.២៥ |
| | សំណល់ដែលអាចដុតបាន | ក្រដាស | % | ៦.៣ | ៦.៥ | ៦.៤ |
| | | ជ័រ និងស្បែក | % | ០.០ | ០.១ | ០.១ |
| | | សំណល់ផ្ទះបាយ | % | ៦៥.៨ | ៦១.២ | ៦៣.៣ |
| | | សំណល់ក្រណាត់ | % | ២.៣ | ២.៧ | ២.៥ |
| | | សំណល់ប្លាស្ទិក | % | ១៧.១ | ១៣.៨ | ១៥.៥ |
| | | សំណល់ស្មៅនិងឈើ | % | ៣.០ | ១០.៥ | ៦.៨ |
| | | សរុប | % | ៩៤.៥ | ៩៤.៨ | ៩៤.៦ |
| | សំណល់ដែលមិនអាចដុតឆេះបាន | លោហៈធាតុ | % | ០.៣ | ០.៩ | ០.៦ |
| | | ដប និងកែវ | % | ១.៣ | ១.១ | ១.២ |
| | | សេរាមិច និងថ្ម | % | ២.១ | ០.៩ | ១.៥ |
| | | សំណល់ដីទៃទៀត | % | ១.៨ | ២.៣ | ២.១ |
| | | សរុប | % | ៥.៥ | ៥.២ | ៥.៤ |
| | បរិមាណសំណល់សរុប (%) | | | ១០០.០ | ១០០.០ | ១០០.០ |

Source: JICA, 2004.

# ឧបសម្ព័ន្ធទី៩

# តារាងស្តង់ដាគុណភាពខ្យល់សាធារណៈ

| ប៉ារ៉ាម៉ែត្រ | មធ្យម ១ម៉ោង $\mu g/m^3$ | មធ្យម ៨ម៉ោង $\mu g/m^3$ | មធ្យម ២៤ម៉ោង $\mu g/m^3$ | មធ្យម ១ឆ្នាំ $\mu g/m^3$ |
|---|---|---|---|---|
| កាបូនម៉ូណូអុកស៊ីត (CO) | ៤០ | ២០ | | |
| អាសូតឌីអុកស៊ីត (NO2) | 0.៣ | | 0.១ | |
| ស្ពាន់ធ័រឌីអុកស៊ីត (SO2) | 0.៥ | | 0.៣ | 0.១ |
| អូសូន (O3) | 0.២ | | | |
| សំណ (Pb) | | | 0.00៥ | |
| កករសរុប TSP | | | 0.៣៣ | 0.១ |

ប្រភព: *MOE,2004*

សំគាល់: $\mu g/m^3$= មីក្រូក្រាម (0.00១ក្រាម) ក្នុង 1$\mu g/m^3$

# ឧបសម្ព័ន្ធទី១០



# ឧបសម្ព័ន្ធទី១១



# ឧបសម្ព័ន្ធទី១២


2010 11 22 15 10